**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

**ឯកសារដើម**
**ORIGINAL/ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date): 11-Jan-2017, 12:46
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី៤៧៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តារា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៊ាង

លោក ហាសាន អាធុរេលិយ៉ា
*(Mr. Harshan ATHURELIYA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក ស្រ៊ា រតនៈ:

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ(*Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោក ហុង គឹមសួន

លោក វ៉ែន ពៅ

លោកស្រី ជេត វណ្ណលី

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោកស្រី ស្លួ សុទ្ធាវី

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក ខេល លីសាក់ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក វ៉ែន ពៅ | ខ្មែរ |
| សាក្សី 2-TCW-1065 | ខ្មែរ |
| លោក ស សារិន (2-TCCP-237) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី÷** 2-TCW-1065

សួរបន្តដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី........................................................... ទំព័រ ៣

**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី÷ លោក ស សារិន** (2-TCCP-237)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........................................................................ ទំព័រ ១៨
សួរដោយលោក វ៉ែន ពៅ ផ្ដើមពី ........................................................................ ទំព័រ ២១
សួរដោយលោក ឌេល លីសាក់ ផ្ដើមពី ................................................................ ទំព័រ ៤៦

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:៤៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី 2-TCW-1065 បញ្ចប់ ហើយនិងផ្តើមស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-237។

ក្រឡាបញ្ជីសវនាការកញ្ញា ជា ស៊ីវហ៉ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន ភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ លើកលែងតែលោក គង់ សំអុន មេធាវីការពារក្តីឱ្យលោក ខៀវ សំផន ដែលបានជូនដំណឹងមកថា នឹងអវត្តមាននៅក្នុងសវនាការព្រឹកនេះ ដោយមូលហេតុផ្ទាល់ខ្លួន និងលោកស្រី ម៉ារី ហ្គីរ៉ូដ៏ សហមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលអវត្តមានដោយមិនដឹងពីមូលហេតុ។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅព្រឹកនេះ នៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះ មានរហស្សនាម 2-TCW-1065 លោក និងមេធាវីប្រឹក្សាលោកស្រី សុក សុជាតា មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកផ្តល់សក្ខីកម្មបន្ទាប់ទៀតនៅថ្ងៃនេះ មានរហស្សនាម 2-TCCP-237។

សូមអរគុណលោកប្រធាន។

[០៩:០៤:៣៥]

**ប្រធានអង្គជំនុំ៖**

មានបញ្ហាអី? ឧបករណ៍ស្តាប់--

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01377241



*(មានបញ្ហាបច្ចេកទេស)*

បាទ អរគុណ។ ហើយជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។

អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា គាត់មានបញ្ហាសុខភាពឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦។

[០៩:០៥:២៦]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាព ជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះ ថាមានអាការៈឈឺចង្កេះ ឈឺខ្នង ពេលអង្គុយយូរ និងបានផ្តល់អនុសាសន៍ថា សុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការតាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។

[០៩:០៦:៣៨]

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមនិងភាគីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន ខ្ញុំនឹងសួរសំណួរបន្ថែមមួយចំនួនទៅកាន់លោកក្នុងឋានៈខ្ញុំជាមេធាវី។ ដើម្បីឱ្យយល់ច្បាស់ អំពីប្រភពព័ត៌មានដែលលោកបានផ្តល់ជូន ខ្ញុំចង់ត្រឡប់មកនិយាយអំពីខ្សែជីវិតរបស់លោក និងមុខងាររបស់លោកជាគ្រូពេទ្យ។ លោកបានឆ្លើយជូនអង្គជំនុំជម្រះក៏ដូចជានៅក្នុងឯកសាររបស់លោក E3/10667 នៅចម្លើយទី២លោកថា៖ "នៅឆ្នាំ១៩៧៥ ខ្ញុំជាប្រធានក្រុមពេទ្យ <នៅស្រុក>សំរោងបច្ចុប្បន្នគេហៅស្រុកស្វាយទាប។ ពីឆ្នាំ៧៥ ដល់ឆ្នាំ៧៧ ខ្ញុំជាប្រធានពេទ្យ ង-១៥៦"។ សូមបញ្ចប់ការដកស្រង់។ ដូច្នេះ ពាក់ព័ន្ធនឹងរយៈពេលពីឆ្នាំ៧៥ ដល់ ៧៧ នេះខ្ញុំចង់សួរលោកថា ទីតាំងមន្ទីរពេទ្យហ្នឹងឆ្ងាយពីសមរភូមិទេ? គឺសមរភូមិវាយប្រយុទ្ធគ្នាចាប់ពីឆ្នាំ៧៦ ដល់ឆ្នាំ៧៧ នោះ?

[០៩:០៨:២០]

**2-TCW-1065៖**

**ឆ៖** អរគុណ។ ខ្ញុំសូមជម្រាបជូនអ៊ីចេះ ពីឆ្នាំ១៩៧៥ ដល់ ៧៦ ពេលនោះខ្ញុំនៅប្រធានមន្ទីរពេទ្យយោធានៅស្រុកសំរោង ហើយបច្ចុប្បន្នគេហៅថា ស្រុកស្វាយទាប។ គឺទីតាំងមិននៅឆ្ងាយប៉ុន្មានទេ ប្រហែលជា២គីឡូដីទេពីសមរភូមិ។ តែពេទ្យហ្នឹងគេចល័តៗលើសមរភូមិរហូត កាលណាទ័ពទៅណា គឺមន្ទីរពេទ្យហ្នឹងចល័ត ព្រោះពេទ្យយោធា។ បាទ ហ្នឹងពី ៧៥ ទៅ ៧៦។ ហើយពី ៧៦ មក ៧៧ អាហ្នឹងខ្ញុំចេញពីស្រុកសំរោង ខ្ញុំមកនៅភូមិភាគបូព៌ា អ៊ំនែ! នៅកងពលលេខ៤ហើយ។ បាទ អរគុណ។

**ស៖** ដូច្នេះ មានន័យថា ក្នុងចម្លើយនេះគឺមានកំហុសមែនទេ? គឺលោកនៅមន្ទីរពេទ្យស្រុកសំរោងហ្នឹង គឺពី ៧៥ ដល់ ៧៦។ តើអ៊ីចឹងមែនទេ?

**ឆ៖** ត្រឹមត្រូវបាទ។

**ស៖** នៅក្នុងចម្លើយរបស់លោកដដែលគឺឯកសារ E3/10667 នៅចម្លើយទី៣ថា៖ "ខ្ញុំមិនមានសកម្មភាពនៅលើសមរភូមិទេ ចាប់ពីឆ្នាំ១៩៧៦ ដល់ខែធ្នូ ឆ្នាំ១៩៧៧ <នៅពេលដែលគេ>បញ្ជូន<ខ្ញុំ>ឱ្យទៅធ្វើកិច្ចការ ពេទ្យនៅសមរភូមិមុខ។ នៅក្នុងចម្លើយនេះលោកនិយាយពីឆ្នាំ៧៦ ទៅដល់<>ឆ្នាំ៧៧ ដែលថាលោកអត់មានធ្វើសកម្មភាពអីនៅសមរភូមិទេ។ អ៊ីចឹងខ្ញុំចង់ឱ្យលោកបញ្ជាក់ថា តើពេលនុំងលោកនៅកន្លែងណា ហើយលោកមានមុខងារអ្វីខ្លះ?

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** អរគុណ។ ចំពោះខ្ញុំដូចខ្ញុំជម្រាបជូនអំមិញថា នៅចេញពីសមរភូមិ ២គីឡូ យ៉ាងឆ្ងាយគឺ ២គីឡូនៅនុ៎ង គឺពេទ្យនុំងពេទ្យយោធាទេ ពេទ្យចល័តនៅសមរភូមិអត់មានទីតាំងពិតប្រាកដទេ គឺចល័ត រហូត កងទ័ពទៅណាចល័តទៅនុ៎ងៗ។ អាហ្នឹងពីចាប់៧៥ ដល់ ៧៦ ហើយចាប់ពី ៧៦ ទៅ ៧៧ អា ហ្នឹងមកនៅ១៥៦ហើយ គឺកងពលលេខ៤ ហើយ។ ហ្នឹងខ្ញុំនិយាយមួយកំណាត់ៗចុះ ព្រោះលោកសួរក៏ មួយកំណាត់ ខ្ញុំឆ្លើយមួយកំណាត់។ បាទ អរគុណ។

[០៩:១១:០២]

**ស៖** នៅក្នុងវរៈ១៥៦ ហ្នឹងខ្ញុំដឹងហើយ អ៊ីចឹងគឺថាពេលហ្នឹងគឺលោកធ្វើជាប្រធានមន្ទីរពេទ្យ ង-១៥៦ មែនទេ?

**ឆ៖** ត្រឹមត្រូវៗ។

**ស៖** ដូច្នេះ ខ្ញុំដូចជាមិនសូវ<យល់>ចម្លើយរបស់លោក <ដែលលោកនិយាយពីការខុសគ្នា រវាង>សកម្មភាពពី៧៥ ដល់ ៧៦ ហើយ ៧៦ ដល់ ៧៧ ហ្នឹងលោកមានមុខងារខុសគ្នាឬក៏យ៉ាងម៉េច ខ្ញុំ មិនសូវយល់?

**ឆ៖** អរគុណ។ ព្រោះអង្កាល់នៅ គឺថានៅខេត្តស្វាយរៀង ពី៧៥ ដល់ ៧៦ នៅនឹងខេត្តស្វាយ រៀង ពេលនុ៎ងគឺខ្ញុំប្រធានៗពេទ្យនៅពេទ្យយោធាមួយរយ-- នៅស្រុកហ្នឹង។ ហើយដល់ ៧៦ ហ្នឹងគេ បញ្ជូនអង្គភាពហ្នឹងចេញពីស្វាយរៀងមកនៅភូមិភាគបូព៌ានេះ។ អ៊ីចឹងវាមានពីរហ្នឹង។ ហើយមក១៥៦ ក៏ខ្ញុំប្រធានដែរនៅតែប្រធានពេទ្យដដែល។ បាទ អរគុណ។

**ស៖** អ៊ីចឹងគឺមុខងាររបស់លោកមិនមានការផ្លាស់ប្តូរទេ លោកផ្លាស់ប្តូរតែទីកន្លែងធ្វើការទេ។ ខ្ញុំយល់ហើយឥឡូវនេះ។ អ៊ីចឹងខ្ញុំចង់ត្រឡប់មកនិយាយអំពីចំណុចមួយដែលលោកបានឆ្លើយជូនមេធាវី គង់ សំអុន កាលពីម្សិលមិញ។ លោកថាពេលដែលលោកធ្វើជាគ្រូពេទ្យលោកមិនបានចូលរួមប្រជុំកង ពលទេ ក៏ប៉ុន្តែលោកទទួលព័ត៌មានពីប្រធានអង្គភាពរបស់លោក។ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ត្រឹមត្រូវៗ។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅនិយាយអំពីប្រភេទព័ត៌មានផ្សេងៗដែលប្រធានអង្គភាពរបស់លោក ផ្តល់ជូនលោក។ តើប្រធានអង្គភាពរបស់លោកហ្នឹងជាអ្នកប្រាប់លោកថា លោកត្រូវបោះទីតាំងមន្ទីរ ពេទ្យចល័តរបស់លោកនៅកន្លែងណាៗ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

[០៩:១៣:៣០]

**ស៖** នៅពេលដែលប្រធានអង្គភាពរបស់លោកប្រាប់ថា ឲ្យបោះទីតាំងមន្ទីរពេទ្យនៅកន្លែងណា អ៊ីចឹង គាត់មានដឹងព័ត៌មានច្បាស់ថា តើនឹងមានការវាយប្រយុទ្ធគ្នានៅកន្លែងណាខ្លះទេ? គាត់មានប្រាប់លោកទេ?

**ឆ៖** អរគុណ។ ព្រោះកាលណាផែនការពីអង្គភាពគេលើកឡើង គេដឹងហើយផែនការប្រយុទ្ធរបស់គេ។ ប៉ុន្តែកិច្ចការងារពេទ្យ គាត់បានប្រាប់តាំងទីត្រូវបោះខាងណោះៗ យើងដឹងតែប៉ុណ្ណឹង ប៉ុនផែនការប្រយុទ្ធកន្លែងត្រង់ណាៗៗ ព្រោះខ្ញុំបាទអត់ដឹងទេ។ បាទ អរគុណ។

**ស៖** បើអ៊ីចឹងកន្លែងដែលប្រយុទ្ធគ្នានៅសមរភូមិហ្នឹងលោកមិនដឹងច្បាស់ទេ លោកមិនដឹងថាតើមានការវាយប្រយុទ្ធគ្នានៅកន្លែង<ណា>ទេ អ៊ីចឹងមែនទេ?

**ឆ៖** អរគុណ។ អត់ដឹង អរគុណ។ វាត្រឹមត្រូវប៉ុណ្ណឹង។

**ស៖** លោកបាននិយាយបីបួនដងថា លោកបានជួប សោ ភឹម ហើយលោកបានជជែកគ្នារឿងគ្រួសារជាមួយគាត់។ ដូច្នេះ ខ្ញុំចង់ដឹងថា ពេលដែលលោកធ្វើការនៅភូមិភាគបូព៌ា <តើលោកធ្លាប់> ដែលត្រឡប់មកសមរភូមិក្រោយទេ? លោកមានបានច្បាប់អនុញ្ញាតមកសមរភូមិក្រោយទេ ឬក៏ពេលដែលលោកនៅសមរភូមិ នៅភូមិភាគបូព៌ាហ្នឹង គឺលោកប្រចាំការនៅទីហ្នឹងរហូតតែម្តង ឬលោកមិនដែលមកសមរភូមិក្រោយទេ?

**ឆ៖** អរគុណ។ ចំពោះខ្ញុំផ្ទាល់ហ្នឹង គឺខ្ញុំនៅប្រចាំការសមរភូមិខាងមុខរហូត។ ប៉ុន្តែពេលវេលាខ្លះដែលសភាពការណ៍នៅសមរភូមិធូរស្រាលហ្នឹង ខ្ញុំក៏អាចឆ្លៀតមកកន្លែងភូមិភាគមួយភ្លែតៗ ពីព្រោះអីគ្រួសារខ្ញុំនៅខាងនុ៎ង។ នៅខាងផលិតកម្ម កសិកម្មហ្នឹង គឺនៅនុ៎ង។ អ៊ីចឹងមកជួបគ្រួសារទៅ មកសម្រាកមួយយប់អ៊ីចឹងទៅក៏វិលទៅមុខវិញ។ អរគុណ។

**ស៖** បើអ៊ីចឹង ខ្ញុំចង់សួរបន្ថែមទៀតថា លោកមកសមរភូមិក្រោយហ្នឹង ញឹកញាប់ប៉ុនណាដែរ?

**ឆ៖** អរគុណ ចំពោះរូបខ្ញុំមិនសូវបានមកញឹកញាប់ទេ ព្រោះអីនៅជាប់នឹងសមរភូមិខាងមុខទាល់តែសភាពការណ៍នៅខាងមុខវាធូរស្រាល បានអាចមកមួយភ្លែតបាន។ ជួនណាពីរខែអីមិនទាន់បានបីខែមិនទាន់បានមកម្តងទេ។ បាទ អរគុណ។

[០៩:១៦:៤៨]

**ស៖** អ៊ីចឹង នៅពេលដែលប្រធានអង្គភាពរបស់លោក ផ្តល់ព័ត៌មានជូនលោកហ្នឹង តើគាត់មាន

ដែលប្រាប់ពីទីតាំងអង្គភាពផ្សេងទៀតទេ ដូចជា ១៥៤, ១៥៥អី អ៊ីចឹងលោកដឹងទេ? ប្រធានអង្គភាព លោកដែលប្រាប់ពីទីតាំងរបស់វរៈ១៥៤, ១៥៥ ទេ?

**ឆ៖** អរគុណ។ ព្រោះនៅអង្គភាពគេចែកដាច់ពីគ្នា គឺ ងៗណា គឹគេដឹង ងនុ៎ង។ វៀរលែងតែ ប្រធានវរសេនាធំដែលគេប្រជុំនៅកន្លែងកងពល អាហ្នឹងគេផ្សព្វផ្សាយដឹង។ តែនៅតាមអង្គភាពវរ សេនាធំមួយៗ គេនិយាយតែពីវរសេនាធំមួយៗទេ។ អត់មានប៉ះពាល់ដល់វរសេនាធំផ្សេងៗទេ។ បាទ អរគុណ។

**ស៖** ទោះបីជាមិនបានពិភាក្សាពីរឿងវរសេនាធំផ្សេងទៀតក៏ដោយនោះ ពេលដែលលោកទៅ សមរភូមិក្រោយពីរបីខែម្ដងនុ៎ង លោកមានដែលស្ដាប់ឮព័ត៌មានគេនិយាយ <ថាតើ>កងវរសេនាធំ ផ្សេងៗទៀត<ត្រូវបានគេបញ្ជូនឱ្យទៅឈរជើងនៅទីណាដែរ ឬទេ>? ឧទាហរណ៍ដូចជា លោកមាន បានឮគេនិយាយអំពីការវាយប្រយុទ្ធគ្នា<ពិសេសណាមួយ ដែលគេបញ្ជូនទៅសមរភូមិក្រោយដែរឬទេ? > ឬក៏មានការពិភាក្សាអ៊ីចឹង ជាមួយនឹងកងទ័ពផ្សេងទៀតហ្នឹង ធ្លាប់មានអ៊ីចឹងទេ?

[០៩:១៨:២៣]

**ឆ៖** អរគុណ។ ចំពោះខ្ញុំ ដែលខ្ញុំមកសមរភូមិគ្មានគោលបំណងអីទៅស្ដាប់សភាពការណ៍ នយោបាយ គេនិយាយថា អ៊ីចេះ អ៊ីចុះ អត់មានទេ។ គឺមកហ្នឹង គោលបំណងគឺថាមកជួបប្រពន្ធកូន ហ្នឹងទេ មកចង់ដឹងសុខទុក្ខប្រពន្ធកូនប៉ុណ្ណឹងទេ។ ឯអាកិច្ចការងារអីផ្សេងៗ យើងអត់ដឹងទេ បាទរឿង ហ្នឹង។ អ៊ីចឹង គឺមកសម្រាកតែ១ថ្ងៃ មកអីទៅ យើងវិលត្រឡប់ទៅសមរភូមិមុខវិញ ទៅទទួលកិច្ចការ ការងាររបស់យើងវិញ។ តែក្រៅពីហ្នឹង ខ្ញុំអត់ដឹងទេ។ អរគុណ។

**ស៖** ដើម្បីឱ្យយល់ច្បាស់ មានន័យថាលោកមិនដែលប្រើប្រាស់ម៉ាស៊ីនទូរលេខទេ ហើយលោក ក៏មិនដែលទទួលបានទូរលេខមួយណាមកពីកងពល ដែលផ្ញើជូនអង្គភាពលោកទេ មែនទេ?

**ឆ៖** អរគុណ គឺត្រឹមត្រូវ។

**ស៖** លោកបានឆ្លើយថា លោកគឺជាប្រធានមន្ទីរពេទ្យចល័ត ហើយលោកចល័តរហូតទៅតាម តម្រូវការ។ ដូច្នេះ ខ្ញុំចង់ដឹងថាតើមន្ទីរពេទ្យចល័តហ្នឹង គឺថាជាកន្លែងមួយដែល<មិន>ព្យាបាលអ្នក របួសធ្ងន់<ទេ? ខ្ញុំយល់ពីអ្វីដែលលោកបាននិយាយ គឺថា លោកបញ្ជូនអ្នករបួសធ្ងន់ទៅមន្ទីរពេទ្យផ្សេង មួយទៀត។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវដែរឬទេ>?

[០៩:២០:១២]

**ឆ៖** អរគុណ។ ចំពោះមន្ទីរពេទ្យខ្ញុំ គេចែកជាពីរ ដែលស្នាក់ការខាងក្រោយចាំព្យាបាលផ្សេង ឯខ្ញុំទៅខាងមុខនោះ មិនមែនកន្លែងព្យាបាលទេ ទៅសម្រាប់សង្គ្រោះអ្នកដែលរបួសស្នាម ដែលមានដូចថារបួសធ្ងន់យ៉ាងម៉េច ពេលហ្នឹងយើងទៅសង្គ្រោះ ហើយបញ្ជូនមកក្រោយ។ មកក្រោយហ្នឹង គឺមកពេទ្យនៅកន្លែងកងពល បញ្ជូនបន្តបន្ទាប់ទៀត ហើយខ្ញុំគ្រាន់តែជួយសង្គ្រោះនៅលើសមរភូមិទេ។ ត្រូវរបួស ថាឥឡូវវាប៉ះពាល់ធ្ងន់ធ្ងរមែនទែន យើងជួយពេលនុ៎ង។ បាទអរគុណ។

**ស៖** អ៊ីចឹងលោកចាំពីទីតាំងដំបូងបំផុត ដែលលោកបានបោះទីតាំងពេទ្យចល័តរបស់លោកទេ? ខ្ញុំដឹងថាពេលនុ៎ង ប្រហែលជាបោះជាតង់ជាអីហើយ អ៊ីចឹងលោកចាំទេថា ដំបូងបំផុតហ្នឹង ដែលលោកទៅសមរភូមិ ហើយលោកបោះទីតាំងមន្ទីរពេទ្យលោកហ្នឹងនៅកន្លែងណាដែរ ក្នុងវរៈ១៥៦របស់លោកហ្នឹង?

**ឆ៖** អរគុណ។ អ៊ីចឹងសូមបញ្ជាក់បន្តិច នៅឆ្នាំណា? សួរខ្ញុំនៅឆ្នាំណាបាទ? អរគុណ។

**ស៖** អ៊ីចឹងខ្ញុំសួរអ៊ីចេះថា នៅឆ្នាំ១៩៧៦ លោកចាំថាអង្គភាពពេទ្យរបស់លោកហ្នឹងត្រូវបានចាត់តាំងទៅទីតាំងកន្លែងណា ដំបូងគេបំផុតហ្នឹងនៅសមរភូមិឆ្នាំ៧៦ហ្នឹង?

[០៩:២២:០២]

**ឆ៖** អរគុណ។ បើនិយាយពីឆ្នាំ៧៦ហ្នឹងគឺ យើងអត់ទៅទាន់ចុះសមរភូមិទេ។ ទីតាំងមន្ទីរពេទ្យហ្នឹង គឺនៅកន្លែងស្រុកពញាក្រែកហ្នឹង កន្លែងមន្ទីរស្រុកហ្នឹង បាទ ហ្នឹងទីតាំងរបស់មន្ទីរពេទ្យនៅហ្នឹង។ ហើយមកខាងម៉ែសាក់ហ្នឹង គឺមន្ទីរពេទ្យកងពល គឺនៅជិតគ្នាទេ មិនឆ្ងាយគ្នាប៉ុន្មានទេ នេះ៧៦។ ហើយដល់៧៧ អាហ្នឹងគិតផ្សេងទៀត។ បាទ អរគុណ។

**ស៖** អ៊ីចឹងសួរបន្តទៀតឆ្នាំ៧៦ ហ្នឹង ពេលដែលលោក គេចាត់តាំងលោកទៅពេទ្យនុ៎ង លោកដឹងថាមានអ្នករបួសទេ ក្រោយពីមានការប្រយុទ្ធគ្នាជាមួយនឹងវៀតណាមហ្នឹង នៅក្នុងមន្ទីរពេទ្យទាំងពីរ ដែលលោកនិយាយអម្បាញ់មិញហ្នឹង ថានៅម៉ែសាក់ ហើយនៅពញាក្រែកហ្នឹង?

**ឆ៖** អរគុណ។ បើនិយាយពីឆ្នាំ៧៦ គឺយើងមិនទាន់ចាប់ផ្តើមប្រយុទ្ធទេ។ យើងចាប់ផ្តើមរៀបចំអង្គភាពកងពលហ្នឹង។ ចូល៧៧ៗបានយើងចាប់ផ្តើមប្រយុទ្ធ។ កាលណាប្រយុទ្ធហ្នឹង ស្នាក់ការខ្ញុំមានពីរ។ ទី១ ស្នាក់ការដែលនៅត្រង់ស្រុកពញាក្រែកហ្នឹង ជាស្នាក់ការមួយសម្រាប់ទទួលព្យាបាលនិងរបួសស្រាលៗ។ ឯខ្ញុំនៅឯមុខទេ នៅជិតសមរភូមិ នៅខ្សែត្រៀម ត្រូវទៅជួយសង្គ្រោះបណ្តោះអាសន្ន ពេលដែលប្រយុទ្ធលើសមរភូមិ គឺខ្ញុំនៅខាងមុខ ខាងក្រោយគ្រាន់តែជាមន្ទីរពេទ្យសម្រាប់ជួយ

ព្យាបាលប៉ុណ្ណឹងទេ។ បាទ អរគុណ។

[០៩:២៣:៤៩]

**ស៖** តាមរយៈចម្លើយរបស់លោក ខ្ញុំយល់ថា លោកត្រូវបានគេចាត់តាំងឲ្យធ្វើការសមរភូមិហ្នឹង ចុងឆ្នាំ៧៧ មែនទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ដូច្នេះមុនឆ្នាំ មុនចុងឆ្នាំ៧៧ ហ្នឹងលោកមានធ្លាប់ដឹងថា មានទាហានដែលរងរបួស ហើយត្រូវបានគេបញ្ជូនមកមន្ទីរពេទ្យនៅពញាក្រែក និងនៅម៉ៃសាក់ហ្នឹងទេ?

**ឆ៖** អរគុណ។ និយាយពីមុនឆ្នាំ៧៧ហ្នឹង យើងអត់មានរបួសទេ បាទអត់មាន ព្រោះវៃបែកភ្នំពេញហើយ គេបញ្ជូនអង្គភាពខ្ញុំចេញពីខេត្តស្វាយរៀងមក មករៀបចំកងពលលេខ៤ នៅៗផ្លូវជាតិលេខ៧ហ្នឹង។ អ៊ីចឹងមិនទាន់មានរបួសស្នាមទេ ពេលនុ៎ង មានតែជីកប្រឡាយ ជីកទំនប់ លើកប្រព័ន្ធភ្លឺស្រែប៉ុណ្ណឹងទេ។ បាទ អរគុណ។

**ស៖** ប្រហែលជាខ្ញុំសួរមិនច្បាស់។ ខ្ញុំយល់ថា លោកថាពេលចាប់ផ្តើមវាយប្រយុទ្ធគ្នា គឺនៅឆ្នាំ៧៧ ហើយគេបញ្ជូនលោកទៅសមរភូមិហ្នឹងគឺនៅចុងឆ្នាំ៧៧។ អ៊ីចឹងខ្ញុំចង់ដឹងថានៅ <ដើមឆ្នាំ>៧៧ <គឺ>នៅក្នុងឆ្នាំ៧៧ដដែលហ្នឹង <គឺនៅ>ពេលដែលមុនគេពេលដែលគេបញ្ជូនលោកទៅសមរភូមិហ្នឹង <តើមានការប្រយុទ្ធគ្នា និង>មានអ្នករបួស<នៅក្នុងឆ្នាំ១៩៧៧ ដែរឬទេ>?

[០៩:២៥:៣៨]

**ឆ៖** អរគុណ។ នៅសមរភូមិតែងតែមានស្លាប់មានរបួស កាលណាស្លាប់របួសហ្នឹងខ្ញុំក៏មិនអាចដឹងច្បាស់ដែរ ព្រោះខ្ញុំសម្រាប់សង្គ្រោះនៅសមរភូមិជំងឺធ្ងន់ស្រាលក៏ដោយ កាលណាយើងសង្គ្រោះរៀបចំហើយស្រួលបួល យើងចាប់បញ្ជូនមកក្រោយហើយ មកមន្ទីរពេទ្យក្រោយៗហើយ។ អ៊ីចឹងខ្ញុំមិនអាចដឹងថា អូ៎! ធ្ងន់ប៉ុន្មានអីប៉ុន្មានយើងអត់ដឹងទេ ស្លាប់ប៉ុន្មានក៏យើងអត់ដឹងដែរបាទ។ បាទ ហ្នឹងដឹងតែប៉ុណ្ណឹងទេ។ អរគុណ។

**ស៖** ខ្ញុំចង់ពិនិត្យមើលទីតាំងមួយចំនួនជាមួយលោក នៅក្នុងឯកសារដែលយើងមាននៅក្នុងសំណុំរឿង។ អ៊ីចឹងខ្ញុំចង់ដឹងថាលោកធ្លាប់ឮកន្លែងហ្នឹងដែរឬក៏អត់? ហើយលោកធ្លាប់ដឹងថាមានការប្រទូសរ៉ាយគ្នានៅទីតាំងហ្នឹងទាំងអស់ឬក៏អត់? ខ្ញុំសំដៅទៅលើភូមិភាគបូព៌ា។ ឯកសារដំបូងគឺចុះខែមេសា ឆ្នាំ៧៧ គឺឯកសារ E3/852, ERN ជាភាសាបារាំង 00386227, ERN ជាភាសាអង់គ្លេស

00183715 និង ERN ជាភាសាខ្មែរ 00021519។ ខ្ញុំសូមឲ្យអ្នកបកប្រែជាភាសាខ្មែរតាមខ្ញុំឲ្យទាន់នៅទីកន្លែងដែលខ្ញុំនឹងរៀបរាប់ជូន ពីព្រោះថាខ្ញុំប្រហែលជាអានឈ្មោះជាខ្មែរហ្នឹងមិនត្រូវទេ។ នៅក្នុងឯកសារចុះខែមេសា ឆ្នាំ១៩៧៧នេះ មានការលើកឡើងអំពីការប្រឈមមុខដាក់គ្នា នៅតាមព្រំដែនស្រុកស្វាយរៀងក្នុងខែមេសា ឆ្នាំ៧៧។ ក្នុងនេះមានការនិយាយអំពីការបះទង្គិចគ្នា អ៊ីចឹងខ្ញុំនឹងអាន គឺថ្ងៃទី១៨ មេសា ៧៧ គេបញ្ជាក់ថា “បន្ទាប់មក គឺវាបាញ់រះនឹងផ្លោងអឹម៧៩ ជាច្រើនគ្រាប់លើកងទ័ពការពារព្រំដែនយើង បងប្អូនយើងបាញ់តវិញការពារខ្លួនអស់រយៈពេល១០នាទី ទើបពួកវាដកថយចូលទៅដីវាវិញ”។ នៅក្នុងទូរលេខនេះគេបានរាយការណ៍ពីហេតុការណ៍ទី២ គឺហេតុការណ៍កើតនៅថ្ងៃទី២១ មេសា ឆ្នាំ៧៧ “លើកទី២ នៅថ្ងៃទី២១ មេសា ឆ្នាំ៧៧ វេលាម៉ោងប្រាំល្ងាច មានកងទ័ពយួន២០នាក់ កាន់អាវុធគ្រប់ដៃចូលមកឈ្លានពានក្នុងដៃយើងត្រង់ខាងជើងដើមថ្កូវ ក្នុងភូមិបារាំង ឃុំប្រសាក់ ឃ្លាតពីព្រំដែន ២០០ម៉ែត្រ”។ សូមបញ្ចប់ការដកស្រង់។ ដូច្នេះ លោកស្គាល់ទីតាំងដែលមានឈ្មោះថា ដើមថ្កូវ ភូមិបារាំង <>ឃុំប្រសាក់។ លោកស្គាល់កន្លែងហ្នឹងទេ? ខ្ញុំគិតថាអ្នកបកប្រែជាភាសាខ្មែរប្រាកដជាអានឈ្មោះកន្លែងហ្នឹងត្រូវហើយ?

[០៩:២៩:១០]

**ឆ៖** អរគុណ។ បើនិយាយពីឆ្នាំចុង៧៧ នៅមូលដ្ឋានខេត្តស្វាយរៀងគឺខ្ញុំអត់ដឹងទេ ព្រោះខ្ញុំចេញផុតហើយ ចេញផុតពីខេត្តស្វាយរៀងហើយ មកនៅកងពលហើយ។ អ៊ីចឹងសភាពការណ៍កើតឡើងនៅខេត្តស្វាយរៀងខ្ញុំអត់បានទេ។ បាទ អរគុណ។

**ស៖** ដើម្បីឲ្យយល់ច្បាស់ ពេលហេតុការណ៍ហ្នឹងគឺកើតឡើងនៅខែមេសា ឆ្នាំ១៩៧៧ <គឺមិនមែនជាចុងឆ្នាំ១៩៧៧ទេ។> គឺសារទូរលេខហ្នឹងចុះខែមេសា ឆ្នាំ៧៧ ។

**ប្រធានអង្គជំនុំ៖**

ចង់សួរគាត់ថាម៉េចទៅ? គាត់ឆ្លើយហើយ គាត់ ៧៧ គាត់ទៅនៅទ័ពភូមិភាគ នៅកងពលលេខ ៤ ដែលឈរជើងនៅផ្លូវជាតិលេខ ៧។ ផ្លូវ៧ គឺផ្លូវជាតិពីខេត្តកំពង់ចាមទៅក្រចេះ។ បើខេត្តធៀបនឹងស្វាយរៀង ឆ្ងាយគ្នាណាស់រាប់រយគីឡូឯណោះ។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ជាកំហុសរបស់ខ្ញុំ។ <ប្រហែលជា ខ្ញុំមិនបានមើលផែនទីឲ្យបានត្រឹមត្រូវ។>

[០៩:៣០:៤៦]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី ខ្ញុំមានសំណួរផ្សេងទៀត គឺឯកសារ E3/889, ERN ជាភាសាបារាំង 00386262, ERN ជាភាសាអង់គ្លេស 00183616, ERNជាភាសាខ្មែរ 00020877 ឯកសារនេះគឺចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៧៧ ចុះហត្ថលេខាដោយឈ្មោះ ឆុន។ ទូរលេខនេះ លើកឡើងអំពីហេតុការណ៍នៅស្រុកចន្ទ្រា ខាងសថូក។ អ្នកបកប្រែ គឺខ្ញុំនិយាយអំពីកថាខ័ណ្ឌទី២ នៃទូរលេខនេះ។ លោកសាក្សី លោកស្គាល់ស្រុកចន្ទ្រា នៅ<ជិត>សថូក លោកស្គាល់ទេ?

**2-TCW-1065៖**

**ឆ៖** អរគុណ។ គ្រាន់តែឈ្មោះស្រុកចន្ទ្រា ខ្ញុំបាទស្គាល់។ ប៉ុន្តែសភាពការណ៍កើតឡើងនៅស្រុកចន្ទ្រាខ្ញុំអត់បានស្គាល់ទេបាទ អត់ដឹងទេ ប៉ុនគ្រាន់តែឈ្មោះស្រុកខ្ញុំស្គាល់ ស្រុកចន្ទ្រា ខេត្តស្វាយរៀង គ្រាន់តែស្គាល់ប៉ុណ្ណឹង ព្រោះខ្ញុំនៅក្នុងខេត្តស្វាយរៀងដែរ។ បាទ គ្រាន់តែប៉ុណ្ណឹងទេ។

**ស៖** លោក<មិន>ស្គាល់ស្រុកចន្ទ្រា <លោកមិនដឹងរឿងអ្វីកើតឡើងនៅទីនោះទេ។> អ៊ីចឹងខ្ញុំចង់ដឹងថា ក្នុងពេលលោកបំពេញការងារនៅក្នុងអង្គភាព ចល័តរបស់លោកហ្នឹងនៅឆ្នាំ៧៧ ឬឆ្នាំ៧៨ ហ្នឹង លោកមានធ្លាប់បោះទីតាំងនៅ<កន្លែង>ហ្នឹងទេ?

**ឆ៖** អរគុណ។ បើសំណួរហ្នឹងខ្ញុំពិបាកឆ្លើយដែរ។ ខ្ញុំ ៧៦ ខ្ញុំចេញផុតពីខេត្តស្វាយរៀងបាត់ទៅហើយ មកនៅផ្លូវជាតិលេខ៧រួចទៅហើយ។ ហើយនៅស្រុកចន្ទ្រា ខ្ញុំដឹង ខ្ញុំអត់ដឹងទេ ព្រោះអង្គភាពហ្នឹងគេដកតាំងពី៧៦ មកនៅភូមិភាគរួចហើយហ្នឹង ហើយបើខ្ញុំម៉េចដឹង៧៧នោះ។ បាទ អរគុណ។

[០៩:៣៣:៤៥]

**ស៖** លោកចៅក្រម ឡាវ៉ែន៍ បានសួរលោក <ហើយ>ក្រោយ<មក> សហព្រះរាជអាជ្ញា <បានសួរ>អំពីហេតុការណ៍មួយនៅបន្ទាយ២៧ ជាបន្ទាយរបស់វៀតណាម។ ហើយលោកបានឆ្លើយថា លោកចាំអំពីហេតុការណ៍ហ្នឹង ទោះបីជាលោកមិនបានចូលរួមក្នុងការវាយប្រយុទ្ធក៏ដោយ។ ដូច្នេះ ខ្ញុំចង់អានឲ្យលោកស្តាប់នូវសម្រង់ មួយនៃទូរលេខដែលចៅក្រម ឡាវ៉ែន៍ គាត់យកមកប្រើគឺឯកសារ E3/891, ERN ជាភាសាបារាំង 00386265, ERN ជាភាសា<អង់គ្លេស> 00183617, ជាភាសាខ្មែរ 00020878។ ទូរលេខនេះនិយាយអំពីការវាយប្រយុទ្ធនៅបន្ទាយ២៧។ គឺជាទូរលេខរបស់ ឆុន ឬក៏ សោ ភឹម នៅចុះថ្ងៃទី២៩ តុលា ៧៧។ គាត់បាននិយាយថា៖ "យើងខ្ញុំសូមជម្រាបជាបឋមនូវសមរភូមិផ្លូវលេខ២២ ដូចខាងក្រោមនេះ មុខព្រួញផ្លូវលេខ២២ យើងបានវ៉ៃសម្រុកវាដាច់ វាជាប់តាំងពីថ្ងៃទី

២៧, ២៨ តុលា។ យប់មិញយើងបុកខ្លាំង ធ្វើឲ្យខ្មាំងបាក់ យើងដេញវាហួសត្រពាំងផ្លុង បច្ចុប្បន្នយើងធ្វើម្ចាស់ការទាំងស្រុងតាមខ្សែការពារចាស់របស់យើងវិញហើយ។ យើងកំពុងដេញតាមខ្មាំង វ៉ៃសម្រុកចូលបន្ទាយលេខ២៧ ទៀត"។ សូមបញ្ចប់ការដកស្រង់។ ដូច្នេះសំណួរទី១ របស់ខ្ញុំពាក់ព័ន្ធនឹងចំណុចនេះលោកបានឆ្លើយថា លោកបាននឹកអំពីការវាយប្រហារនៅបន្ទាយលេខ២៧--

[០៩:៣៥:៥៣]

**លោក នីកូឡាស គូមជែន៖**

ប្រហែលជាដោយសារការបកប្រែ ប៉ុន្តែខ្ញុំស្តាប់មេធាវីនិយាយថា ពីឈុន ផ្ញើទៅ សោ ភឹម <ហើយវា>គឺថា<សារទូរលេខផ្ញើជូនមន្ទីរ៨៧០> ចម្លងជូនទៅអ្នកដទៃទៀតមាន អ៊ំនួន ជាដើម។ល។

**កញ្ញា អង់តា ហ្គិសសេ៖**

ខ្ញុំគិតថាប្រាកដជាមានកំហុសបកប្រែជាភាសាអង់គ្លេសហើយ។ ខ្ញុំនិយាយថា ឈុន ឬ សោ ភឹម មានន័យថាជាមនុស្សតែមួយទេ មិនមែន ឈុន ផ្ញើជូនទៅ សោ ភឹម ទេ។

**សួរដោយកញ្ញា អង់តា ហ្គិសសេ៖**

**ស៖** ដូច្នេះសំណួរខ្ញុំនៅតែដដែលលោកសាក្សី។ លោកចាំអំពីហេតុការណ៍វ៉ៃសម្រុកចូលបន្ទាយ២៧។ អ៊ីចឹងលោកមានចាំទេថា មុនពេលវាយចូលបន្ទាយ២៧ ហ្នឹងមានការវាយប្រហារពីខាងសំណាក់ទាហានវៀតណាមចូលមកត្រពាំងផ្លុងទេ? ហើយលោកស្គាល់ទីតាំងឈ្មោះត្រពាំងផ្លុងហ្នឹងទេ?

[០៩:៣៦:៥៦]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំយល់ហើយថា សារទូរលេខនេះ គឺនិយាយអំពីការវាយប្រហាររបស់វៀតណាមមកត្រពាំងផ្លុង គឺសារទូរលេខនិយាយអំពីការវាយប្រហាររបស់កងទ័ពរបស់ ឈុន នៅត្រពាំងផ្លុងដើម្បីរុញខ្មាំងចេញទៅៗវិញ។

**សួរដោយកញ្ញា អង់តា ហ្គិសសេ៖**

**ស៖** បើយើងដេញខ្មាំងចេញ មានន័យថាខ្មាំងចូលមកដីយើងហើយ វាៗអត់មានអីខុសពីហ្នឹងទេ។ អ៊ីចឹងឥឡូវខ្ញុំសួរលោកសាក្សីថា លោកស្គាល់កន្លែងមួយឈ្មោះថា "ត្រពាំងផ្លុង" ហ្នឹងទេ?

**2-TCW-1065៖**

**ឆ៖** អរគុណ។ បើនិយាយរឿងនេះ ព្រោះកន្លងមកខ្ញុំក៏បាននិយាយហើយដែរ វាចូលរឿង

01377251



ដដែលៗទៀត។ សមរភូមិផ្លូវជាតិលេខ២២ ហើយបន្ទាយ២៧ នេះ បើនិយាយដំបូងឡើងគឺកងទ័ពខ្មែរក្រហមហ្នឹង គឺភូមិភាគបូព៌ាហ្នឹងចាប់--

[០៩:៣៨:០២]

**ប្រធានអង្គជំនុំ៖**

ឈប់! ឈប់! ចាំស្តាប់សំណួរសិន! បើលោកស្តាប់សំណួរមិនបាន លោកឆ្លើយថារឿងដដែល។ រឿងដដែល បានន័យថារឿងសម្រាប់ភាគីផ្សេងទៀតសួរ រឿងដដែលហ្នឹងចៅក្រមសួរ។ មានចំណុចដែលវាមិនច្បាស់លាស់សម្រាប់ភាគីការពារក្តីគេត្រូវការសួរដែរ ព្រោះអ្នកភាគីពាក់ព័ន្ធទាំងអស់ហ្នឹងមានផលប្រយោជន៍ខុសៗគ្នា។ អ៊ីចឹងហើយបានមានចំណុចឯកសារដដែល គេអាចឲ្យយកចំណុចផ្សេងទៀតដែលមានប្រយោជន៍នៅក្នុងការ -- ជាយុត្តិសាស្ត្រការពារក្តីយកមកសួរដេញដោលលោកដើម្បីបញ្ជាក់ផ្ទុកផ្តងផ្ទៀងផ្ទាត់ជាមួយនឹងចម្លើយមុន។ លោកស្តាប់សំណួរគេសិន ហើយសឹមឆ្លើយត្រង់ចំណុចដែលៗគេសួរបានហើយ តបនឹងភាពចាំបាច់ទៅនឹងសំណួរបានហើយ បើលោកស្តាប់សំណួរមិនយល់លោកឆ្លើយទៅវាអត់បានប្រយោជន៍ ហើយវានាំតែប្រើពេលវេលាវែង ហើយកាន់តែស្មុគស្មាញឡើង។

សូមតាំងសំណួរជាមួយគាត់ ចំពោះគាត់ម្តង សាជាថ្មីម្តងទៀត។ គេចង់ដឹងថា តើលោកស្គាល់ភូមិសាស្ត្រត្រពាំងផ្លុងដែរឬទេ? នេះសំណួរ។

[០៩:៣៩:១២]

**2-TCW-1065៖**

**ឆ៖** អរគុណ។ ចំពោះខ្ញុំគឺស្គាល់ភូមិសាស្ត្រត្រពាំងផ្លុង។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ត្រពាំងផ្លុងនេះស្ថិតនៅក្នុងទឹកដីខ្មែរមែនទេ?

**ឆ៖** អរគុណ។ ត្រពាំងផ្លុងគឺនៅទឹកដីខ្មែរ។

**ស៖** លោកចាំទេថា មុនពេលមានហេតុការណ៍ វាយលុកចូលបន្ទាយលេខ២៧ហ្នឹង គឺមានការលុកលុយចូលពីសំណាក់កងទ័ពវៀតណាមនៅក្នុងត្រពាំងផ្លុងនេះ ដូចមានបញ្ជាក់នៅក្នុងឯកសារនេះ។ លោកមាននឹកឃើញទេ?

**ឆ៖** អរគុណ។ និយាយពីមុនវៃចូលវៀតណាមនេះ កន្លងមកវាអត់មានចូលត្រពាំងផ្លុងទេ

គ្រាន់តែមកតាមខ្សែព្រំដែន បាទ គ្រាន់មកតាមព្រំដែនទេ។ បាទ អរគុណ។

**ស៖** ខ្ញុំសូមអានឲ្យលោកស្តាប់ម្តងទៀត "យប់មិញយើងបុកខ្លាំង ធ្វើឲ្យខ្មាំងបាក់ យើងដេញវាហួសត្រពាំងផ្លុង" សូមបញ្ចប់ការដកស្រង់។ ដូច្នេះ លោកធ្លាប់ឮថា សោ ភឹម នេះចេញបញ្ជាឲ្យដេញវាយកងទ័ពវៀតណាមហ្នឹង ហួសត្រពាំងផ្លុងទៅទៀត។ ខ្ញុំដឹងថា លោកមិនចូលរួមប្រជុំថ្នាក់កងពលទេ អ៊ីចឹង ខ្ញុំគ្រាន់តែសួរលោកថា លោកធ្លាប់ឮគេនិយាយអំពីហេតុការណ៍ ដូចដែលបានរាយការណ៍នៅក្នុងទូរលេខហ្នឹងទេ?

[០៩:៤១:០៦]

**ឆ៖** អរគុណ។ ក្រោយពីបានប្រយុទ្ធគ្នារួចហើយ វៀតណាមវ៉ៃផ្តាច់១៥៥ ហើយមកនៅខាងក្រោយខ្នងខ្ញុំ។ ពេលនុ៎ង វៀតណាមវ៉ៃបុកផ្តាច់មករហូតដល់ត្រពាំងព្រីង មកដល់ក្តុលជ្រុំ ដល់អីទៀត បាទ បុកដាច់យើងតែម្តង។ អ៊ីចឹងបានយើងវ៉ៃរុញទៅវិញ ចុង៧៧ហ្នឹង វ៉ៃរុញទៅវិញ គ្រាន់តែវ៉ៃរុញទៅវិញហ្នឹង វ៉ៃគ្នាជាប់៣យប់ ៣ថ្ងៃ នៅក្បែរត្រពាំងផ្លុងហ្នឹង។ បាទ វ៉ៃ៣យប់ ៣ថ្ងៃ ពេលហ្នឹងហើយបានវៀតណាមដកថយទៅក្រោយវិញ។ បាទអរគុណ។

**ស៖** ខ្ញុំចង់ដកស្រង់នៅផ្នែកមួយទៀតនៃទូរលេខដែលលោកប្រធានបានអាន គឺឯកសារ E3/908, ERN ជាភាសាអង់គ្លេស 00183638, ERN ជាភាសាខ្មែរ 00020923, ERN ជាភាសាបារាំង 00386278។ នេះ គឺជាហេតុការណ៍មួយពាក់ព័ន្ធនឹងរោងចក្រនៅមេមត់ <លោកនិយាយថា> លោកចាំថា ភ្លូង <ទទួលខុសត្រូវរោងចក្រហ្នឹង>។ ដូច្នេះ ខ្ញុំចង់ឲ្យលោកពិនិត្យមើលនៅផ្នែកមួយនៃទូរលេខនេះ <ខ្ញុំសូមអានជូនលោក៖ "នៅព្រឹក> ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៧៧ <ពួក>វាចូល (គឺពួកវាហ្នឹង គឺសំដៅទៅលើវៀតណាមហ្នឹងហើយ) វាចូលមុខព្រួញពីខាងកើតរោងចក្រ ខ្មាំងរឹបយកអីវ៉ាន់ប្រជាជនជាច្រើន ចាប់បានប្រជាជន និងកងចល័តច្រូតស្រូវខាងនោះ។ <មានប្រជាជន>ជាង២០០នាក់ វាធ្វើបាបយ៉ាងខ្លោចផ្សាណាស់ វាសម្រាតឲ្យនៅខ្លួនទទេ ទាំងប្រុសទាំងស្រី ហើយនៅមុខវាកុំឲ្យយើងបាញ់"។ សូមបញ្ចប់ការដកស្រង់។

លោកបានឆ្លើយថាលោកស្គាល់ចម្ការកៅស៊ូនៅមេមត់ ដូច្នេះលោកនឹកឃើញថា មានហេតុ-ការណ៍មួយនៅព្រឹកថ្ងៃទី២៤ <ខែធ្នូ ឆ្នាំ១៩៧៧>នេះ នៅចម្ការកៅស៊ូមេមត់ហ្នឹង ដែលពេលនោះ គឺ <>ប្រជាជនហ្នឹង<ត្រូវបានកងទ័ពវៀតណាមហ្នឹងចាប់>មកធ្វើជាខែលដើម្បីឲ្យកុំខាងយើងហ្នឹងបាញ់ទៅពួកគេ?

[០៩:៤៤:០៥]

**ឆ៖** អរគុណ។ ចំពោះខ្ញុំផ្ទាល់វិញ ចម្ការកៅស៊ូមេមត់ ខ្ញុំស្គាល់ តែចំពោះមុខព្រួញនិងសភាពការណ៍នៅមេមត់ គឺអត់ស្គាល់ទេ ព្រោះមុខព្រួញខុសគ្នា ខាងនោះ១៥៤ ហើយខ្ញុំនៅ១៥៦ទេ។ អ៊ីចឹងទោះបីយ៉ាងម៉េចក៏យើងអត់ដឹងទេ ប៉ុន្តែចម្ការកៅស៊ូស្គាល់ មេមត់ហ្នឹង។ ប៉ុន្តែសភាពការណ៍កើតឡើងនៅនុ៎ង ខ្ញុំបាទអត់ដឹងទេ។ បាទ អរគុណ។

**ស៖** ខ្ញុំចង់ត្រឡប់មកសួរលោកអំពីឯកសារមួយទៀត ដែលលោកចៅក្រម ឡាវ៉ែន៍ យកមកសួរ គឺឯកសារ E3/10669.1, ERN ជាភាសាបារាំង 00611727 មានឃ្លាមួយទៀតផងដែរ នៅ<ត្រង់ទំព័រ>728, ជាភាសាខ្មែរគឺ 00020943, ERN ជាភាសាអង់គ្លេស 00183646។ នេះជាទូរលេខផ្ញើជូន បងប៉ ដោយឈ្មោះ ឆុន នៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៧៨។ <ហើយសារទូរលេខនេះផ្ញើជូនទៅតំបន់មួយចំនួន> ខ្ញុំសូមឲ្យអ្នកបកប្រែខ្មែរ ជួយខ្ញុំឲ្យអានឈ្មោះហ្នឹងត្រូវផង។ "ខ្ញុំសូមរាយការណ៍ពីសភាពការណ៍មានដូចតទៅ ១) មុខព្រួញកំពង់ក្ដី កំពង់ថ្កូវ។ ២) មុខព្រួញកំពង់រកា។ ៣) មុខព្រួញកំពង់រទេះ ទៅត្នោត"។ សូមបញ្ចប់ការដកស្រង់។ ជាដំបូង ខ្ញុំចង់សួរលោកថា លោកស្គាល់ទីតាំងទាំងអស់ហ្នឹងទេ? ហើយតើទីតាំងទាំងអស់ហ្នឹងគេមានបានចាត់តាំងអង្គភាពរបស់លោក១៥៦ ហ្នឹងឲ្យទៅកន្លែងទាំងអស់ហ្នឹងទេ? <តើលោកទទួលបានព័ត៌មានអ្វីខ្លះអំពីទីតាំងទាំងអស់ហ្នឹង?>

[០៩:៤៦:៣៤]

**ឆ៖** អរគុណ។ ចំពោះខ្ញុំ គឺខ្ញុំអត់ស្គាល់ទេ ទីតាំងទាំងអស់ហ្នឹង អត់ស្គាល់ទេ។

**ស៖** នៅក្នុង ERN បន្តទៅទៀត <គ្រប់ភាសាទាំងអស់ គឺ>ភាសាខ្មែរហ្នឹងគឺ 00020944 ទូរលេខនេះបានលើកឡើងអំពីទីតាំងមួយទៀត "នៅថ្ងៃទី២០ មករា យើងដណ្ដើមបានជីពាយ និងព្រែកស្ពា"។ លោកស្គាល់ទីតាំងទាំងពីរហ្នឹងទេ ហើយលោកមានដឹងថាមានហេតុការណ៍អ្វីកើតឡើងនៅទីតាំង ជីពាយ ហើយនិងព្រែកស្ពាហ្នឹងទេ នៅខែមករា ឆ្នាំ១៩៧៨ នោះ?

**ឆ៖** អរគុណ។ ចំពោះខ្ញុំអត់បានដឹងទេ ជីពាយ និងព្រែកស្ពា ហ្នឹងមិនដឹងនៅត្រង់ណាបាទអស់ស្គាល់ទេ។ បាទ អរគុណ។

**ស៖** នៅក្នុងទូរលេខដដែលនេះមានការបញ្ជាក់ថា នៅក្នុងតំបន់ នៅក្នុងមុខព្រួញនេះ ពួកខ្មាំងបានដាក់មីនគ្រប់ប្រភេទ ហើយយើងបានដក យើងបានដោះមីន <ដែលមានរូបរាងពុកមាត់បង្កង និង> ផ្លែឈើ <>ហើយបន្ទាប់មកទៀត គឺអានអត់ដាច់ទេ។ អ៊ីចឹងខ្ញុំដឹងថាលោកមិនស្គាល់កន្លែងហ្នឹងទេ ក៏

ប៉ុន្តែក្នុងឋានៈលោកជាគ្រូពេទ្យនេះ លោកធ្លាប់ព្យាបាលអ្នកណាដែលរងរបួស ដោយសារតែការជាន់មីន <ប្រភេទហ្នឹង>ទេ?

[០៩:៤៨:៣៥]

**ឆ៖** អរគុណ បើនិយាយមុខព្រួញខ្ញុំ អត់មានជាន់មីនទេ មានតែប្រយុទ្ធគ្នាតែម្តង។ អរគុណ។

**ស៖** សំណួរផ្សេងទៀត ទោះបីជាមិនមានទាហានរងរបួសដោយសារមីនក៏ដោយ តើលោកដឹងថាមានអង្គភាពជំនាញណាមួយ <នៅក្នុងកងពលរបស់លោកហ្នឹង> ដែលទទួលបន្ទុកក្នុងការដោះមីនទេ?

**ឆ៖** អរគុណ។ រឿងក្នុងភូមិភាគ ខ្ញុំអត់បានដឹងទេ ប៉ុនអង្គភាពខ្ញុំ វាគ្មានជំនាញទេ មីន គ្រាន់តែឃើញគេដោះតែម្តង។ អ្នកណាឃើញ អ្នកនុំងដោះ ប៉ុនថាឲ្យមានជំនាញ អត់មានទេ។ អរគុណ។

**ស៖** ដោយសារតែខ្ញុំមានពេលវេលាខ្លី អ៊ីចឹងខ្ញុំចូលទៅដល់ប្រធានបទចុងក្រោយ។ លោកបាននិយាយថា នៅថ្ងៃទី២៥ ឧសភា ឆ្នាំ១៩៧៨ លោកបានក្តាប់ដឹកនាំកងទ័ព៣០០នាក់ ហើយលោកបានផ្តាច់ខ្លួន ហើយលោកបានឆ្លើយថា ពួកវៀតណាមបានមកទាក់ទងលោកហ្នឹងចន្លោះខែតុលា <ឬ>វិច្ឆិកា ឆ្នាំ៧៨។ <>តាមរយៈចម្លើយរបស់លោកនេះ ខ្ញុំយល់ថា លោកទទួលបានលិខិតពីវៀតណាម ដើម្បីរៀបចំការណាត់ជួបគ្នា។ អ៊ីចឹងខ្ញុំចង់ដឹងថាតើពួកវៀតណាមដឹងថា លោកជាអ្នកណាហ្នឹង ដោយរបៀបណា ហើយគេមកទាក់ទងលោកហ្នឹងតាមរយៈអ្នកណា ហើយលិខិតដែលគេសុំជួបលោកអីហ្នឹងគេមកដល់ មកតាមរយៈអ្នកណាដែរ?

[០៩:៥០:៤០]

**ឆ៖** អរគុណ។ ឥឡូវខ្ញុំសូមជម្រាបជូនអ៊ីចេះ ព្រោះលិខិតនេះគ្មានមកតាមរយៈអ្នកណាទេ។ ពួកខ្ញុំបោះនៅកន្លែងណាតែងតែមានដាក់អីវ៉ាន់នៅកំប្រោងហ្នឹង មានផ្លែ មានបន្លែបង្ការដាក់ហ្នឹងបាទ។ អ៊ីចឹងតែយើងចេញទៅយើងទុកបន្លែនៅហ្នឹង នៅកន្លែងដែលយើងទៅបោះហ្នឹង ដល់ថ្ងៃក្រោយយើងត្រូវការបន្លែយើងមករកទៅស្រាប់តែឃើញសំបុត្រស្នាមហ្នឹង។ ហ្នឹងពីបញ្ហាការទាក់ទង។ ដល់ជួបហ្នឹងហើយថាយើងអត់មានកំណត់ថាយ៉ាងម៉េច ហើយវៀតណាមគេថាខ្ញុំម៉េចអត់ដឹងទេ ប៉ុន្តែមកជួបគ្នាក្នុងនាមថាខ្ញុំជាអ្នកតស៊ូ បាទ តស៊ូមកនៅក្នុងព្រៃ ផ្តាច់ៗខ្លួនចេញពីខ្មែរក្រហម។ អ៊ីចឹងគេចង់មកទាក់ទងយើង បាទ ទាក់ទងយើងប៉ុណ្ណឹង។ បាទ អរគុណ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

តើតាមរយៈអ្នកណាដែលមកទាក់ទងលោកនោះ? លោកបានឆ្លើយរួចហើយ បាទ សូមបញ្ជាក់ឱ្យគាត់អស់ចិត្តទៅ ព្រោះគាត់ប្រហែលជាសំណួរហ្នឹងលោកឆ្លើយច្រើនដងហើយ។ អ្នកណាដែលមកទាក់ទងលោក។

**2-TCW-1065៖**

អរគុណ។ ចំពោះវៀតណាមខ្ញុំភ្លេចហើយមិនដឹងឈ្មោះអី ប៉ុន្តែខ្ញុំនៅឈ្មោះនៅចាំតែពីរនាក់ទេ ខាងខ្មែរដែលនៅជាមួយវៀតណាមហ្នឹង ឈ្មោះ កុយ ប៉ៀន មួយ និង កៅ តឹក មួយ តែប៉ុណ្ណឹងទេ ស្គាល់តែពីរហ្នឹង។ តែវាយូរហើយភ្លេចហើយ វៀតណាមអីមិនដឹងពីណាៗខ្លះ។

[០៩:៥២:២២]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** សំណួរហ្នឹងសំណួរខ្ញុំហ្នឹងគឺខុសពីហ្នឹងបន្តិច។ ខ្ញុំចង់ដឹងថាអ៊ីចេះ ហេតុអីបានជាពួកវៀត-ណាមហ្នឹងគេដឹងថាលោកផ្តាច់ខ្លួន ហើយគេមកបង្ហាញខ្លួនមកជួបលោកហ្នឹង ក្នុងនាមពួកគេជាវៀតណាមហ្នឹងតែម្តង ឬក៏គេធ្វើតាមរបៀបណាផ្សេងខ្ញុំសួរសំណួរអ៊ីចឹង ដោយសារតែលោកឆ្លើយថាពេលដែលលោកផ្តាច់ខ្លួននៅខែ<ឧសភា> ឆ្នាំ៧៨ ហ្នឹងលោកវាយប្រយុទ្ធគ្នាជាមួយកងទ័ពខ្មែរក្រហមផងកងទ័ពវៀតណាមផង។ អ៊ីចឹងម៉េចក៏ខ្មាំងហ្នឹងហ៊ានមកទាក់ទងជាមួយលោកនោះ វៀតណាមហ្នឹងជាខ្មាំងគេមានពឹងពាក់ឱ្យអ្នកណាមកទាក់ទងលោកទេ បើថាបើខ្មាំងមកអ៊ីចឹងប្រហែលជាលោកវាយហើយ?

**2-TCW-1065៖**

**ឆ៖** អរគុណ។ ខ្ញុំសូមបញ្ជាក់បន្តិច ពេលអ្នកមកទាក់ទងខ្ញុំនោះ មានខ្មែរ មានវៀតណាមស៊ើបការណ៍របស់គេទេ។ ប៉ុន្តែនេះតាមខ្ញុំយល់គេនឹកឃើញថានៅខាងក្រោយ ព្រោះមានអ្នកតស៊ូនៅព្រៃហើយបាទ បានប្រយុទ្ធគ្នានៅខាងក្រោយហ្នឹង។ អ៊ីចឹងគេចង់មកជួបអ្នកតស៊ូនៅព្រៃហ្នឹង បាទដើម្បីយកកម្លាំង ហើយខ្ញុំក៏វ៉ៃទាំងអស់។ បាទ វៀតណាមវ៉ៃវៀតណាមបាទ ទ័ពខ្មែរក្រហមវ៉ៃខ្មែរក្រហម។ អ៊ីចឹងមិនដឹងជាអ្នកណាខុសអ្នកណាត្រូវទេ។ អ៊ីចឹងបានវៀតណាមគេឱ្យស៊ើបការណ៍គេមួយក្រុម គេចល័តមកខាងក្រោយខ្សែត្រៀមរបស់ខ្មែរក្រហមហ្នឹង មកទាក់ទងជួបខ្ញុំដែលអ្នកតស៊ូនៅព្រៃប៉ុណ្ណោះ។ បាទអរគុណ។

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:៥៩:០០]

**ប្រធានអង្គជំនុំ៖**

៥៥នាទីបានកន្លងផុតទៅ ឥឡូវចង់៥០, ៦០នាទីហើយលោកស្រីមេធាវី ដូចជារំលោភលើពេលវេលាដែលបានបែងចែកឲ្យហើយ ម្សិលមិញទាមទារតែ៤៥នាទីទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

អ៊ីចឹងជាការសោកស្តាយណាស់លោកប្រធាន ដែលខ្ញុំត្រូវតែបញ្ចប់ការសួរសំណួរត្រឹមហ្នឹង ព្រោះថាអំមិញហ្នឹងខ្ញុំចង់សួរសំណួរហ្នឹងក៏សំណួរចុងក្រោយដែរ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអរគុណលោកសាក្សី សវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅពេលនេះដល់ទីបញ្ចប់ហើយ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះវត្តមានរបស់លោកនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្តីសុខសេចក្តីចម្រើន ហើយអង្គជំនុំជម្រះក៏សូមអរគុណលោកស្រីសុក សុជាតា មេធាវីប្រឹក្សាសាក្សី លោកស្រីអាចសម្រាកបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះ វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ ហើយជាបន្តទៅទៀតនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-237 ពេលគាត់ចាកចេញទៅ សូមមន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ។ លោកអាចចាកចេញបានហើយ រួមទាំងមេធាវីប្រឹក្សាសាក្សី។

បាទ ហើយដោយសារការត្រៀមខ្លួនមិនទាន់ ដូច្នេះយើងសម្រាកតែម្តងទៅ វាសមស្របដល់ពេលសម្រាកហើយដែរ។ អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះ តទៅរហូតដល់ម៉ោងដប់ និងម្ភៃនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ៩:៥៨ នាទី ដល់ម៉ោង ១០:២១ នាទី)*

[១០:២១:៣៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ។ មន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១០:២៣:៥៦]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកឈ្មោះអី?

**លោក ស សារិន៖**

**ឆ៖** សូមគោរពលោកប្រធាន ខ្ញុំឈ្មោះ ស សារិន។

**ស៖** អរគុណលោក ស សារិន។ តើលោកចាំទេ លោកកើតនៅថ្ងៃខែឆ្នាំណា?

**ឆ៖** ខ្ញុំបាទកើតនៅថ្ងៃអង្គារ ទី០៧ ខែ៧ ឆ្នាំ១៩៥៧ បាទ។

**ស៖** បាទ អរគុណ។ មុននឹងឆ្លើយលោកចាំ រង់ចាំក្បាលមីក្រូហ្វូនឲ្យសញ្ញាភ្លើងក្រហម លោកមើលខាងក្រោមលើភ្លើងក្រហម សូមលោកឆ្លើយ -- លោកឆ្លើយ នោះទើបសំឡេងរបស់លោកហ្នឹងគឺស្រូបបញ្ចូលទៅប្រព័ន្ធចែកចាយសំឡេងសម្រាប់ភាគីទាំងអស់ រួមទាំង សំខាន់គឺ អ្នកបកប្រែភាសា។ ហើយលោកមានទីកន្លែងកំណើតនៅទីកន្លែងណាដែរ លោក សារិន?

[១០:២៥:០៥]

**ឆ៖** ខ្ញុំមានទីកន្លែងកំណើតហ្នឹង នៅភូមិត្រពាំងក្រពើ ឃុំមួងរាវ ស្រុកត្បូងឃ្មុំ ឥឡូវហ្នឹងខេត្តត្បូងឃ្មុំហើយ មុនខេត្តកំពង់ចាម បាទ។

**ស៖** សព្វថ្ងៃនេះ លោកមានទីលំនៅ នៅទីកន្លែងណា ហើយលោកប្រកបមុខរបរអ្វីដែរ?

**ឆ៖** សព្វថ្ងៃហ្នឹង ខ្ញុំមានទីកន្លែងផ្ទះរបស់ខ្ញុំហ្នឹង នៅផ្ទះលេខ១០ ហើយនិងក្រុមទី១ ភូមិទី៥ សង្កាត់វាលវង់ ក្រុងកំពង់ចាម ហើយមុខរបរខ្ញុំឥឡូវហ្នឹង ពីមុននឹងបើកបររថយន្ត នៅកន្លែងថ្នាក់ដឹកនាំ

ខេត្តហ្នឹង ហើយដល់ទៅឥឡូវហ្នឹង ខ្ញុំចូលនិវត្តន៍ហើយ។

**ស៖** ឪពុកបង្កើតរបស់លោកអី ហើយម្ដាយបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** ឪពុកបង្កើតរបស់ខ្ញុំហ្នឹងឈ្មោះ លោកឪពុកខ្ញុំហ្នឹងឈ្មោះ ស សេន គាត់ស្លាប់ហើយ។ ម្ដាយបង្កើតរបស់ខ្ញុំហ្នឹងឈ្មោះ សាន សារឿន មុខរបរគាត់ហ្នឹងជាកសិករ ប៉ុន្តែគាត់ស្លាប់អស់ហើយឥឡូវហ្នឹង។

**ស៖** ចុះប្រពន្ធរបស់លោកឈ្មោះអី ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធរបស់ខ្ញុំនុំងឈ្មោះ ម៉ម សារ៉ុន កូនខ្ញុំនុំងមានប្រាំនាក់ ប្រុសពីរនាក់ ស្រីបីនាក់។

[១០:២៧:០៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយលោក ស សារិន ជាចុងក្រោយបង្អស់នៃការផ្ដល់សក្ខីកម្មរបស់លោក ក្នុងឋានៈលោកជាដើមបណ្ដឹងរដ្ឋប្បវេណី លោកអាចមានសិទ្ធិថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនានិងស្ថានភាពព្យសនកម្ម គឺផលអន្តរាយដែលកើតមានចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។ ហើយយើងនឹងរំឭកលោកសាជាថ្មីម្ដងទៀត នៅពេលចុងបញ្ចប់នៃការផ្ដល់សក្ខីកម្មរបស់លោក។ ហើយអនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ ស្ទួន នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី សួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្ដី។ សហមេធាវីមុខដើមបណ្ដឹងរដ្ឋប្បវេណី រួមទាំងសហព្រះរាជអាជ្ញាមានរយៈពេលមួយថ្ងៃ គឺបួនវគ្គនៃថ្ងៃសវនាការក្នុងការសួរដេញដោលសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពប្រធាន លោក លោកស្រីចៅក្រម សូម -- មេធាវីនាំមុខសូមអនុញ្ញាតលោកប្រធាន ឲ្យលោកមេធាវី វ៉ែន ពៅ សួរសំណួរទៅលោកដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមលោកប្រធានអនុញ្ញាត។

[១០:២៨:២០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញលោក វ៉ែន ពៅ!

**លោក វ៉ែន ពៅ៖**

បាទ សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម និងភាគី ព្រមទាំងអង្គសវនាការទាំងមូល។

សូមជម្រាបសួរពូ ស សារិន ខ្ញុំបាទឈ្មោះ វ៉ែន ពៅ ជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ហើយក៏ជាមេធាវីផ្ទាល់របស់លោកពូ ស សារិន ដែរ។ ខ្ញុំចង់បញ្ជាក់ទៅលោកពូបន្តិចថា លោកពូបានបញ្ជាក់ប្រាប់ខ្ញុំមុន ពីរបីថ្ងៃថាពូមានបញ្ហាសុខភាពខ្លះ ដែលពូចង់សុំទៅ ស្នើសុំលោកប្រធានពាក់ព័ន្ធនឹងការចូលរួមនេះ តើពូអាចស្នើសុំផ្ទាល់បាន បើសិនជាពូចង់ស្នើសុំពីរឿងបញ្ហាសុខភាពពូយ៉ាងម៉េច។

[១០:២៩:១១]

**លោក ស សារិន៖**

សូមគោរពលោកប្រធាន ពាក់ព័ន្ធពីបញ្ហាសុខភាពហ្នឹង ខ្ញុំជម្រាបតាមរយៈលោកមេធាវីខ្ញុំហ្នឹង ខ្ញុំថាខ្ញុំបានចូលរួមសវនាការហ្នឹងតែមួយកំណាត់ ដូចថា មួយកំណាត់ថ្ងៃ ឬក៏មួយកំណាត់ល្ងាច ព្រោះខ្ញុំវាមានអការៈឡើងឈាម ហើយប៉ុន្មានថ្ងៃទៅក៏បានដែរ។ អាហ្នឹងសូមលោកប្រធានមេត្តាអធ្យាស្រ័យ ព្រោះខ្ញុំវាធ្វើទុក្ខការរឿងឡើងឈាមហ្នឹងតែម្ដង។ សូមលោកប្រធានអនុញ្ញាត គ្រាន់ថា១ថ្ងៃ ២ថ្ងៃ ៣ថ្ងៃ ៤ថ្ងៃក្ដី។ ខ្ញុំវាអត់សូវស្រួលខ្លួន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយអង្គជំនុំនឹងពិនិត្យតាមស្ថានភាពជាក់ស្ដែង ព្រោះបញ្ហានេះយឺតពេល ដោយសារមេធាវីនាំមុខតំណាងដើមបណ្ដឹតរដ្ឋប្បវេណីមិនបានផ្ដល់ពេលវេលា ផ្ដល់ដំណឹងនេះឲ្យយើងគ្រប់គ្រាន់ទេ យើងមិនបានត្រៀមៗជាមុននៅសាក្សី ឬក៏ដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងទៀត សម្រាប់ដំណើរការ។ យើងពិនិត្យជាក់ស្ដែង ពីព្រោះជាគោលការណ៍របស់អង្គជំនុំជម្រះ គឺត្រូវប្រឹងប្រែងធ្វើយ៉ាងណា ប្រឹងប្រែងប្រើប្រាស់ពេលវេលាឲ្យអស់ពីលទ្ធភាព ដើម្បីជំរុញល្បឿននៃកិច្ចដំណើរការសវនាការនេះឲ្យបានឆាប់ៗចប់តាមដែលអាចប្រឹងប្រែងធ្វើទៅបាន។

ដូច្នេះវាអាចមានបញ្ហាដែរ ហើយនៅទីនេះក៏យើងមានគ្រូពេទ្យដែរ។ អ៊ីចឹងតាមស្ថានភាពជាក់ស្ដែងនាពេលនេះ យើងមានពេលវេលាខ្លីដែរទេនៅព្រឹកនេះ ហើយយើងពេលវេលាសម្រាកផង។ អ៊ីចឹងចាំយើងនឹងពិនិត្យស្ថានភាពជាក់ស្ដែងណា។

បាទ ជាបន្តទៀត!

01377260



**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** បាទ ពូៗ ស សារិន ខ្ញុំមានសំណួរមួយចំនួនដែលត្រូវសួរពូនៅៗពេលព្រឹកនេះ។ ហើយសំណួរខ្ញុំជាសំខាន់ គឺពាក់ព័ន្ធទៅនឹងអ្វីដែលពូបានឆ្លើយ ឬក៏ផ្ដល់សក្ខីកម្មម្ដងហើយកាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣ ដែលពាក់ព័ន្ធទៅនឹងការងាររបស់ពូផ្ទាល់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ។ នៅក្នុងចម្លើយរបស់ពូ ដែលពូធ្លាប់បានផ្ដល់សក្ខីកម្មហើយ ពូបានបញ្ជាក់ហើយថា ពូធ្លាប់ជាអ្នកធ្វើការនៅមន្ទីរក-១៣ ដែលជាកន្លែងដឹកជញ្ជូន។ សូមទោស ក-១២។ ហើយពូបានបញ្ជាក់រួចហើយផងដែរថា ពូធ្លាប់បានចូលរួមដឹកគណៈប្រតិភូបរទេសសំខាន់ៗមួយចំនួនដែរនៅសម័យនោះ ដែលពូក៏បាន ធ្លាប់បានឃើញ ឬក៏ជួបមុខផ្ទាល់ជនជាប់ចោទទាំងពីរនាក់ ជាពិសេសគឺលោក ខៀវ សំផន និងលោក នួន ជា ផងដែរ។ ចំណុចសំខាន់ដែលខ្ញុំចង់សួរពូ ចង់ឲ្យពូបញ្ជាក់ឡើងវិញ ថាតើនៅពេលដែលពូដឹកភ្ញៀវបរទេស ក៏ដូចជាគណៈប្រតិភូបរទេសទាំងនោះ តើពូនៅចងចាំ ពូអាចរំឭកឡើងវិញបានទេ នៅពេលណា ហើយដឹកគណៈប្រតិភូប្រទេសណាខ្លះដែរបាទ?

[១០:៣២:២៨]

**ប្រធានអង្គជំនុំ៖**

លោកសរុបខ្លួនឯងអ៊ីចឹង ហើយលោកមិនសួរពីរស្ថានភាពនៃតួនាទី និងការធ្វើការងាររបស់គាត់ផង ហើយលោកមកឆ្លើយផ្ដល់សក្ខីកម្មខ្លួនឯង លោកមេធាវី! ម៉េចក៏មិនសួរពីដំណើររឿងសង្ខេបមកដើម្បីឲ្យវាមានជាប់ពាក់ព័ន្ធនឹងមុខងាររបស់គាត់នៅក្នុងតួនាទីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ លោករៀបចំសំណួរឡើងវិញ លោកមិនគប្បីផ្ដល់សក្ខីកម្មខ្លួនឯងទេ។

**លោក វ៉ែន ពៅ៖**

បាទ លោក។

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** ពូៗអាចបញ្ជាក់បានទេ ថាតើនៅក្នុងសម័យនោះ ពូ -- ខ្ញុំចង់ឲ្យពូនិយាយតែពី បន្ទាប់ពី ១៧ មេសា ៧៥ មក ថាតើពូមានតួនាទីជាៗអ្វី ហើយពូធ្វើការនៅកន្លែងណាបាទ?

**លោក ស សារិន៖**

**ឆ៖** នៅក្រោយពេលរំដោះថ្ងៃ១៧ មេសា ខ្ញុំកាលនុំងមានតួនាទីប្រមូលស្បៀង ដើម្បីឧបត្ថម្ភ

01377261



កងទ័ពដែលត្រៀមប្រយុទ្ធគ្នា ម្ខាងភាគី លន់ នល់ ម្ខាងភាគីខាងគេហៅកងទ័ពរំដោះហ្នឹង។ មានតួនាទីប្រមូលស្បៀង និងខាងសមរភូមិគេមកសុំអ៊ីចឹង។ ហើយដល់ទៅ ដូចខ្ញុំជម្រាបលោកប្រធាន សក្ខីកម្មខ្ញុំមុនមួយសាអ៊ីចឹង ស្បៀងខ្ញុំដល់ទៅឈប់ឲ្យកងទ័ពទៅ មកឲ្យខាងកងទ័ព លន់ នល់ វិញ។ ដល់ក្រោយមកហ្នឹង គេបញ្ជូនខាងកងទ័ពហ្នឹងទៅរៀនសូត្រ។ រៀនសូត្រសម័យនុ៎ង គ្មានស្អីជាងរឿងទៅស្តាប់ទេ កងទ័ព លន់ នល់ សម័យហ្នឹងនោះ។ រួចដល់ រួចទៅគេបញ្ជូនទៅរៀនសូត្រអស់ទៅ។

[១០:៣៤:៤៦]

ដល់ក្រោយមកទៀត ខាងថ្នាក់លើហ្នឹងគេត្រូវការកម្លាំងអ៊ីចឹងទៅ គេក៏ចុះពីមូលដ្ឋានមករើសបាន១ឡើងមកស្រុក មកតំបន់ មកតំបន់មក មកភូមិភាគ។ ម៉ាតំបន់ហ្នឹង គេយក១000នាក់ កាលហ្នឹងនោះ។ ខ្ញុំសង្ខេបខ្លី១។ រួចតំបន់ទាំងប្រាំនៃភូមិភាគបូព៌ាហ្នឹង មានតំបន់២១, ២០, ២២, ២៣, ២៤ ហ្នឹងមករៀននៅសាលាស-២០០។ រៀននៅសាលាស-២០០ហ្នឹងបានប្រហែលកន្លះខែ បាន១មកភ្នំពេញ។ បានគេបញ្ជូនមកភ្នំពេញ រួចតាមយោបល់លោកមេបញ្ជាការយោធាភូមិភាគ២០៣ហ្នឹង ភ្លេចឈ្មោះគាត់ហើយ គាត់ឈ្មោះ ម៉ុន អ៊ីចឹងហើយ ឈ្មោះ សំណាង -- កែវ សំណាង។ គាត់សរុបថាមានប៉ុន្មាន៥.000នាក់ឡើងមកមជ្ឈិមហ្នឹង។ រួចឡើងមកហ្នឹងដើរតែយប់១ទេសម័យហ្នឹងនោះ។ ដើរពីស្វាយរមៀតហ្នឹងមកដេកនៅព្រៃវែង ចេញពីព្រៃវែងហ្នឹងមកដេកនៅពាមបាកណាម អ្នកលឿង។ ចេញពីហ្នឹងមកដេកនៅគគី ខាងរោងចក្រក្ដារបន្ទះយើងដីឥដ្ឋហ្នឹង។ ចេញពីហ្នឹងមកទៀតមកច្បារអំពៅ ចេញពីច្បារអំពៅមកបានមកតាមផ្លូវយើងវិមានឯករាជ្យក្បាលថ្នល់ហ្នឹង ឆ្ពោះមកវិមានឯករាជ្យហ្នឹងមកវាំងមកជិតវាំង មិនដែលស្គាល់វាំងស្គាល់អីទេខ្ញុំជីវិតជាកូនកសិករ តែភ្នំពេញហ្នឹងក៏មិនដឹងបែរមុខទៅខាងណាដែរ។ ទើបមកដល់ភ្នំពេញលើកទី១ ឃើញវិមានឯករាជ្យនេះក៏ចេះនឹកឃើញធ្លប់ឃើញនៅក្នុងគម្រប់សៀវភៅកាលនៅពីតូច១រៀនហ្នឹង ចេះឆ្ងល់ម្នាក់ឯងមានពីណាសួរ ដើរដំណើរទ័ពគេដើរបណ្ដើរអី១បណ្ដើរអ៊ីចឹង រួចមកដល់កន្លែងខាងឆ្វេងដៃវាំងហ្នឹងត្រង់ហ្នឹងគេហៅមន្ទីរក-៧ ប៉ុនក្រោយមកទៀតទេបានខ្ញុំស្គាល់គេហៅថា ក-៧ នោះ។

[១០:៣៧:១៤]

បានបែងចែកកម្លាំងគេ មានអ្នកនៅឈរចាំរើសហ្នឹងកម្មាភិបាលឈរចាំរើសហ្នឹង មានជាច្រើនដែលក្រោយមកដែលខ្ញុំស្គាល់ឈ្មោះគាត់មាន តាព្រំ, តាគី, តាភុំ ហ្នឹង មានទាំង ប៉ង់ ហ្នឹង គេឈរចាំរើស។ រើស គេសួរខ្ញុំដំបូង គេសួរថាមិត្តឯងចេះបើកឡានទេ? ខ្ញុំថា ខ្ញុំអត់ចេះទេ។ អ៊ីចឹងចេះបររទេះ

គោទេ? តាភុំ ហ្នឹងគាត់សួរ។ តាភុំ ជាគ្រូនយោបាយ ក្រោយមកគាត់ ខ្ញុំបាន គាត់បានបង្រៀនខ្ញុំជាគ្រូនយោបាយនៅសាលា ក-១៥ បច្ចេកទេសសូវៀតហ្នឹង។ រើសគ្នាហ្នឹងបានច្រើននាក់ដែរ ប្រហែលជា ៣០០នាក់អីដែរណ៎ាប៉ុណ្ណឹង។ រើសទៅគេអត់ទាន់ឱ្យទៅបើឡានភ្លាមទេ គេចែកកាំបិតពូថៅ កាំបិតហ្នឹងទៅត្រាយព្រៃ ឱ្យចបអីក្បាលជ្រោយណោះ គ្មានផ្ទះដេកទេ ដេកតែក្រោមដើមជម្ពូហ្នឹង។ កាប់ព្រៃហ្នឹងដាំបន្លែ ខ្យល់ធ្លាក់ពីជើងហើយកាលហ្នឹង ខ្ញុំចំណាំ ទឹកស្រកហើយ។

ដល់ក្រោយមកបានប្រហែលមួយអាទិត្យ បួនដប់ថ្ងៃហ្នឹងបាន បងវុយ ប្រធានមន្ទីរក-១២ហ្នឹងគាត់ទៅដើររើសពីហ្នឹងមក ខ្ញុំលួចមើលកាយវិការគាត់ តែពីណាខ្ជិលហ្នឹង គាត់អត់ហៅទេ។ ទាល់តែរាងអ្នកធ្វើ ឧស្សាហ៍ធ្វើពលកម្មហ្នឹង បានគាត់ហៅមកសួរនាំពីរឿង គាត់សួរថា មិត្តណាខ្លះ -- គេចែកជាក្រុមៗនោះ -- ដែលចូលបដិវត្តន៍១៧មេសាហ្នឹង មុន ១៧ មេសា ឱ្យលើកដៃ។ ដល់ទៅ ខ្ញុំនឹកឃើញខ្ញុំមុន ១៧ មេសា ដែរតើ លើកដៃទៅ ដល់រួចគាត់សួរខ្ញុំថា ដល់អ៊ីចឹងគាត់ប្រាប់ថា មិត្តឯងរៀបខោអាវទៅកំពង់កាណូតទៅ ហើយចេះតែឆ្ងល់ទៀតហើយ ទៅណាទៀតហើយ រួចទឹករលកដូចថា ចលនាតស៊ូបដិវត្តន៍ហ្នឹងវាដូចផ្សងព្រេងណាស់។ យុទ្ធជនទាំងឡាយចុះមកពីតាមតំបន់ភូមិភាគត្រង់ហ្នឹងច្រើន តាមគ្រប់ភូមិភាគ គេយកទៅដាក់ត្រង់ហ្នឹង រួចខាងកម្លាំងខាងក្នុងដូចថា ខាងរោងចក្រទៅ ខាងមន្ទីរនេះមន្ទីរនោះគេត្រូវការអ៊ីចឹងទៅ។ ដល់ក្រោយមកហ្នឹងបានជួបៗគ្នាខ្លះ ហើយខាងកាត់ដេរអីៗអ៊ីចឹងទៅ ខ្លះនៅខាងសាលាភាសា គេមានចែកជាសាលាភាសាអីៗឱ្យរៀនជាភាសាគ្រប់ភាសា នៅបឹងត្របែកអីៗហ្នឹង។ ជួបគ្នាពេលដែលខ្ញុំចេះបើកឡាន ក្រោយមកទេ។ ក៏ទៅបានគ្នា ទៅរើសហ្នឹង បានគ្នាប្រហែល ៣០នាក់ មកនៅក-១២ ហ្នឹង។

[១០:៤០:៣០]

ដល់មកដំបូង មកឱ្យនៅមុខចំការមន កន្លែងមន្ទីរគណបក្សរាល់ថ្ងៃហ្នឹង អាហ្នឹងមានឃ្លាំងមួយឆេះ មុខដំណាក់ចំការមនហ្នឹង រួចអត់ផ្ទះច្រើនអ៊ីចឹងទេ កាលនោះវាលល្វឹង។ ឆេះហើយកាលនោះសង្គ្រាមបំផ្លាញ ដេកក្រោមផ្ទះឆេះនោះ អត់មានដំបូលទៀត។ ទៅដល់ត្រង់ហ្នឹងគេឱ្យដាំបន្លែដដែល។ ដាំបន្លែហ្នឹងបានប្រហែលជាបួនដប់ថ្ងៃ គេឱ្យទៅ តែយើងខ្ជិលហ្នឹង គេអត់ឱ្យទៅណាទេ នៅតែដាំបន្លែហ្នឹង ទាល់តែឧស្សាហ៍កាលហ្នឹង។ ខ្ញុំចេះតែលួចមើល បងៗគាត់ចុះទៅរើសហ្នឹង។ រួចដល់អ៊ីចឹង គាត់ដកខ្ញុំ ហ្នឹងមុនមក ប្រមាណបួនប្រាំនាក់ ប្រហែលប្រាំមួយនាក់ប៉ុណ្ណឹង មួយក្រុមហ្នឹង ហើយទៅឱ្យអូសឡាន នៅខាងកោះធំ ស្អាង កោះក្របីអីឯណោះ ដែលប្រជាជន ១៧ មេសា គាត់គេជម្លៀសគាត់ចេញ

ទៅ ប៉ុនអត់មានមនុស្សទេ ជំនាន់ខ្ញុំមកនោះ ស្ងាត់អស់ហើយ នៅតែខ្មោចឡានហ្នឹង។ តាមផ្លូវហ្នឹងតម្រៀបត្រៀបត្រា រួចតាមផ្លូវហ្នឹង--។

**ប្រធានអង្គជំនុំ៖**

ឈប់សិនលោក ស សារិន! ហើយលោកចាំស្ដាប់សំណួរ ហើយសុំឲ្យសំណួរខ្លីៗបានហើយ តែមិនអីចឹងវែងពេក ហើយវាប្រាសចាកនូវភាពចាំបាច់នៃការស្ដាប់សក្ខីកម្មសាក្សី ហើយលោកមានបញ្ហាសុខភាពផង លោកកុំព្យាយាមឆ្លើយវែងចាក ប្រាសចាកពីសំណួរអី ឆ្លើយតបចាំបាច់ទៅនឹងសំណួរខ្លីៗទៅបានហើយ។ ហើយមេធាវីគប្បីអង្កន់សំណួររបស់លោកដើម្បីឲ្យ ធ្វើម៉េចឲ្យសាក្សីស្ដាប់យល់ ហើយឆ្លើយបាន។ សួរៗច្រើនចុះ ចៀសវាងសួរឲ្យគាត់អត្ថាធិប្បាយវែងឆ្ងាយអន្លាយពេក វាពិបាកក្នុងការស្វែងរកការពិតណាស់។

[១០:៤១:២៩]

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** តើមន្ទីរក-១២ នោះមានទីតាំងនៅឯណានៅពេលនោះ ពូអាចបញ្ជាក់បានទេ? ហើយពូដឹងថា មន្ទីរក-១២ នេះស្ថិតក្រោមការគ្រប់គ្រងរបស់ថ្នាក់លើណាដែរបាទ?

**លោក ស សារិន៖**

**ឆ៖** មន្ទីរក-១២ នេះ គឺមានបរិវេណច្រើនកន្លែងណាស់។ បរិវេណមន្ទីរធំកណ្ដាលហ្នឹង នៅចំសណ្ឋាគារបង់មេគង្គគេរាល់ថ្ងៃហ្នឹង ប៉ុនកាលនោះ ផ្ទះទាបទេ ដែលដាក់រថយន្តថ្នាក់ដឹកនាំទាំងអស់ ដូចអ៊ំ ប៉ុល ពត, អ៊ំនួន ជា, អ៊ំ ខៀវ សំផន អីៗថ្នាក់ដឹកនាំដែលធំៗទាំងអស់ គឺនៅក្នុងមន្ទីរ ក-១២ ហ្នឹង អាចំកណ្ដាលហ្នឹង និងសម្រាប់ទទួលថ្នាក់គណៈប្រតិភូ ក្រសួងការបរទេសក្ដី គណៈប្រតិភូប្រធានាធិបតីក្ដីអីហ្នឹង ឡានទាំងអស់ និងអ្នកបច្ចេកទេសមកពីបរទេស វិស្វករបរទេស មកពីបរទេសអីហ្នឹងក៏ទទួលឡាននៅហ្នឹងទាំងអស់។ ត្រង់ហ្នឹងសម្រាប់ទទួលដឹកភ្ញៀវបរទេសនៅក្នុងស្រុកយើងហ្នឹង និងភ្ញៀវក្រៅស្រុក។

**ស៖** បាទ ខ្ញុំសូមកាត់ពូ។ ចុះពូដឹងថា មន្ទីរក-១២ ហ្នឹងក្រោមការគ្រប់គ្រងរបស់ថ្នាក់លើណាដែរបាទ ពូដឹងទេ?

[១០:៤៤:៣៦]

**ឆ៖** មន្ទីរក-១២ ហ្នឹង មានអ្នកគ្រប់គ្រងប្រធានគេ កាលហ្នឹងគេហៅគណៈមន្ទីរ។ គណៈមន្ទីរ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហ្នឹងមានឈ្មោះ បងមៀល បងវុយ បងសុត បងហ៊ិន បងអ៊ូន បងថុន បងហួន អាហ្នឹងបន្តបន្ទាប់មក អាហ្នឹងថ្នាក់កង ថ្នាក់ដូចប្រធានកងបើកបរត្រឹម ក្ដាប់ត្រឹម៣០-៤០នាក់ មានឈ្មោះ បងឡាត់, មានឈ្មោះ បងឆិត ហ្នឹងប្រធានកង ប្រធានកងហើយ។ មានឈ្មោះបងហួន, មានឈ្មោះបងថេន បាទ ប្រហែលបួនកងហ្នឹង។ កងបងឆិត បងឡាត់ បងថេន បងហួន បួនកងហ្នឹងគ្នាប្រហែលជាមួយ ១០០ ជាងនាក់អីប៉ុណ្ណឹង ក្រុមអ្នកបើកបរហ្នឹង។ ហើយក្រុមបងហួន ហ្នឹងនៅចំការមនណោះ កន្លែង--

**សៈ** សូមទោស ខ្ញុំត្រូវការពូប្រាប់ ថាតើ ខ្ញុំចង់ដឹងថាតើ ក-១២ មន្ទីរក-១២ ហ្នឹងក្រោមការគ្រប់គ្រងផ្ទាល់ពីថ្នាក់លើណាទៀតទេក្រៅពីឈ្មោះដែលពូបានរៀបរាប់អំមិញហើយ?

**ឆៈ** នៅក្រោមការគ្រប់គ្រងរបស់ថ្នាក់លើហ្នឹង គឺនៅគ្រប់គ្រងរបស់គណៈមជ្ឈិមបក្ស គ្រប់គ្រងផ្ទាល់ហ្មង គឺមជ្ឈិមបក្ស៨៧០ នៅក្នុងលិខិតបើកផ្លូវខ្ញុំអីហ្នឹងគេដាក់អ៊ីចឹង ហើយមានឈ្មោះសមមិត្តខាង ប៉ុនមិនដឹង សមមិត្តខាង ហ្នឹងមួយណាទេ។ អត់ដឹងថា មិត្តខាង ហ្នឹងមួយណាទេនៅក្នុងលិខិតបើកផ្លូវខ្ញុំ គឺកូនសៀវភៅមួយតូច ធំជាងអត្តសញ្ញាណបណ្ណយើង ប៉ុនទូរស័ព្ទយើងអាយហ្វូនហ្វាយ ហ្នឹង។ តូចហ្នឹង រួចពណ៌វាលឿង គេដាក់លិខិតបើកផ្លូវហ្នឹង រួចនៅក្នុងហ្នឹងគេដាក់អង្គភាពបរទេស ក-១២ របស់មន្ទីរ៨៧០។ គេដាក់អ៊ីចឹង ប៉ុនបើនិយាយទៅក្រោមការក្ដោបក្ដាប់របស់មជ្ឈិមបក្សផ្ទាល់តែម្ដងមន្ទីរហ្នឹង។ ខ្ញុំគ្រាន់ជម្រាប។

[១០:៤៧:៣០]

**សៈ** សូមអរគុណ។ អ៊ីចឹងៗបានន័យថានៅក្នុងលិខិតធ្វើដំណើរដែលពូមានថាពណ៌លឿងហ្នឹង គឺមានបញ្ជាក់ថា មន្ទីរ៧៧០ -- ៨៧០។ ខ្ញុំចង់សួរថា តើពូមានធ្លាប់ឮ ឬក៏មេបញ្ជាការពូ ឬអង្គភាពពូប្រាប់ពូថា តើមន្ទីរ៨៧០ ហ្នឹងជាមន្ទីរអីដែរទៅ?

**ឆៈ** មន្ទីរ៨៧០ អត់មានទីតាំងទេ គ្រាន់តែឈ្មោះដូចលេខកូដទេ សំដៅទៅលើមជ្ឈិមបក្សហ្មង តាមមើល។ អត់មានទីតាំងនៅណាៗ បើតាមខ្ញុំស្មាននោះ វានៅ ក-១ហ្មង។ ព្រោះ ក-១ ហ្នឹងកន្លែងថ្នាក់ដឹកនាំនៅ បើមិន ក-១, ក-៣ ជាប់គ្នាហ្នឹង។ គ្រាន់ថាដឹងថា លេខជាលេខកូដរបស់មជ្ឈិមបក្ស អត់មានទីតាំង ព្រោះសម័យនុ៎ងគេអត់មានសរសេរស្លាកថា ត្រង់នេះមន្ទីរ៨៧០, ត្រង់នេះមន្ទីរ ក-១២, ត្រង់នេះមន្ទីរ ក-៧, ត្រង់នេះសាលានយោបាយមជ្ឈិមបក្សអីទេ គេអត់មានសរសេរទេ។ មានសរសេរតែដូចកន្លែងសភាតំណាងប្រជាជនកម្ពុជា ត្រង់ហ្នឹងមានមួយ។ ទីស្ដីការក្រសួងការបរទេស ត្រង់ហ្នឹងមានមួយ។ បើរោងចក្រមានគ្រប់ៗ គេដាក់ស្លាកគេពីមុនហ្នឹង តែឯមន្ទីរ ក៧ ហ្នឹង អត់មាននរណាដឹង

ទេ ទាល់តែដឹងភាគច្រើនតែពួកខ្ញុំអ្នកបើកឡាន គេឧស្សាហ៍ប្រើទៅមន្ទីរ“ក”នេះ “ក”នោះ អ៊ីចឹងទៅ។ អាហ្នឹងដឹងៗអ៊ីចឹងទេ មន្ទីរ៨៧០ ហ្នឹង អត់មានមន្ទីរទេ ជាឈ្មោះលេខកូដមជ្ឈិមបក្សទេ លោកមេធាវី។ សូមជម្រាបប្រសាសន៍ដល់អង្គសវនាការ។

[១០:៤៩:៣១]

**សៈ** ពូៗបានបញ្ជាក់ហើយថា ពូដឹងថាមានក-១, ក-២ អីជាដើម។ ចាតើពូអាចបញ្ជាក់នៅសម័យនោះមន្ទីរក-១, ក-២ មានប្រហែលប៉ុន្មានដែរ ពូអាចនៅចងចាំ ឬកន្លែងដែលពូធ្លាប់ទៅនុ៎ងមានមន្ទីរ“ក” ដល់ប៉ុន្មានដែរពូអាចចាំបាន?

**ឆៈ** ខ្ញុំចាំបានត្រួសៗទេ។ មន្ទីរមានតែ មើល ក-១, ក-២, ក-៣។ ក-១ ហ្នឹងកន្លែង អ៊ំប៉ុលនៅ។ ក-២ ហ្នឹងប្រហែលជាអ៊ំ អៀង សារី កាលហ្នឹងនៅជិត ក-១២ ដែរ ក្រោយមួយជួរស្ថានទូតហ្នឹងខ្ញុំឃើញគាត់ឧស្សាហ៍ចេញចូល។ ហើយ ក-៣ ប្រហែលជាកន្លែង អ៊ំនួន។ តាមមើល ក-៣ ហ្នឹងជាប់ ក-១ នៅដែលមានប្លុកនៅពីវិមានឯករាជ្យយើងហ្នឹង ទៅដល់ទូតអាមេរិកចាស់ ឡើងទៅដល់មហោស្រពទន្លេបាសាក់បរិវេណ ក-១ ហ្នឹង ហើយនិង ក-៣។ ហើយជាប់នឹងខាងវិទ្យុទាក់ទង “ក” ប៉ុន្មានទេនេះ ១៨អ៊ីចឹងហើយយ៉ាង។ ហើយមន្ទីរ“ក”ៗ ហ្នឹង បើតាមខ្ញុំចាប់ហ្នឹងមានដល់រហូតដល់ ក-៣៣, ៣៤។ ក-៣៣ ហ្នឹងខាងវិទ្យុកម្ពុជាប្រជាធិបតេយ្យ។ បាទ ក-៣៤ នុ៎ងខាងសិល្បៈ ប្រហែលជា “ក” ជាង៣០នោះ។ រួច ក-១២ ហ្នឹង ខ្ញុំខាងឡានហ្នឹង។ ក-៤ នោះ ខាងកាត់ដេរ នៅបឹងកេងកង របស់តាភឹម ប្រធានគាត់។ ខ្ញុំចំណាំឈ្មោះគាត់។ រួច ក-៦ហ្នឹង សាលានយោបាយមជ្ឈិមបក្សបុរីកីឡាហ្នឹង។ ក-៧ ហ្នឹង កន្លែងមន្ទីរនីរសារហ្នឹង ខាងឆ្វេងដៃវាំងហ្នឹង។ ភ្លេចអស់ហើយ យូរហើយលោកមេធាវី ចាំគ្រាន់តែថា មន្ទីរ “ក”ៗហ្នឹងប្រហែលមានជាង៣០។

[១០:៥១:៥០]

**សៈ** បាទ សូមអរគុណ។ ខ្ញុំចង់សួរពូបញ្ជាក់ឡើងវិញពាក់ព័ន្ធនឹងការដឹកភ្ញៀវ ក៏ដូចជាគណៈប្រតិភូបរទេសដែលពូធ្លាប់បានបញ្ជាក់ថា ពូធ្លាប់បានដឹកពូ សូមពូរំឭកឡើងវិញ ថាតើធ្លាប់បានដឹកភ្ញៀវក៏ដូចគណៈប្រតិភូធំៗដែលមកចូលរួម មកទស្សនកិច្ចនៅក្នុងសម័យនោះ ថាតើមានប្រទេសណាខ្លះហើយនៅពេលណា ពូអាចនៅចាំបានខ្លះទេ?

**ឆៈ** ពេលដឹកភ្ញៀវបរទេសហ្នឹងមានច្រើនណាស់ ច្រើនប្រទេសណាស់ រៀបរាប់មិនអស់ទេ។ បើនិយាយពីថ្នាក់ការបរទេសវិញ ច្រើនណាស់ គេមកទស្សនកិច្ចមួយឆ្នាំៗ បន្តិចប្រទេសនេះ បន្តិច

ប្រទេសនោះ ដូច ប្រទេសយូហ្គោស្លាវី, ប្រទេសកូរ៉េ ប្រទេសអីហ្នឹង ចិនប្រជាមានិតហ្នឹង ឧស្សាហ៍មកច្រើនជាងគេ។ ហើយថ្នាក់ប្រធានាធិបតីខ្ញុំចាំ ថ្នាក់ប្រធានាធិបតីធំៗទេ ចាំច្រើនជាងគេហ្នឹង គឺមកប្រធានាធិបតីភូមា ប្រធានាធិបតីឡាវ និងលេខបក្សកុម្មុយនីស្តចិន។ ចាំធំៗជាងគេហ្នឹង ព្រោះការទទួលកាលនុំងវាហឹកហាក់ច្រើន។ អីចឹង ខ្ញុំនៅចាំតែបីហ្នឹងទេ។ ទី១ គឺប្រធានាធិបតីភូមាហ្នឹង គាត់ឈ្មោះ អ៊ូណេវិន មកទស្សនកិច្ចជាផ្លូវរដ្ឋយើងហ្នឹង។ ហើយពេលទទួលគាត់អ៊ំ ខៀវ សំផន ហ្នឹងគាត់អ្នកទៅទទួល និងរដ្ឋមន្ត្រីខាងក្រោមៗហ្នឹងទៅទាំងអស់។ តាមខ្ញុំចាំ ឡានច្រើនណាស់មក--

[១០:៥៣:៥៨]

**ស៖** ខ្ញុំសូមកាត់ពូ ថាតើពូអំមិញបញ្ជាក់ថា នៅពេលប្រធានាធិបតីភូមាមក លោក ខៀវ សំផន គាត់ទៅទទួល។ តើពូមានដឹង ឬមានអ្នកណាប្រាប់ពូ នៅថាតើគាត់មានឋានៈជាស្អីដែរ លោក ខៀវ សំផន នៅពេលនោះ?

**ឆ៖** លោក ខៀវ សំផន កាលនុំងគាត់មានឋានៈជាប្រធានគណៈប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ ហើយបើនិយាយពីពាក្យយើងឥឡូវហ្នឹង គេហៅប្រធានាធិបតីហើយ ឬប្រមុខរដ្ឋហើយ ព្រោះអ៊ូណេវិន គាត់ប្រធានាធិបតី។ អីចឹងប្រធាននាធិបតី ថ្នាក់ប្រធានាធិបតី គេទៅទទួលហើយ។ អាហ្នឹងជម្រាបលោកមេធាវីអីចឹង។

**ស៖** បាទ សូមអរគុណ។ ចុះក្រៅពីពូបានឃើញគាត់ទៅចូលរួមទទួលគណៈប្រតិភូនោះ ថាតើពូធ្លាប់មានដឹកភ្ញៀវបរទេស ឬក៏គណៈប្រតិភូបរទេសណាទៅជួបមេដឹកនាំណាទៀតដែរទេបាទ?

**ឆ៖** ពេលប្រធានាធិបតីមកម្តងៗ ឬគណៈប្រតិភូមកម្តងៗ គេហ្នឹង គេហៅថានឹងមានជូនសារតាំង ចំពោះប្រធានគណៈប្រធានរដ្ឋហ្នឹង។ ខ្ញុំឃើញកាលហ្នឹង ប្រធានាធិបតីហ្នឹង ខាងប្រហែលជាថ្នាក់ខាងការបរទេសទេ មិនមែន អ៊ូណេវិន ទេមកទេកាលហ្នឹង ទៅជូនសារតាំងនៅវិមានគណៈប្រធានរដ្ឋហ្នឹង។ វិធានគណៈប្រធានប្រធានរដ្ឋហ្នឹង កន្លែងខាងជើងវិមានឯករាជ្យរាល់ថ្ងៃ មុនហ្នឹង ខ្ញុំឃើញគេដាក់ស្លាកក្រសួងយុទ្ធជនសង្គមកិច្ចត្រង់ហ្នឹង។ កន្លែងអ៊ំ ខៀវ សំផន ចាស់ហ្នឹងនោះ។ ខ្ញុំតែង ខ្ញុំឃើញគេទៅជូនសារតាំងចំពោះគាត់នៅហ្នឹង ឧស្សាហ៍ជូនទៅហ្នឹង។

[១០:៥៦:៤២]

**ស៖** បាទ សូមអរគុណ។ ចុះក្រៅពីទៅជូនសារតាំង ថាតើពូធ្លាប់ដឹកគណៈប្រតិភូ ឬក៏បានឃើញលោក ខៀវ សំផន ទៅជូនភ្ញៀវ ឬទៅកន្លែងណាទៀតដែរទេ ក្រៅពីៗអ្វីដែលពូបាននិយាយអំមិញ

ហើយបាទ?

**ឆ៖** ក្រោយពីហ្នឹងទៅ មានជូនប្រតិភូប្រធានាធិបតីទៅមើលវាំង។ មើលនៅវាំង ប្រាសាទកែវមរកតហ្នឹង។ គាត់ជូនគណៈប្រតិភូ អូណេរិន ហ្នឹងទៅ។ រួចពីហ្នឹងទៅ ទៅជប់លៀងនៅវិមានចំការមនកន្លែងវិមានចំការមនយើងរាល់ថ្ងៃហ្នឹង ហើយទៅមើលសិល្បៈ ដល់ក្រោយមក ខាងភ្ញៀវគេជប់លៀងយើងវិញ គេហៅជប់លៀងលា មកដល់យើងទទួលគេ ទៅវិញគេជប់លៀងលាយើងវិញ នៅវិមានរដ្ឋាភិបាលមុខវត្តភ្នំហ្នឹង។

**ស៖** បាទ សូមអរគុណ។ ពូ ខ្ញុំចង់បញ្ជាក់ ថាតើពូមានចាំ ឮពេលដែលពូជូនគណៈប្រតិភូទៅហ្នឹង ថាពូមានបានឮការពិភាក្សាគ្នារវាងថ្នាក់ដឹកនាំហ្នឹងដែរទេ ឬក៏ពូគ្រាន់មើលចម្ងាយ ឬយ៉ាងម៉េច? ពូអាចដែលមានឮសួរគាត់និយាយពីអី ពិភាក្សាគ្នាពីអីដែរទេ?

**ឆ៖** ចំពោះការឮគាត់ពិភាក្សានិយាយពីអីៗ ស្តាប់អត់បានទេ គ្រាន់មើលឃើញកាយវិការ។ ខ្ញុំបើករថយន្តទី១១។ គាត់ថ្នាក់ប្រធានាធិបតី គាត់ជិះ គេដាក់លេខឡាន លេខកូដតាមឡាន លេខ១ លេខ២ លេខ៣ រហូតឡានជាង៣០។ ខ្ញុំបើកឡានទី១១។ អ៊ីចឹងអត់មានឃើញគាត់ដោយផ្ទាល់ជិតៗដែរទេ ឆ្ងាយៗដែរទេ ព្រោះយើងខ្ញុំ យើងគោរពតួនាទី ថាយើងជាអ្នកឡាន អត់មានដើរចោលឡានទេ។ យ៉ាងឆ្ងាយគឺ៣ម៉ែត្រហ្នឹង ព្រោះពេលគណៈប្រតិភូចុះពីយន្តហោះអីៗអ៊ីចឹង ឡានគេតម្រៀបរួចស្រេច យើងឃើញគាត់តែពីចម្ងាយទេ គាត់និយាយអីជាមួយភ្ញៀវៗអី យើងអត់ឮទេ រួចទៅជូនសារតាំងអ៊ីចឹងដែរ គ្រាន់តែខ្ញុំដឹកភ្ញៀវដូចភ្ញៀវខាងភូមាហ្នឹងទៅ គេចុះទៅ គាត់មួយសន្ទុះទៅបានឃើញ បងហឿន បើកម៉ាកស៊ីដេស ដឹកគាត់មកវង្វក្នុងដំណើរយ៉ាងរហ័សរហួន គាត់ដំណើររហ័សណាស់អ៊ំ ខៀវ សំផន នុ៎ងហ្នឹងបាទ។ ឃើញគាត់ដើរលឿន ឡើងចូលទៅក្នុងនុ៎ងផ្តុក គ្មាននិយាយអីមួយមាត់ទេ។ ដោយមានកាលនុ៎ង មានពិធីការគេ ដូចបង ជាម ហ្នឹង បងជាម បងឈាន អីហ្នឹង។ គាត់ចាំបើកទ្វារឡានអញ្ជើញគាត់ចូលកន្លែងវិមាន១ប្រធានគណៈប្រធានរដ្ឋហ្នឹង អត់ដែលឮគាត់និយាយជាសារជិតៗអីទេ ព្រោះនៅឆ្ងាយបាទ។

[១១:០០:២៩]

**ស៖** បាទ សូមអរគុណ។ ក្រៅពីពូបានដឹកភ្ញៀវ ក៏ដូចគណៈប្រតិភូនៅជុំវិញភ្នំពេញ ថាតើមានគណៈប្រតិភូ ឬភ្ញៀវត្រូវជូនដំណើរ ឬក៏ថ្នាក់ដឹកនាំជូនដំណើរទៅតាមបណ្តាខេត្តនានាអីដែរទេបាទនៅសម័យនោះ?

**ធ៖** ភ្ញៀវភូមាហ្នឹងមក ដល់រួចគេទៅទស្សនកិច្ចនៅសៀមរាប ខ្ញុំគ្រាន់តែបានជូនឡើងទៅត្រឹមពោធិ៍ចិនតុងទេ។ ឡានមួយខ្សែទៀត នៅចាំខាងសៀមរាបគេត្រៀមរួចអស់ហើយ។ ទាំងអ៊ំ ខៀវ សំផន ហៅ អ៊ំហែម ហ្នឹងក៏ជូនប្រធានាធិបតីហ្នឹងទៅទស្សនកិច្ចអង្គរ។ ដល់រួចគេក៏ទៅស្រុកគេទៅ តែពេលហ្នឹងខ្ញុំអត់បានទៅទេ ខ្ញុំបកមកហ្កាវាសវិញ។ រួចដំណើរហ្នឹងទៅ ហើយ អូណេរិន ក៏គាត់ទៅស្រុកគាត់ទៅបាទ។

**ស៖** បាទ សូមអរគុណ។ ចុះពាក់ព័ន្ធនឹងលោក នួន ជា វិញ ថាតើពូធ្លាប់បានឃើញឬក៏ជួបគាត់ទៅចូលរួមអមដំណើរគណៈប្រតិភូនៅពេលណាដែរ ឬពូអាចនឹកឃើញឬចងចាំបានខ្លះទេពាក់ព័ន្ធនឹងលោក នួន ជា?

**ធ៖** រាល់ៗមានគណៈប្រតិភូថ្នាក់ប្រធានាធិបតីហ្នឹង គឺៗមានទៅទាំងអស់ហ្នុង ទៅទទួលនៅពោធិ៍ចិនតុងហ្នឹង ថ្នាក់រដ្ឋមន្ត្រី ទាំងអ៊ំនួន ហ្នឹងអីហ្នឹងមក ក៏ទៅដែរកាលហ្នឹងនោះ បាទ ទៅទទួលប្រធានាធិបតី គ្រាន់តែថាទៅតាមឋានៈនីមួយៗ។

[១១:០២:៣៨]

**ស៖** បាទ សូមអរគុណ។ ពាក់ព័ន្ធនឹងលោក នួន ជា វិញ តើនៅសម័យនោះពូមានដឹង ឬមានអ្នកណាប្រាប់ពូថាគាត់មានឋានៈឬតួនាទីជាអ្វីដែរ?

**ធ៖** បើតាមខ្ញុំដឹងគាត់មានឋានៈជាប្រធានតំណាង ប្រធានតំណាងសភាប្រជាជនកម្ពុជា គាត់ជាប្រធានតំណាងសភាប្រជាជនកម្ពុជា។ ព្រោះអត់ពិបាកអីចំណាំទេកាលហ្នឹង ទស្សនាវដ្ដី វិទ្យុអីក៏ផ្សាយ ចេះចាំពីពេលហ្នឹងទៅ រួចមានពិបាកអីទេ។

**ស៖** បាទ សូមៗអរគុណ។ ចំណុចមួយទៀតពាក់ព័ន្ធនឹងការចូលរួមក្នុងខួបជ័យជម្នះខែមេសាឆ្នាំ៧៧ ថាតើ នៅក្នុងរបបនោះថាតើពូធ្លាប់បានចូលរួមអបអរសាទរខួបជ័យជម្នះអីដែរទេ ពូនៅចាំទេនៅពេលណា ហើយនៅឆ្នាំណា ហើយពូបានជួបថ្នាក់ដឹកនាំណាខ្លះនៅៗសម័យនោះ?

[១១:០៤:០៧]

**ធ៖** សូមទោសលោកមេធាវី ខ្ញុំចង់បង្ហើយព័ត៌មានខ្ញុំបន្តិច ព្រោះវាសំខាន់ដែរ។ ការទទួលប្រធានាធិបតីភូមាអីៗហ្នឹង រួចប្រធានាធិបតីឡាវ។ ប្រធានធិបតីឡាវហ្នឹងគាត់មានឈ្មោះ សុផាន់វង្សហ្នឹងក៏ អ៊ំខៀវ សំផន ទៅទទួលដែរបាទ។ ហើយពេលហ្នឹងដល់ទៅខ្វះឡានខ្វះអី រួចមកជប់លៀងទទួលជប់លៀងលាអីដូចគ្នាអ៊ីចឹង ទៅមើលរាំងមើលអីដូចគ្នាអ៊ីចឹង។ ទៅដល់ខ្វះឡានខាង បងមៀល ហ្នឹង

គាត់ឲ្យខ្ញុំនិងក្រុមការងារនៅនេះហ្នឹង ខាងក្រុម បងឡាត់ ឡើងយកឡានទៅប្រហែលជា១០គ្រឿងទៀត បើកទាំងយប់ទៅ ទៅចាំទទួលនៅឯសៀមរាបតែម្តង។ រួចទៅ ទៅមើលវត្តអង្គរ វត្តអី -- ប្រាសាទអង្គរ បាយ័នអីៗហ្នឹងធម្មតាអីចឹង។ បន្ទាប់ពីហ្នឹងមកទៀត នាយករដ្ឋមន្ត្រី -- លេខាបក្សកុម្មុយនីស្តចិន ឈ្មោះ អ៊ីង យឹងគួយ បាទ ឈ្មោះ អ៊ីង យឹងគួយ ហ្នឹង ហៅតាចាយ។ ហ្នឹងអ៊ំ ខៀវ សំផន លែងទៅហើយ។ អ៊ំ ប៉ុលពត គាត់ទៅម្តង។ រួចដើរទស្សនកិច្ចនៅស្រុកខ្មែរយើងហ្នឹង កន្លះខែ ចំនួនប្រហែលកន្លះខែ គ្រប់ភូមិភាគទម្រាំគាត់ទៅប្រទេសគាត់វិញ។ ប៉ុន្តែពេលហ្នឹង អ៊ំខៀវ សំផន លែងទៅទទួលហើយ អ៊ំ នួន ជា អីអត់បានជូនដំណើរដើរទស្សនកិច្ចតាមភូមិភាគអីៗទេ ហ្នឹងជម្រាបលោកមេធាវី។ ហើយអំមិញ លោកមេធាវីសួរថា តើពូបានធ្លាប់ឃើញនៅក្នុងបុណ្យខួប ១៧ មេសា។ ប្រហែលជាមុនហ្នឹងបន្តិច ប៉ុន្តែក្នុងពាក់កណ្តាលខែមេសា ហ្នឹង មានការបង្រៀនជាវគ្គនយោបាយ--

**ស៖** ឆ្នាំណាដែលបាទ ដែលពូត្រូវរៀនវគ្គនយោបាយ? ហើយរៀននៅឯណា? សូមបញ្ជាក់។

[១១:០៧:០០]

**ឆ៖** ការរៀនវគ្គនយោបាយរបស់ខ្ញុំហ្នឹង ដំបូងឡើយឆ្នាំ៧៥ ខ្ញុំមកដល់ភ្នំពេញចុងឆ្នាំហើយ គេឲ្យខ្ញុំទៅរៀននៅសាលាបច្ចេកទេសសូវៀត។ ត្រង់ហ្នឹងគេហៅសាលានយោបាយមជ្ឈិមដែរ ប៉ុនខ្ញុំមកដល់ដំបូង អាហ្នឹងគេឲ្យរៀននៅហ្នឹង។ បង្រៀនដោយសមមិត្តភុំ។ ដល់ទៅបានមួយឆ្នាំមកទៀត មួយឆ្នាំជាងមកទៀត បានបង្រៀនដោយ អ៊ំនួន និងអ៊ំ ខៀវ សំផន ហ្នឹងនៅសាលានយោបាយមជ្ឈិមដែរ នៅបុរីកីឡាហ្នឹង។ បាទ គាត់លើកឡើងអំពី--

**ស៖** បាទសុំទោស ខ្ញុំកាត់ពូ។ ខ្ញុំចង់ឲ្យពូបញ្ជាក់អ្នកដែលបង្រៀនពូឲ្យផ្សេងពីនេះ កុំឲ្យមានការច្រឡំគ្នាថាតើ នៅពេលនោះ ពូបានថាពូបានរៀនជាមួយលោក ខៀវ សំផន ក៏ធ្លាប់បានរៀនវគ្គនយោ-បាយ លោក នួន ជា ក៏ធ្លាប់បានរៀន។ អីចឹងសូមពូបញ្ជាក់ឲ្យដាច់ៗពីគ្នា ថាតើនៅពេលនោះ លោក ខៀវ សំផន បង្រៀនពូពីអ្វីខ្លះ? ហើយលោក នួន ជា បានបង្រៀនពូ--?

[១១:០៨:៣២]

**ឆ៖** នៅពេលហ្នឹង អ៊ំ ខៀវ សំផន ហ្នឹង និងអ៊ំ នួន ជា ហ្នឹងគាត់បានបង្រៀនពីរនាក់ហ្នឹង វគ្គហ្នឹង។ ហើយគាត់លើកឡើងអំពីប្រវត្តិតស៊ូរបស់បក្សកុម្មុយនីស្តកម្ពុជាយើងហ្នឹង។ បាទ តាំងពីទសវត្សរ៍ទី៣០ ទី៤០ ទី៥០ ទី៦០ រហូតមកដល់បច្ចុប្បន្ន។ បាទ គាត់លើកឡើងអីចឹង។ មានការលំបាកលំបិនក្នុងព្រៃអីៗ។

**ស៖** ហ្នឹងលោក នួន ជា ឬក៏លោក ខៀវ សំផន ដែលនិយាយពីរឿងទសវត្សរ៍៥០, ៦០ ដែលពូនិយាយអំមិញ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយៗ!

**លោក ស សារិន៖**

**ឆ៖** និយាយពីប្រវត្តិតស៊ូរបស់បក្សហ្នឹង។ ថាចលនាតស៊ូរបស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹងកើតមានតាំងពីឆ្នាំ៣០ មក តាំងពីសម័យចលនាតស៊ូវៃពួកអាណានិគមបារាំង មានអាចារ្យស្វា ពោធិ៍កំបោរ និងអ្នកតស៊ូជាច្រើនទៀត ខ្ញុំចាំឈ្មោះមិនអស់ទេ។ ដល់ក្រោយមក ក៏បារាំងធ្វើបាបចាប់សម្លាប់ចោលបង្ក្រាបអត់ឲ្យមានចលនាតស៊ូទេរហូតមកទសវត្សរ៍ទី៤០ជាងហ្នឹង មានចលនាតស៊ូខ្មែរឥស្សរៈអីហ្នឹង។ រហូតមកដល់ទសវត្សរ៍៥០ មានចលនាតស៊ូរវាងខ្មែរយើងហើយនិងខាងគេហៅយៀកមិញតស៊ូខ្មែរខាងយៀកមិញ ខាងវៀតណាមគេហៅខាងយៀកមិញ ខ្ញុំចាំអ៊ីចឹងពី ៤០ជាងហ្នឹង។ រួចមកដល់៥០ជាងហ្នឹងគឺការតស៊ូបដិវត្តន៍ហ្នឹងនៅក្រោមដូចថា ជាសហព័ន្ធឥណ្ឌូចិន ដែលមានវៀតណាមហ្នឹងគេនៅក្តោបក្តាប់ពីលើ។ ដល់អ៊ីចឹងខាងចលនាតស៊ូរបស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹងកើតទុក្ខមិនសុខចិត្តទេ ព្រោះវានៅក្រោមរបស់អំណាចវៀតណាមក៏មានការបង្កើតជាបក្សកុម្មុយនីស្តកម្ពុជាថ្មីហ្នឹងនៅឆ្នាំ៦០ ចុង៥៩-៦០ហ្នឹង។ បាទ គាត់លើកពីប្រវត្តិតស៊ូរបស់បក្សហ្នឹងកំសត់កម្រណាស់ កម្លាំងបក្សយើងមានពីមុនមកហ្នឹងក្រោយពីខ្មាំងបង្ក្រាបរួចតស៊ូឡើងជាថ្មីហ្នឹងមានគ្នាតែ៧នាក់ទេ។ រួចមកប្រជុំគ្នាហ្នឹងនៅរ៉ាវថទេះភ្លើង ខ្ញុំចាំអ៊ីចឹង រ៉ាវទេះភ្លើងហ្នឹងចំថ្ងៃភ្ជុំតែម្តង ដែលខ្មាំងវាអត់ចាប់អារម្មណ៍មនុស្សទាំងឡាយ គេទៅវត្តទៅវ៉ាអីភ្ជុំអស់ យើងដឹងប្រពៃណីខ្មែរយើង រួចអ៊ីចឹងបក្សយើងឆ្លៀតឱកាសថាថ្ងៃភ្ជុំហ្នឹងប្រជុំគ្នា ដែលជាបក្សធំៗមកពីជុំវិញតាមភូមិភាគនានា ជុំវិញប្រទេសហ្នឹង រួចដល់ទៅ ហ្នឹងប្រជុំ រួចអ៊ីចឹងបក្ស ខ្ញុំចាំបានអ៊ីចឹងទៀត បក្សៗ អ៊ីចឹងបក្សយកថ្ងៃភ្ជុំហ្នឹង យកថ្ងៃទី២៨ កញ្ញាហ្នឹងជាកំណើតរបស់បក្សកុម្មុយនីស្តកម្ពុជារហូតមកដល់សព្វថ្ងៃហ្នឹងបក្សយើងរីកធំធាត់បានប៉ុណ្ណឹង យ៉ាងលឿន យ៉ាងឆាប់រហ័ស។ បាទ ខ្ញុំចាំបានអ៊ីចឹងរហូតមកដល់ទៅយើងនៅនឹងភ្នំពេញហ្នឹងមិនបានទៀតរត់ទៅតស៊ូនៅក្នុងព្រៃ។

[១១:១៣:៣១]

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** បាទ ខ្ញុំកាត់ពូ។ ថាតើក្រៅពីលោក នួន ជា រៀបរាប់ពីប្រវត្តិតស៊ូបក្ស ថាតើគាត់មានផ្តល់

ជាគោលនយោបាយ ឬពាក់ព័ន្ធនឹងទ្រឹស្តីអប់រំអីផ្សេងៗទៀតទេ ដែលពូនៅចងចាំ?

**ឆ៖** ដោយៗមានភាពដូចថា រញ៉េចរញ៉ាចនៅក្នុងជួរបក្ស គាត់លើកឡើងថា បក្ខជនទាំងអស់ មិនថាបក្ខជនពីឆ្នាំ៤០ មិនថាបក្ខជនពីឆ្នាំ៥០ ឬក៏បក្ខជនឆ្នាំ៦០ ឬ ៧០ ឬបច្ចុប្បន្នហ្នឹងទេ យើងត្រូវតែកសាងខ្លួនឡើងជាថ្មីទាំងអស់ បក្ខជននៅក្នុងដំណាក់កាលបដិវត្តន៍ហ្នឹង។ ព្រោះមានច្របូកច្របល់ ដូចថានៅក្នុងជួរបក្សហ្នឹងមានអ្នកក្បត់ អង្គាល់ហ្នឹងគាត់និយាយអ៊ីចឹង។ ហើយចេះ ដូច្នេះត្រូវកម្ទេច និងបោសសម្អាត គាត់និយាយអង្កាល់ហ្នឹងបែរមុខទៅជើងអ៊ីចឹងមានពាក្យស្លោកកម្ទេច សេ.អ៊ី.អា អាមេរិក កា.ហ្សេ.បេ របស់សូវៀត និងខ្មាំងយួនវាតទីលេបទឹកដី និងខ្មាំងស៊ីរូងផ្ទៃក្នុង ហើយកម្ទេចនិងបោសសម្អាតពួក សេ.អ៊ី.អា អាមេរិកហ្នឹង ដែលមានពួកក្បត់ នល់ នល់, សិរិមតៈ, អ៊ិន តាំ, ចេង ហេង, ឡុង បូរ៉េត, សូស្តែន គាត់ថា បនក្បត់ទាំងប្រាំពីរហ្នឹង និងពួកបរិវារវា យើងក្រោយពី យើងដឹងស្ថានភាពខ្មាំងដែលប្រុងវ៉ៃយើងពីក្រោយខ្នងហ្នឹង នៅក្រោយរំដោះហើយហ្នឹង អ៊ីចឹងបក្សយើងបានដឹង គឺបក្សមានវិធានការកម្ទេចវាចូលមុន ដើម្បីកុំឱ្យពួកវាងើបប្រឆាំងយើងឡើងថ្ងៃក្រោយ។ ពួកខ្សែរយៈ សេ.អ៊ី.អា ហ្នឹង ដល់ទៅ -- មិនមាននៅសេសសល់នៅតាមទឹកដី ដូចថាទីជនបទ ដែលវានៅសល់តាមប្រជាជនជម្លៀស ១៧មេសា ហ្នឹងយើងត្រូវបោសសម្អាត ទៅតាមរយៈប្រជាជនហ្នឹងកុំឱ្យវាមានពួក គេហៅបនក្បត់ខ្សែរយៈខ្មាំងហ្នឹង។ សំដៅទៅលើ ហើយគាត់ចង់និយាយសំដៅទៅលើ បើទាហានប៉ូលិសហ្នឹង គេដឹងតែសម្លាប់ហើយ និងអ្នករដ្ឋការ។ អ្នករដ្ឋការខាងលន់ នល់ ហ្នឹង ត្រូវបោសសម្អាតទាំងអស់ហ្នឹង។ អាហ្នឹងចំពោះពួក សេ.អ៊ី.អា អាមេរិក និងខ្មាំងសត្រូវដែលទំនាស់ជាមួយ ជំទាស់ ដែលជាមួយបក្សកុម្មុយនីស្តកម្ពុជាយើង ដូចជាពួក គាត់លើកឡើងពួកនិស្សិត បញ្ញវន្តពួកផែនដីវិលអីៗអ៊ីចឹង។ ចំណុចហ្នឹង គាត់សួរទៀតថា មើល៍ មានសមមិត្តណាខ្លះថា ផែនដីវិលអីៗអ៊ីចឹង។ លើកដៃ ឱ្យលើកដៃអីៗ រួចអត់មានពីណាលើកដៃទេ តែគាត់លើកឡើងពីបញ្ហាហ្នឹង។

[១១:១៨:០៥]

**ស៖** តើក្រៅពីអ្វីដែលគាត់បានលើកឡើងពាក់ព័ន្ធនឹងការបោសសម្អាតខ្មាំងហ្នឹង ថាតើគាត់មានលើកពីវិស័យផ្សេងៗនៅក្នុងសង្គមឱ្យអ្នកចូលរួមបានដឹងដែរទេ គឺគាត់មានបានរៀបរាប់អំពីវិស័យផ្សេងៗខ្លះទេ?

**ឆ៖** គាត់បានលើកឡើងវិស័យផ្សេងៗទៀត ឧទាហរណ៍ ត្រូវមានប្រពៃណីយាមកាម និងលាក់ការណ៍បដិវត្តន៍បន្តទៅទៀត ទោះបីស្រុកយើងហ្នឹងសន្តិភាពក៏ដោយ។ គាត់ឱ្យមានការយាមកាម

តាមបណ្តាសហករណ៍នីមួយៗ អង្គភាពមួយៗ និងលាក់ការណ៍បដិវត្តន៍មិនត្រូវចង់ដឹង ចង់ឮការងាររបស់បុគ្គលដទៃដែល ឧទាហរណ៍ ខ្ញុំជូនភ្ញៀវទៅណា មកណាអ៊ីចឹង ឬមិត្តនៅក្នុងរួមការងារខ្ញុំ ជូនភ្ញៀវទៅណាមកណាអី យើងមិនត្រូវចង់ដឹង ចង់ឮកិច្ចការហ្នឹងទេ។ រួចសម័យនុំង តាមក្រុម តាមពួកនៅនឹងក្រុងហ្នឹង ក៏ដោយក៏នៅតែយាមអ៊ីចឹងដែរ។ ហើយនិងគាត់មួយទៀត គឺគាត់ឲ្យមានសញ្ជាតិតែមួយនៅលើទឹកដីយើងហ្នឹង។ ឲ្យមានសញ្ជាតិតែមួយហ្នឹងគឺសញ្ជាតិខ្មែរ។ គាត់លើកឡើងន័យត្រង់ហ្នឹង គាត់ថានៅលើទឹកដីខ្មែរយើងហ្នឹង មានសញ្ជាតិដល់ទៅ១៦ណោះ។ មានច្រើនណាស់ ខ្ញុំចាំអត់អស់ ចាំបានមានចាម មានក្លួយ រដែ សំរែ ព្នង ការ៉ែត ហើយស្ទៀងអ៊ីចឹងទៅ។ ប៉ុនដល់គាត់លើកឡើងថា ដោយខ្មែរហ្នឹងមានចរិតស្លូតបូតស្មោះត្រង់សុភាពរាបសា។ អ៊ីចឹងឲ្យមានសញ្ជាតិអីច្រើនទេ ឲ្យមានតែសញ្ជាតិខ្មែរហ្នឹងមួយទេ និងមិនឲ្យមានសាសនា។ អត់ឲ្យមានសាសនាអី សាសនាចាម សាសនាព្រះពុទ្ធ និងទំនៀមទម្លាប់បែបជនជាតិអ្វីទេ ព្រោះវាអត់ចំណេញអីដល់ការកសាងប្រទេស។ ន័យត្រង់ហ្នឹង។ រួចដូចជាវិស័យសិក្សាធិការអីហ្នឹង គាត់ឲ្យយើងរៀនត្រឹមម៉ាចេះសរសេរ ចេះអាន។ រៀនជាក់ស្តែង គឺរៀននៅកន្លែងណា ទៅរៀនកន្លែងនុំងតែម្តង។ ឧទាហរណ៍កុមារនៅជនបទ យើងរៀនផង យើងបង្កបង្កើនផលផងកុមារនៅទីក្រុង យើងរៀនផង យើងរៀនបច្ចេកទេសផង យើងរៀនគ្រឿងចក្រផង។ ឧទាហរណ៍នៅកន្លែង ដូចខ្ញុំខាងឡានអ៊ីចឹង កុមារតូចៗហ្នឹង ធ្វើអីអត់កើត-- អាឡូៗ! ឮទេ?

*(មានបញ្ហាបច្ចេកទេស)*

[១១:២២:៥១]

គាត់គឺគាត់ឲ្យនៅត្រង់ណា រៀនត្រង់នុំង។ រៀនបច្ចេកទេសបណ្តើរ រៀនអក្សរបណ្តើរ ឲ្យត្រឹមរៀន អត់មានឌីប្លូមសញ្ញាបត្រអីៗ បរិញ្ញាអីៗដូចរាល់ថ្ងៃទេ។ មិនដែលឮផងខ្ញុំកាលនុំង បរិញ្ញាបណ្ឌិតអីៗ ដែលឮត្រឹមបាក់អង បាក់ឌុបហ្នឹង។ បាក់ឌុបហ្នឹង ជាសត្រូវនឹងបដិវត្តន៍ហើយ ជាមុខសញ្ញានឹងបដិវត្តន៍ទៀត បាក់អង បាក់ឌុបហ្នឹង កាលហ្នឹង។ ត្រូវ គេត្រូវតាមដានហើយ អ្នកចេះៗអី សម័យហ្នឹងនោះ។

**ស៖** សុំ -- តើពូមានចាំពាក់ព័ន្ធនឹងពាក្យស្លោកដែលគាត់លើកបង្ហាញអី ពូមាននៅចាំបានពាក្យស្លោកក្នុងរបបនោះ ដែលថ្នាក់ដឹកនាំបង្ហាញ ពូជាពិសេស នួន ជា គាត់បង្ហាញពាក្យស្លោកពាក្យអីដែរទេបាទ?

**ឆ៖** គាត់មានបង្ហាញ និយាយពីរឿងពាក្យស្លោកប្តេជ្ញាបង្កបង្កើនផលស្រូវឲ្យបាន៣តោនក្នុង

១ហិកតា ទៅ៦តោនអីហ្នឹង។ ខ្ញុំចង់សង្ខេបការងារអំមិញបន្តិច។ វិស័យសិក្សាហ្នឹងវាពាក់ព័ន្ធជាមួយវិស័យកីឡា ហើយគាត់លើកឡើងអំពីវិស័យកីឡាហ្នឹង។ គាត់ថាបក្សយើងមិនមានកីឡាអ្វីបញ្ជូនទៅប្រកួតនៅអន្តរជាតិទេ។ កីឡាយើងគឺកីឡាបង្កបង្កើនផល បាទវិស័យហ្នឹង។ ហើយវិស័យសង្គមកិច្ចអីហ្នឹង យើងត្រូវខិតខំស្រាវជ្រាវរកឱសថបូរាណទៅតាមបណ្ដាលសហករណ៍នីមួយៗហ្នឹង បែបបូរាណដូចបុព្វបុរសយើងពីអតីតកាលមកហ្នឹងមានឱសថបូរាណហ្នឹងទេ។

[១១:២៥:០៥]

រួចចំពោះពាក្យស្លោក ចំពោះពាក្យស្លោកពីរគាត់លើកឡើងអ៊ីចឹង ប្ដេជ្ញាបង្កបង្កើនផលឲ្យបានពី៣តោន ទៅ៦តោនអ៊ីចឹង។ ប្ដេជ្ញាដាំៗកុំឲ្យមានសល់ដីមួយចង្អាមអ៊ីចឹង ពាក្យនៅសុទ្ធពេញហ្នឹងគាត់បង្រៀន និយាយទៅមើលទៅតាមពាក្យស្លោកហ្នឹងបាទ។

**ស៖** ពូនៅចាំទៀតទេពាក់ព័ន្ធនឹងលោក នួន ជា ដើម្បីខ្ញុំចូលទៅលោក ខៀវ សំផន តែម្ដង ក៏នៅចាំសម្ដីអីដែលគាត់បានអះអាង លើកបញ្ជាក់បានទេ ឬក៏ខ្ញុំ -- ពូអស់ហើយ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**លោក ស សារិន៖**

**ឆ៖** គាត់លើកឡើងអំពីខ្មាំងខ្ញុំរាប់មើលទៅមានបួន អំមិញហ្នឹងខ្ញុំនិយាយបានត្រឹមបន្តិចខាងខ្សែរយៈ សេ.អ៊ី.អា នៅកា.ហ្សេ.បេ។ បាទ កា.ហ្សេ.បេ ហ្នឹងសំដៅពីលើអ្នកមកពីវៀននៅសហភាពសូវៀតនិងពីភាគខាងជើងរបស់វៀតណាមបាទ ដែលត្រូវមុខសញ្ញាបក្សយើងត្រូវបោសសម្អាតពួកខ្មាំងអស់ទាំងហ្នឹង។ កាលជំនាន់ហ្នឹងឲ្យតែមកពីភាគខាងជើង គឺអត់មានទេ ភាគច្រើននៅមន្ទីរខ្ញុំអ្នកភាគខាងជើងអីអត់មានសោះ មកពីវៀតណាមមកពីសូវៀតពីអីហ្នឹង គេបោសសម្អាតអស់ហើយបាទ។ រួចគាត់លើកឡើងអ៊ីចេះទៀត គាត់ថាអំពីខ្មាំងមួយទៀត គឺខ្មាំងសីលធម៌ទី៦។ ខ្មាំងសីលធម៌ទី៦ ហ្នឹងគាត់សំដៅទៅលើអ្នកនៅដឹកនាំនៅជាមួយបក្សហ្នឹងគឺមាន ឈ្មោះ កុយ ឃួន ហៅ ធុច អតីតហ្នឹងគាត់មកពីភូមិភាគកណ្ដាល ហើយភូមិភាគឧត្ដរ ក្រោយមកៗនៅពាណិជ្ជកម្ម។ ដល់រួចគាត់មានសេចក្ដីស្នេហាជាមួយនារីសិល្បៈម្នាក់ហ្នឹង ដល់អ៊ីចឹងទៅបែកការណ៍ ដល់បែកការណ៍អ៊ីចឹងទៅដូចជារៀបការឲ្យនីរសារឯងអ៊ីចឹងកាលហ្នឹង។ ឈ្មោះ ខ្ញុំនៅចាំឈ្មោះៗ មិត្តឡុង អ៊ីចឹងហើយយ៉ាង។ រួចដល់អ៊ីចឹងទៅបែកការណ៍អ៊ីចឹងទៅក៏ កុយ ធួន ហ្នឹងយក មិត្តឡុង ហ្នឹងទៅសម្លាប់ចោល។ ដល់ដឹងៗដល់បក្សយើង

ហ្នឹង បក្សយើងហៅសួរទៅ ថាគាត់ហ្នឹងទៅលេងផ្ទះ រួចអត់មានទៅលេងផ្ទះណា កុយ ធួន យកទៅសម្លាប់ចោល។ ដល់រួច កុយ ធួន ហ្នឹងមានវិធានការក្បត់ប្រុងសម្លាប់ ប៉ុល ពត យកអំណាច។ បាទ ក្នុងឯកសារគាត់ហ្នឹងគាត់លើកឡើងអ៊ីចឹង។ ដល់អ៊ីចឹងគាត់កំណត់ថាអ្នកខុសសីលធម៌ទី៦ បុគ្គលណាក៏ដោយពីថ្ងៃហ្នឹងទៅ ឲ្យអ្នកខុសសីលធម៌ទី៦ ហ្នឹងចាត់ទុកជាជនក្បត់ ដែលស្ដែងចេញពីការស្រលាញ់គ្នាហ្នឹងយូរៗទៅមានគំនិតក្បត់បក្សឯង។ រួចដល់អ៊ីចឹងគាត់លើកឡើងទៀត គាត់ថាមានសមមិត្តណាខ្លះមើលដែលពាក់ព័ន្ធជាមួយជនក្បត់ហ្នឹង។ ជនក្បត់ហ្នឹងមានច្រើនកាលហ្នឹង មិនមែនតែ កុយ ធួន ហ្នឹងមួយទេ មានសមមិត្ត ឌឿន។ សមមិត្ត ឌឿន ហ្នឹងនៅគាត់ជាគណៈមន្ទីរ៨៧០ ហ្នឹងដែរ។ គ្រប់គ្រងនៅកន្លែងមន្ទីរមជ្ឈិមបក្សហ្នឹងដែរ និងសមមិត្តសុត មួយនៅអីតំបន់១០៦ សៀមរាប ឧត្ដរមានជ័យហ្នឹងមួយដែរ និង ចាន់ចក្រី មេទ័ពបូព៌ាហ្នឹងមួយដែរ។ បាទ ជាប្រព័ន្ធអ៊ីចឹង។ រួចគាត់បានលើកឡើងថាប្រសិនជាសមមិត្តណាមានពាក់ព័ន្ធនៅក្នុងខ្សែរយៈពួកក្បត់ហ្នឹងត្រូវសារភាពជូនបក្ស ព្រោះបក្សយើងជាម៉ែ បក្សយើងហ្នឹងជាឪ។ បើសមមិត្តណាដែលមិនយល់ពីទោសកំហុសរបស់ខ្លួនហ្នឹង បក្សយើងមិនយកទោសពៃរ៍អ្វីទេ បក្សយើងលើកលែងទោសឲ្យហើយ។ ប្រសិនបើសមមិត្តណាលាក់ ហើយបក្សយើងរកឃើញ បក្សយើងនឹងអនុវត្តនយោបាយជីកស្មៅអស់ទាំងឫសហើយ។ អាហ្នឹងអ៊ីចឹងគាត់ថាមើលមានមិត្តណាខ្លះមានពាក់ព័ន្ធអ៊ីចឹង ឲ្យលើកដៃ ដល់ពេលលើកវាច្រើនពេលសរសេរបានតែបីបួននាក់ ពីរបីនាក់អ៊ីចឹងណោះ គាត់ថាចាំដាក់ក្នុងជីវទស្សន៍ទៅ បើម្នាក់ៗស្មោះត្រង់នឹងបក្ស សម័យនុ៎ង។ ឃើញលើកនោះ វាច្រើនដែរប្រហែលចង់ដប់ ប្រាំដណ្ដប់ភាគរយហ្នឹងមួយស្អាត ពាក់ព័ន្ធជាមួយខ្សែរយៈក្បត់ហ្នឹង ក្បត់ កុយ ធួន អីមិនដឹងៗទេ។

[១១:៣១:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀល សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក ហើយរួមទាំងសម្របសម្រួលជាមួយនឹងអង្គភាពវីស្ទិ និងពេទ្យប្រចាំការផង ដើម្បីពិនិត្យមើលសុខភាពរបស់គាត់ នៅក្នុងអំឡុងពេលឈប់សម្រាក

និងឲ្យបានមុនពេលចូលមកចាប់ផ្ដើមសវនាការនៅរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣២ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:១៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនផងភាគីផងដែរថា តាមរបាយការណ៍របស់គ្រូពេទ្យ ដែលប្រចាំការនៅ អ.វ.ត.ក ហ្នឹងបានពិនិត្យសុខភាពរបស់លោក ស សារិន រួចហើយ មុនពេលចូលសវនាការនេះ ថាគាត់មានសុខភាពល្អធម្មតាទេ ប៉ុន្តែទោះបីយ៉ាងនេះក្ដី លោក ស សារិន ប្រសិនបើលោកមានបញ្ហាអាការៈមិនស្រួលខ្លួន ដែលទំនងតាមកត់សម្គាល់របស់លោកថា អាចនឹងមានបញ្ហាកើតឡើងអំពីបញ្ហាសុខភាពរបស់លោកនោះ លោកអាចប្រាប់មកយើង ដើម្បីយើងផ្អាកសវនាការ ហើយលោកអាចធ្វើការពិនិត្យ ឬក៏ធ្វើការសម្របសម្រួល ដើម្បីឲ្យសភាពសុខភាពរបស់លោកអាចប្រព្រឹត្តទៅបាន កុំខ្លាចរអែងអី។

បាទ ជាបន្តទៅនេះ ផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារ -- នាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះ ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន។

**លោក វ៉ែន ពៅ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** បាទ ពូពីព្រឹកមិញ ពូបានឆ្លើយរួចហើយពាក់ព័ន្ធនឹងវគ្គអប់រំរៀនសូត្រ ដែលពូបានចូលរួមផ្ទាល់ ហើយពូបានរៀបរាប់ពាក់ព័ន្ធនឹងលោក នួន ជា។ តែពេលនេះ ខ្ញុំចង់សួរពូពាក់ព័ន្ធនឹងលោក ខៀវ សំផន វិញម្ដង ថាតើពូនៅនឹកឃើញ ឬចងចាំបាននៅអ្វីខ្លះដែលលោក ខៀវ សំផន បានអប់រំបង្រៀនពូ

នៅពេលនោះ?

**លោក ស សារិន៖**

**ឆ៖** បាទ ចំពោះលោកអ៊ំខៀវ សំផន គាត់លើកឡើងកាលពីបង្រៀននោះ គាត់លើកឡើងតាមខ្ញុំនៅចាំ គឺលើកអំពីវិនាសសកម្មរបស់ចក្រពត្តិអាមេរិក ដែលបង្កវិនាសសកម្មមកលើទឹកដីកម្ពុជាប្រជាធិបតេយ្យនាក្នុងសង្គ្រាម៥ឆ្នាំហ្នឹង គឺចំនួន៣០០យប់ ៣០០ថ្ងៃហ្នឹង បេ៥២ហ្នឹងចាក់រហូត។ រួចបើគិតជាតោនហ្នឹង អស់៥៦លានតោនណោះ គាត់លើកឡើងអ៊ីចឹង តាមខ្ញុំចាំ។ រួចគាត់ថា ចែកនឹងប្រជាជន៧លាននាក់ ប្រជាជនយើងម្នាក់ៗហ្នឹង ត្រូវទទួល៧តោនគ្រាប់ ៨តោនគ្រាប់ម្នាក់។ អាហ្នឹង គាត់លើកឡើងរឿងវិនាសកម្មពីសម័យសង្គ្រាម ហើយឲ្យយើងប្តេជ្ញាការពារព្រំដែនទាំងបី ទាំងជើងគោក ទាំងព្រំដែនជើងអាកាស ទាំងព្រំដែនជើងទឹក ឲ្យបានគង់វង្ស និងបន្តកសាងប្រទេសតទៅទៀត។ ហើយគាត់លើអំពីរឿងជម្លោះរវាងខ្មាំងយួនវាតទីលេបទឹកដី។ មិនមែនហៅវៀតណាមៗអ៊ីចឹងទេ សម័យនុ៎ងនោះ។ គាត់ថាពួកគាត់ខ្មាំងយួនហ្នឹងបានបង្កវិនាសកម្មរហូត តាំងពីកន្ទុយនាគមកដល់ងៀងសន្ទូច តាំងពីងៀងសន្ទូចហ្នឹងទៅដល់ឆ្នេរសមុទ្រ។ មានការប្រយុទ្ធគ្នាជាហូរហែពីសម័យហ្នឹង។ គាត់លើកឡើងពីជម្លោះផ្ទៃក្នុងរបស់យួនហ្នឹង ជម្លោះដណ្តើមកម្មសិទ្ធិគ្នាក្រោយពីថ្ងៃទីរំដោះ ៣០ មេសា ហ្នឹង អត់មានសន្តិភាពអីដូចកម្ពុជាយើងទេ។ គាត់ថាជម្លោះ វាដណ្តើមគ្នាផ្នែកកម្មសិទ្ធិឯកជនហ្នឹងតាំងពីអ៊ីចឹងៗ គាត់ចង្អុលទៅកង្ហារ ទៅផ្ទះសម្បែង ដណ្តើមគ្នាជម្លោះកម្មសិទ្ធិឯកជនហ្នឹង។ រួចសព្វថ្ងៃហ្នឹងពួកខ្មាំងយួនវាតទីលេបទឹកដីហ្នឹង កំពុងតែអត់ ជួបប្រទះនឹងការអត់ឃ្លាន ខ្វះស្បៀង រដ្ឋាភិបាលយួន បន ឡេយន់, ផាំ វ៉ាន់ ដុង ហ្នឹងលើកដៃសំពះអន្តរជាតិដើម្បីសុំជំនួយ។ អាហ្នឹងជម្លោះជាមួយវៀតណាមហ្នឹង ហើយនិងគាត់លើកពីរឿងវៀតណាមហ្នឹង ខ្មាំងយួនហ្នឹងច្រណែននឹងយើង គ្រាន់តែយើងនឹងវ៉ៃរំដោះមុនបានមុនថ្ងៃ១៧ មេសា ហ្នឹង ក៏គេច្រណែននឹងយើង។ គ្រាន់តែទៅប្រជុំនៅសន្និសីទប្រទេសមិនចូលបក្សសម្ព័ន្ធនៅកូឡុំបូហ្នឹង ក៏ៗច្រណែននឹងយើង ដោយមានលោកស្រី អាន់តារា គន្ធី ដែលជាប្រធានាធិបតីនៃប្រទេសស្រីលង្កាហ្នឹង គេឲ្យយើងធ្វើជាប្រធានអង្គប្រជុំហ្នឹង ក៏ច្រណែនយើងដែរ។ តាំងពីអាអ៊ីចឹងៗឡើងទៅ។

[១៣:៣៨:២៧]

រួចកាលហ្នឹង-- ហេឡូ! កាលហ្នឹងគាត់លើកឡើងទៀតអំពីឲ្យបក្សយើងល្អាសវ៉ៃ នៅឆ្នាំ៧៣ ប្រហែលជាដើមឆ្នាំ៧៣ហ្នឹង មានកិច្ចព្រមព្រៀងឈប់បាញ់មួយនៅទីក្រុងប៉ារីសហ្នឹង រវាងអាមេរិក

---

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

និងឥណ្ឌូចិនយើងហ្នឹង និងឥណ្ឌូចិនហ្នឹង ដែលឈប់ឲ្យប្រយុទ្ធគ្នាហ្នឹង តែកម្ពុជាយើងនៅតែដាច់ខាតប្រយុទ្ធ អត់មានចរចាទេ។ ដល់អ៊ីចឹងលុះត្រាណាតែបានជ័យជម្នះថ្ងៃ១៧ មេសា ហ្នឹង។ ហើយម្យ៉ាងទៀតបក្សយើងឈ្លាសវៃ នៅពេលនោះបានជម្លៀសប្រជាជនវៀតណាមហ្នឹងចេញអស់ អត់មានឲ្យនៅសល់ទេ តាំងពីដងទន្លេសាប តាំងទន្លេមេគង្គ តាំងពីនៅតាមចម្ការកៅស៊ូហ្នឹង បណ្ដេញអ្នកឯងទៅស្រុកវិញអស់។ ហើយគាត់លើកឡើងអំពីខ្មាំងយួនហ្នឹង វាពូកែបង្កាត់ពូជសាសន៍ណាស់។ ធ្វើឲ្យដូចថា ប្រុសហ្នឹងយកប្ដីយួន ស្រីហ្នឹងយកៗប្រពន្ធយួន ស្រីហ្នឹងយកប្ដីខ្មែរ ប្រវត្តិសាស្ត្រពួកវាហ្នឹង។ បើអ៊ីចឹងទេឥឡូវកុំសូម្បីឡើយតែកូនយួន ចៅយួនហ្នឹងក៏យើងត្រូវបោសសម្អាត អត់ឲ្យមាននៅទេ។ ហ្នឹងចំពោះខ្មាំងយួនហ្នឹង គាត់លើកឡើងអ៊ីចឹង។

រួចពីហ្នឹងទៅក៏គាត់លើកឡើងពីរឿងជំនួយៗបក្សយើង អត់មានទទួលជំនួយពីបរទេសទេ មិនលើកដៃសំពះសុំដូចពួកអាខ្មាំងយួនទេ យើងប្រកាន់នូវគោលជំហរឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ទោះបីយើងចប់ ទើបនឹងចប់សង្គ្រាមជួបប្រទះនឹងខ្វះ ការខ្វះស្បៀង ខ្វះសព្វ ខ្វះគ្រប់ក្ដី ក៏យើងដាច់ខាតត្រូវតែតស៊ូអត់មានទទួលជំនួយពីបរទេសទេ។ រួចគាត់ថាទៀតលើកពីរឿង ថាបើយើងទទួលជំនួយ វាមិនមែនត្រឹមតែមកត្រឹមជំនួយទេ វាមកតាំងពីអា សេ.អ៊ី.អា, វាមកតាំងពីអា កា.ហ្សេ.បេ អ៊ីចឹងយើងអត់មានទទួលជំនួយពីៗៗបរទេសទេ អាហ្នឹងន័យត្រង់ហ្នឹង ខ្ញុំនៅចាំគាត់បង្រៀនអ៊ីចឹង។

[១៣:៤១:៣៦]

ហើយនិងរឿងមិនចាយលុយ។ ថាបក្សយើងបន្តការមិនចាយលុយហ្នឹងតទៅទៀត ព្រោះកាលណាចាយលុយទៅធ្វើឲ្យខ្មាំងហ្នឹងទិញទឹកចិត្តបាន ការចាយលុយហ្នឹង។ រួចឧទាហរណ៍ត្រូវការចំណាយបេឡាប៉ុន្មាននាក់ គណនីហ្នឹងប៉ុន្មាននាក់ សម័យហ្នឹងខ្ញុំអត់ដឹងថាបេឡា គណនីហ្នឹងគេធ្វើអីផង អត់ធ្លាប់ៗឆ្លងកាត់រៀនដឹងអី មានប្រាក់ខែ បេឡាគេអ្នកបើកអីផង ខ្ញុំអត់យល់ ប៉ុនចំណាំពាក្យគាត់ហ្នឹងនិយាយនេះ គាត់ថា រួចចុះបើមួយប្រទេសហ្នឹង វាត្រូវចំណាយអាបេឡាហ្នឹង អាគណនីហ្នឹងអស់ប៉ុន្មាននាក់ វាត្រូវបើយើងយកកម្លាំងនៅហ្នឹងទៅបង្កបង្កើនផលបានច្រើន វាអត់មានខាត អ៊ីចឹងបក្សយើងអត់មានឲ្យចាយលុយទៀតទេ។

**ស៖** បាទ សូមអរគុណ។ ចុះពាក់ព័ន្ធនឹងបញ្ហាគ្រួសារ ឬក៏អាពាហ៍ពិពាហ៍ តើលោកចាំថាគាត់មានបានលើកឡើងពីបញ្ហានេះដែរទេបាទ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**លោក ស សារិន៖**

**ឆ៖** ពីបញ្ហារៀបចំគ្រួសារហ្នឹងក៏គាត់លើកឡើងដែរ គាត់លើកឡើងអំពីយើងត្រូវប្ដេជ្ញាបង្កបង្កើនផលឲ្យបានពី ៣តោន ទៅ៦តោនក្នុង១ហិកតាហ្នឹង។ ហ្នឹងគឺមានកត្តាប្រាំបីជាចម្បង៖ ទី១ ទឹក, ទី២ ដី, ទី៣ហ្នឹងពូជ យើងត្រូវខំកែច្នៃវត្ថុធាតុដើមយើងមានដីធម្មជាតិ ដីលេខ១ហ្នឹង ដីដំបូកអីៗ ដីបាតបឹងអីៗយកមកកែច្នៃអីរឿងហ្នឹងឲ្យបាន ហើយពី១០ ទៅ១៥ឆ្នាំហ្នឹង -- ពី ៥ ទៅ១០ឆ្នាំហ្នឹង យើងត្រូវឈានធ្វើឲ្យបានពីកសិកម្មទៅកសិកម្មទំនើប ពី៥ទៅ១០ឆ្នាំហ្នឹង។ ហើយ១៥ទៅ២០ឆ្នាំហ្នឹង ត្រូវឲ្យឈានឡើងដល់ទៅដល់ឧស្សាហកម្មទំនើប។ ទន្ទឹមនឹងនេះ គាត់និយាយពាក់ព័ន្ធពីរឿង ដល់អ៊ីចឹងវាពាក់ព័ន្ធពីរឿងមនុស្ស ធនធានមនុស្សបាទ។ បក្សយើងត្រូវការប្រជាជន បង្កើនប្រជាជនហ្នឹងឲ្យបាន១០ ទៅ១៥លាននាក់រយៈពេល ៥ទៅ១០ឆ្នាំហ្នឹង។ អ៊ីចឹងៗយើងត្រូវរៀបការជាសមូហភាព បាទ រៀបការជាសមូហភាព ហើយការរៀបការជាសមូហភាពនេះទៀត គឺនារីហ្នឹងមានអាយុពី២០ឆ្នាំឡើងទៅ ហើយយុវជនហ្នឹងអាយុ២៥ឡើងទៅ បានឲ្យរៀបការ។ តែរៀបការជាសមូហភាព បាទ អត់មានដើរទៅស្រលាញ់ឯណាបានតាមចិត្តទេ ចាំបក្សយើងរើសឲ្យបាទ ចាំបក្សយើងរើសឲ្យអត់មានដើរទៅយកឯណាឯណីតាពីសតាពាស ព្រោះអ្វី? គាត់លើកឡើងអ៊ីចឹងថា ព្រោះខ្លាចមិត្តនារីហ្នឹងកើតមានប្រវត្តិកើតឃ្លង់បាទ ខ្លាចបុរសហ្នឹងមានប្រវត្តិកើតឃ្លង់ កើតជំងឺរបេង ឬមួយពាក់ព័ន្ធជាមួយខ្សែរយៈក្បត់អ៊ីចឹងនាំឲ្យសមមិត្តម្នាក់ៗអត់មានអនាគត។ បាទ ហ្នឹងគាត់ឲ្យរៀបការហ្នឹងជាសមូហភាព ហើយគាត់ឧទាហរណ៍ត្រង់នេះអ៊ីចេះបន្តិចទៀតខ្ញុំនៅចាំ។ គាត់ថា ឧទាហរណ៍ដូចកាលពីសង្គមចាស់ ចំពោះបញ្ហារៀបការហ្នឹងអ្នកខ្លះហ្នឹងក្រទេ រួចឃើញគេមានហ្នឹងរៀបចំការកូនហីកប៉ាក់កក្រឹកកក្រេងអ៊ីចឹងទៅ រួចដល់ទៅអ្នកក្រហ្នឹងចង់ការកូនធ្វើដូចគេអ៊ីចឹងដែរ។ រួចទីបំផុតជំពាក់គេអស់ លក់គោលក់ក្របីលក់ស្រែលក់ចំការដោយសារអាពាហ៍ពិពាហ៍ហ្នឹង។ អ៊ីចឹងសម័យយើងៗអត់ធ្វើអ៊ីចឹងទេ យើងត្រូវរៀបការជាសមូហភាព ដើម្បីកុំឲ្យវាខាត។ បាទ រួចអ៊ីចឹងទៅគាត់លើកឡើងអំពីការកសាងប្រទេសហ្នឹង យើងត្រូវឈរលើបដិវត្តវណ្ណៈអធន បាទបុគ្គលម្នាក់ៗហ្នឹងត្រូវបំពាក់នៅជំហរ គោលជំហរសមូហភាពវណ្ណៈអធនហ្នឹង ដើម្បីបន្តធ្វើបដិវត្តន៍សង្គមនិយម ឲ្យមានល្បឿនមហាលោតផ្លោះ មហាអស្ចារ្យហ្នឹងបាទ។

[១៣:៤៧:៤៣]

**ស៖** បាទ សូមអរគុណ។ ពូនៅចងចាំអ្វីទៀតទេ ក្រៅពីអ្វីដែលពូបានលើកឡើងពាក់ព័ន្ធនឹង

រឿងការសន្សំសំចៃ ក៏ដូចជាសីលធម៌វិន័យអីដែរទេបាទ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**លោក ស សារិន៖**

**ឆ៖** ខ្ញុំនៅចាំបានអីចេះ បញ្ហាសន្សំសំចៃនេះ គាត់និយាយចង់មួយកំណាត់ល្អិច។ គាត់ថាយើងត្រូវចេះសន្សំសំចៃ តាំងពីកូនដែកគោលតូចមួយឡើងទៅ បើសមមិត្តយើងម្នាក់ៗដើរទៅឃើញរើសបាននៅត្រង់ណា យើងរើសយកមកដាក់ម៉ុទៅជាកម្ទេច។ ឧទាហរណ៍នៅតាមជនបទ តាមសហករណ៍មានចបចាស់ៗ កាំបិតពូថៅចាស់ៗ កម្ទេចកម្ទីដែកចាស់ៗ យើងប្រមូលវាមកដាក់ម៉ុ ដាក់មួយគំនរទៅ។ រួចបើសមមិត្តនៅក្នុងទីក្រុង មានបាឡុង មានដែកគោល មានដែកអីក៏ដោយ ឲ្យតែថាដែកយើងមកៗដាក់មួយម៉ុទៅ យើងមើលពីតាំងពីរឿងអីចឹងតូចៗទៅ។ បាទរួចយើងយកទៅស្លដាដែកនេះទៅ ក៏កើតជារបស់អ្វីមួយទៅអីចឹងដែរ។ បាទ រួចគាត់លើកឡើងថា បើសិនជាយើងនឹងជីករ៉ែទម្រាំបានវាយកមកស្លស្លហើយនិងទម្រាំបានកែឲ្យកើតជាដែកហ្នឹង គឺថាយើងត្រូវចំណាយវត្ថុធាតុហ្នឹងអ្វីខ្លះ ចំណាយច្រើនណាស់ទម្រាំបានកើតជាដែកមួយដុំ។ គាត់លើកឡើងសន្សំពីៗៗរឿងការងារសន្សំសំចៃហ្នឹងអីចឹងបាទ។

[១៣:៤៩:៤៩]

រួចលើកឡើងពីរឿងសន្សំសំចៃមួយទៀត ឧទាហរណ៍ ទៅតាមសហករណ៍នីមួយៗ ទៅតាមសហជីពនីមួយៗ ទៅតាមអង្គភាពទ័ពនីមួយៗ យើងត្រូវបំពាក់នូវគោលជំហរមាគ៌ាសន្សំសំចៃ ផ្ចិតប្រឹតហ្នឹង រួចឧទាហរណ៍អ្នកដាំបាយ គាត់លើកឡើងពីរឿងអ្នកដាំបាយ ត្រូវចេះសន្សំសំចៃតាំងពីផ្លែកប្រហុក។ លោកមិនត្រូវលើកពីអាពាងធំមកហូបទេ ត្រូវលើកលូកពីពាងធំហ្នឹងមកដាក់ពាងតូចមកដាក់ក្រឡតូច យើងកុំខ្ជះខ្ជាយ រួចអ្នកដាំបាយហ្នឹងទៀតត្រូវចេះកែច្នៃ កុំស្លហ្នឹងដដែលៗ ថ្ងៃហ្នឹងស្លម្ជូរទៅថ្ងៃស្អែកហ្នឹងស្លកកូរអីចឹងទៅ ថ្ងៃខានស្អែកហ្នឹងសម្លស្ងោរ សម្លឆាអីចឹងទៅ។ មានបាយហ្នឹងមួយមុខទៅ មានសម្លហ្នឹងមួយមុខទៅ មានទឹកត្រីហ្នឹងមួយមុខទៅ។ ចំត្រង់ហ្នឹង ខ្ញុំចាំតែរាប់ដែរហ្នឹង ព្រោះនឹកឃ្លានបាយផងកាលហ្នឹង រាប់ទៅគាត់ថាបីមុខហ្នឹង ធ្វើម៉េចបានបីមុខអីចឹង។ បាយក៏គាត់រាប់មួយមុខទឹកត្រីក៏គាត់រាប់មួយមុខ សម្លរាប់មួយមុខ អីចឹងបានយើងទូទាំងប្រទេសយើងវា យើងដឹងស្រាប់ហើយខ្មែរទាំងអស់គ្នានេះជួបប្រទះនឹងការអត់ឃ្លាន ដោយគាត់យកគោលជំហរវណ្ណៈអធន ដោយយកវណ្ណៈកសិករកណ្តាលថ្នាក់ក្រោម និងកណ្តាលកសិករក្រហ្នឹងជាមូលដ្ឋាន ជាចម្បងហ្នឹង។ អីចឹងតាមនេះ

នីមួយៗគេអនុវត្តទៅតាមហ្នឹង ដល់អ៊ីចឹងយើងវាត្រូវជួបការអត់ឃ្លាន ទោះបីខ្ញុំនៅកន្លែងឡាន ក-១២ ហ្នឹងក៏ដោយ។ ឲ្យតែខែ៩ ខែ១០ឡើង បបរឈ្នោលហើយ បានឆ្អែត បានឆ្ងាញ់តែពេលណាទៅដឹកភ្ញៀវ ភ្ញៀវទៅកំពង់សោម ទៅកំពង់ចាមក៏ដោយ ខាងផ្ទះលេខ៥ គេដាក់បាយមួយស្រាក់ៗឲ្យកាលហ្នឹង យើងអត់មានផ្សារមានអីទេ។

[១៣:៥២:៤៧]

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** បាទ សូមអរគុណពូ។ ពូបានរៀបរាប់មកច្រើនដែរហើយ ពាក់ព័ន្ធនឹងវគ្គអប់រំរៀនសូត្រពីគោលនយោបាយនេះ។ ខ្ញុំចង់សួរពូមួយទៀតពាក់ព័ន្ធនឹងពូធ្លាប់បាននិយាយថា ពូធ្លាប់បានចូលរួមអបអរសាទរខួបអនុស្សាវរីយ៍ជ័យជម្នះ។ ពូនៅចាំទេនៅឆ្នាំណា? ហើយនៅកន្លែងណាពូចូលរួមនៅពេលណាដែរ ពូអាចបញ្ជាក់បានទេ?

**ឆ៖** កាលចូលរៀនហ្នឹង រៀនអ៊ីចេះ រៀនប្រហែលមើល មុន១៧ មេសា ហ្នឹងខ្ញុំរៀនជាមួយអ៊ំទាំងពីរហ្នឹងមួយសាទៅ ដល់តែក្រោយវគ្គក្រោយប្រហែលខែ៧ ចុងប្រហែលខែ៧ ហ្នឹងមួយសាទៀតទៅ។ បានថាអ៊ីចឹង--

**ប្រធានអង្គជំនុំ៖**

លោកៗស្ដាប់សំណួរអត់យល់ទេ ស្ដាប់សំណួរឲ្យបានសិនណ៎ះ! សួរបំណងសួរចូលរួមនៅក្នុងពិធីអបអរសាទរជ័យជម្នះ ប្រហែលទំនងជ័យជម្នះ១៧ មេសា។ ស្ដាប់សំណួរឲ្យបានសិន តែអ៊ីចឹងឆ្លើយប្រាសចាកនឹងសំណួរហើយ មិនឆ្លើយតបនឹងសំណួរដែលសួរទេ ណ៎ះ! លោកមេធាវីសួរសំណួរគាត់សាជាថ្មីម្ដងទៀត ដើម្បីគាត់ស្ដាប់សំណួរលោកយល់ ហើយឆ្លើយតបទៅនឹងសំណួរបាន។

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** ខ្ញុំចង់សួរពូអ៊ីចេះ ព្រោះពូបានបញ្ជាក់មកច្រើនហើយពាក់ព័ន្ធនឹងវគ្គអប់រំរៀនសូត្រជាមួយលោក នួន ជា និង ខៀវ សំផន។ តែនៅក្នុងឯកសារលោកក៏បានធ្លាប់បញ្ជាក់ដែរថា លោកពូធ្លាប់ចូលរួមអបអរសាទរខួបអនុស្សាវរីយ៍។ ខ្ញុំចង់សួរថា តើពូចូលនៅឆ្នាំណា? នៅកន្លែងណា? ពូនៅចងចាំបានទេពាក់ព័ន្ធនឹងការចូលរួមអបអរសាទរជ័យជម្នះ១៧ មេសា នោះ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01377281



[១៣:៥៤:៣៨]

**លោក ស សារិន៖**

**ឆ៖** បាទ នៅនឹងបុរីកីឡាហ្នឹង លោកប្រធាន។

**ស៖** ឆ្នាំណាដែរពូ ឆ្នាំណា ខែណាពូអាចនឹកឃើញចាំបានទេ?

**ឆ៖** ឆ្នាំ៧៧ ហ្នឹង។

**ស៖** តើនៅពេលនោះ ពូបានចូលរួម តើពូបានសង្កេតឃើញមានថ្នាក់ដឹកនាំណាខ្លះដែលចូលរួមនៅខួបអបអរសាទរនោះនៅឆ្នាំ៧៧ ដែលពូថានោះ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**លោក ស សារិន៖**

**ឆ៖** មួយវគ្គហ្នឹងមានអ៊ំ អ៊ំទាំងពីរហ្នឹងគាត់អ្នកបង្រៀនហ្នឹង។ បាទ ដូចខ្ញុំលើកឡើងនៅក្នុងឯកសារហ្នឹង ពីកន្លងមកហ្នឹង។

**សួរដោយលោក វ៉ើន ពៅ៖**

**ស៖** អ៊ីចឹងបានន័យថា វគ្គអប់រំហ្នឹង គឺដដែលទេ ឬក៏មានប្រធានបទផ្សេងៗគ្នាដែរ?

**ឆ៖** ប្រធានបទ--

**ប្រធានអង្គជំនុំ៖**

ចែកឲ្យច្បាស់លាស់រវាងវគ្គអប់រំ ហើយនិងចូលរួមពិធីអបអរ រំឭកខួបអនុស្សាវរីយ ថ្ងៃទី១៧ មេសា ១៩៧៥ ដែលជាថ្ងៃជ័យជម្នះ។ បើមិនអ៊ីចឹងទេ ច្របូកច្របល់អ៊ីចឹង មិនដឹងថាយ៉ាងម៉េចទេ។ ហើយមេធាវីសួរ ឲ្យបញ្ជាក់ឲ្យច្បាស់លាស់។ អំមិញ១ឆ្នាំ១៩៧៧ អាពិធីហ្នឹងធ្វើថ្ងៃណា ខែណាឲ្យច្បាស់លាស់ ដើម្បីកំណត់ថ្ងៃហ្នឹង ដែលជាកាលបរិច្ឆេទសំខាន់សួរដេញដោលពាក់ព័ន្ធទៅនឹង តែមួយទៅបានហើយ។

[១៣:៥៦:៣០]

**លោក ស សារិន៖**

**ឆ៖** សូមគោរពលោកប្រធាន តាមខ្ញុំចាំការរៀនហ្នឹង គឺរៀនប្រហែលជាមុន មុនមួយអាទិត្យអីហ្នឹង ហើយបុណ្យខួប ១៧មេសាហ្នឹង គេធ្វើនៅអីនេះវិញទេ លោកប្រធាន ធ្វើនៅស្តាតវិញអង្កាល់ហ្នឹង

តែខ្ញុំអត់បានចូលរួមទេ។ គេធ្វើ -- បាទ ខ្ញុំអត់បានចូលរួមទេ។ អានេះ ដូចវគ្គរៀនសូត្រទេ។

**ប្រធានអង្គជំនុំ៖**

បាន។ បន្តទៅទៀតណាលោកមេធាវី លោកស្តាប់រឿងហេតុហ្នឹងមិនបានច្បាស់ដែរ។ អ៊ីចឹងគាត់អត់បានចូលរួមទេ នៅក្នុងពិធីអបអរសាទរ ខួបអនុស្សាវរីយ ១៧មេសា ៧៥ហ្នឹង គាត់មិនដែលបានចូលរួមទេ។ ដូច្នេះលោកសួរ មិនអាចមិន ទំនងមិនដឹងទេ។

តទៅសួរទៀត!

[១៣:៥៧:២២]

**លោក វ៉ែន ពៅ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** កាលពីព្រឹកមិញ ពូបានបញ្ជាក់ហើយថា នៅពេលវគ្គរៀនសូត្រដែលបង្រៀនដោយលោកនួន ជា នោះ ពូបានបញ្ជាក់ថា មានឲ្យការលើកដៃចុះឈ្មោះធ្វើប្រវត្តិរូប ឬក៏ជីវទស្សន៍នោះ តើពូមានដឹងឬក៏មានអ្នកណាប្រាប់ពូទេ វាសនាអ្នកដទៃទៀត ដែលលើកដៃ ហើយចុះប្រវត្តិរូបនោះ តើពួកគេយ៉ាងម៉េចដែរ ពូបានដឹងទេ?

**លោក ស សារិន៖**

**ឆ៖** មនុស្សជាច្រើនដែលលើកដៃហ្នឹង ភាគច្រើនមន្ទីរក-១២ ខ្ញុំទៅរៀនហ្នឹងប៉ុន្មាននាក់ទេ។ តែប្រធាន១ទេ។ តាមខ្ញុំចំណាំ ខ្ញុំមានឃើញវត្តមានប្រធាន១ខ្ញុំហ្នឹងទេ និងប្រធានកង កងតូចហ្នឹង គេហៅប្រធាន ឃហ្នឹង។ តែដល់ទៅក្រោយមក មានអ្នកខាងដឹកជញ្ជូនជើងគោក និង ខាងក្រសួងថាមពលខ្លះលើកដៃហ្នឹង ដែលគាត់កត់ឈ្មោះហ្នឹង។ ប៉ុន្តែដល់មកមន្ទីរវិញ ក្រោយមក១មន្ទីរហ្នឹង ឃើញតែបាត់មនុស្សមិនតិចជាង២០នាក់ទេកាលហ្នឹង ផ្លាស់ប្តូរភារកិច្ច មិនដឹងជាគេទៅណា យើងក៏មិនហ៊ានដេញដោល យើងក៏រវល់ទៅខាងនោះ ធ្វើខាងនេះ ធ្វើខាងនោះទៅ។

[១៣:៥៩:១១]

**ស៖** បាទ សូមអរគុណ។ ចុះពាក់ព័ន្ធចំពោះរូបពូផ្ទាល់វិញ ថាពូមានបានចុះឈ្មោះ ឬលើកដៃនឹងគេទេ ហើយក្រោយរបបហ្នឹង តើពូត្រូវបានគេដូរចេញពី ក-១២ ហ្នឹងដែរ ឬក៏ពូធ្វើការនៅហ្នឹងរហូតដល់ចប់របបហ្នឹង?

**ឆ៖** ប្រវត្តិរបស់ខ្ញុំនុ៎ងវែងឆ្ងាយណាស់លោកមេធាវី។ ដល់ទៅក្រោយមក រហូតមានជម្លោះជាមួយវៀតណាមហ្នឹងខ្លាំង ខាងមន្ទីរហ្នឹងគេឲ្យខ្ញុំទៅដឹកគ្រាប់ ទៅកាន់ខាងឃ្លាំងកំពង់ចាមនោះ។ ជម្លោះជាមួយវៀតណាមហ្នឹងទៅប្រហែលជាដើមឆ្នាំ៧៨ ប្រហែលខែ១ ខែ២ ហ្នឹង លែងបាននៅកន្លែងភ្ញៀវហ្នឹងទៀតហើយ។ កាលហ្នឹង ខ្ញុំធ្លាប់ឮសម្ដីបង ប៉ង់ គាត់ជួបជាមួយ បងមៀល ហ្នឹង បងសាំក្រោយមកគាត់ឡើងប្រធានមន្ទីរហ្នឹងដែរហ្នឹង។ គាត់ថាឲ្យរើសសមមិត្តណានេះទៅយើងមានគោលជំហរល្អ ប្រវត្តិរូបល្អអីឲ្យទៅនៅឯឃ្លាំងគ្រាប់កំពង់ចាមហ្នឹង។ រួចទៅ ពេលនុ៎ងពេលហូបបាយ ខ្ញុំឮពាក្យសម្ដីគាត់។ ដល់ថ្ងៃក្រោយមកទៀត គេឲ្យយកឡានហ្នឹង១០គ្រឿងឡើងទៅនៅកំពង់ចាមហ្នឹង ដឹកគ្រាប់ដឹកអី សម្រាប់ផ្គត់ផ្គង់ភូមិភាគបូព៌ា ភូមិភាគកណ្ដាល និងភូមិភាគពាយ័ព្យ និងតាមបណ្ដាកងពលដោយយើងមានការប្រយុទ្ធគ្នាជាមួយខាងកងទ័ពវៀតណាមហ្នឹង រួចខ្ញុំលែងបាននៅដឹកភ្ញៀវទៀតហើយគ្រាន់យូរៗមកម្ដងអ៊ីចឹងទៅ។

ដល់ទៅក្រោយមកទៀត ប្រហែលជាខែ៦ មានព្រឹត្តិការណ៍នៅបូព៌ាហ្នឹង ដល់ទៅមានព្រឹត្តិ-ការណ៍នៅបូព៌ាហ្នឹង គេប្រាប់ថាតាភឹម ហ្នឹងធ្វើឃាត គេថាតាភឹម ហ្នឹងក្បត់។ អ៊ីចឹងតាំងពីពេលនុ៎ងមកខ្ញុំហ្នឹងគេលែងឲ្យទៅទឹកដីបូព៌ារហូត។ ទទួលពេលហ្នឹងខ្ញុំធ្លាក់ខ្លួនឈឺ ហើយខ្ញុំមកដេកពេទ្យ១៧មេសា។ ដល់ទៅដេកពេទ្យទៅ ធម្មតាអ្នករបួសឡើងពេញណែនរកកន្លែងដេកមិនចង់បានទេ។ រួចជួបពួកបូព៌ាៗហ្នឹង គេចេះតែសួរនាំមកពីស្រុកណាអីស្រុកណើ រួចឮថានៅបូព៌ាហ្នឹង គេរាប់អានគ្នាទៅ ក្រែងលោមានបងប្អូនមានអី។ រួចជួបបងមួយនៅភូមិ គេហៅភូមិម្ហូងរាវ ជាប់ភូមិខ្ញុំហ្នឹង គាត់ខ្សឹបប្រាប់ខ្ញុំថា បូព៌ាយើង គេចាប់អស់ហើយ ថាអ្នកឯងកុំទៅវិញនោះ។ ខ្ញុំថា ទោះបីយ៉ាងម៉េច គេចាប់គេជាក៏យ៉ាងម៉េច ក៏ខ្ញុំទៅដែរ ព្រោះខ្ញុំអត់ដែលធ្វើអីខុសទេ ទោះបីយ៉ាងម៉េចក៏ដោយ។ ដឹងដំណឹងពីគាត់អ៊ីចឹងថា ដល់ខ្ញុំដឹងអ៊ីចឹងបានគេអត់ឲ្យខ្ញុំចេញចូលទៅបូព៌ាហ្នឹង។ ហ្នឹងខ្ញុំគ្រាន់បញ្ជាក់ជូនអ៊ីចឹង ដល់លោកមេធាវី។ រួចវែងឆ្ងាយទៅទៀត ក្រោយបាទ។

[១៤:០៣:១៤]

**ស៖** បាទ សូមអរគុណ។ នេះជាសំណួរចុងក្រោយរបស់ខ្ញុំហើយ ខ្ញុំចង់សួរពូ ពូធ្លាប់បញ្ជាក់ថាមានផ្ទះលេខ១ លេខ២។ តើពូអាចរៀបរាប់បានទេ នៅរបបនោះ ផ្ទះលេខ១ លេខ២ ដល់លេខប៉ុន្មានហើយជាកន្លែងអីដែរបាទ?

**ឆ៖** ផ្ទះលេខ១ ផ្ទះលេខ២ ហ្នឹង គឺៗជាកម្មសិទ្ធិខាងប-១។ បើនិយាយទៅប-១ គេអ្នកគ្រប់

គ្រងខាងផ្នែកអង្គភាពការបរទេស។ ផ្ទះលេខ១ ហ្នឹងជាវិមានរដ្ឋាភិបាលរាល់ថ្ងៃហ្នឹង នៅខាងកើតវត្តភ្នំហ្នឹង គេសម្រាប់ភ្ញៀវថ្នាក់ប្រធានាធិបតី។ ហើយផ្ទះលេខ២ហ្នឹង គឺនៅៗអូតែលឡឺរ៉ូយ៉ាល់ ទល់មុខសាលាសេដ្ឋកិច្ចហ្នឹង ហ្នឹងសម្រាប់ភ្ញៀវថ្នាក់ការបរទេសអី ហើយគេឲ្យសម្រាកនៅហ្នឹង។ ប៉ុណ្ណឹងបាទ។

**ស៖** ចុះមានផ្ទះដល់លេខប៉ុន្មានដែរ តែពីរហ្នឹងទេ ឬក៏មានលេខ៣ លេខ៤ អីតទៀត?

**ឆ៖** ហ្នឹងជាៗខាងអង្គភាព ប-១ ហើយ។ ផ្ទះលេខ៣ហ្នឹង នៅមុខវត្តភ្នំ អាកន្លែងជិតជាប់ប្រៃសណីយ៍ហ្នឹង។ អាហ្នឹងថ្នាក់អ្នកកាសែតបរទេសអី ដូចកាសែតស៊ុយអែត កាសែតអី ខ្ញុំឃើញ ខ្ញុំធ្លាប់ជូនភ្ញៀវផ្សេងៗទៀតអីគាត់នៅសម្រាកហ្នឹង ថ្នាក់បច្ចេកទេសអីៗនៅសម្រាកហ្នឹង ហើយផ្ទះលេខ៤ហ្នឹង នៅនែ!ក្រោយទន្ទឹមក-១២ខ្ញុំ ក្រោយវិមានទិព្វឯណោះ ចូលទៅក្នុងប្រហែលជា៣០០ម៉ែត្រ អាហ្នឹងខាងបច្ចេកទេសចិន បាទ ផ្ទះលេខ៤ត្រង់ហ្នឹង។ ហើយផ្ទះលេខ៥ហ្នឹង អាជ្ញាធរគ្រឿងញៀននោះត្រង់ហ្នឹងដែលធំជាងគេ ដែលភ្ញៀវកម្មករចិនរាប់ពាន់នាក់នោះ សម័យហ្នឹងគេមកធ្វើកសាងនៅកម្ពុជាប្រជាធិបតេយ្យយើងហ្នឹងមានៗ ដូចរោងចក្រប្រេងកាត កំពង់ផែរាម និងកប៉ាល់លិចៗតាមទន្លេមេគង្គតាមសម័យដោយសម័យ លន់ នល់ ហ្នឹង ក៏ខាងបច្ចេកទេសចិនហ្នឹង គេមកស្រង់ឲ្យដែរ ហើយនិងតាមរោងចក្រតម្បាញ តាមរោងចក្រចម្ការកៅស៊ូ និយាយទៅ អ្នកបច្ចេកទេសចិនច្រើនណាស់កាលហ្នឹង។ បាទផ្ទះលេខ៥ហ្នឹង ក្រៅពីហ្នឹងវាមានតែតាមខេត្តទេ ហើយនិងភ្ញៀវខាងយន្តហោះនៅជិតបូរីកីឡាដែរហ្នឹងខាងអ៊ំ សុន សេន ទេ គេអ្នកក្តាប់រឿងខាងភ្ញៀវបច្ចេកទេសយន្តហោះនោះ។ ជម្រាបជូនលោកមេធាវីអ៊ីចឹងបាទ។

**លោក វ៉ែន ពៅ៖**

បាទ សូមៗអរគុណពូ។ លោកប្រធាន ខ្ញុំអស់សំណួរហើយបាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ យកធ្វើអីទៅ? បាទៗអង្គជំនុំជម្រះអនុញ្ញាត។ អញ្ជើញៗ។

[១៤:០៧:៥៣]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមជម្រាបសួរលោកដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរលោកក្នុងនាមព្រះរាជអាជ្ញា។ ខ្ញុំគិតថាលោករង់ចាំក្រដាសរបស់លោកសិន ដូច្នេះយើងអាចរង់ចាំ។ ខ្ញុំចង់សួរលោកអំពីពេលវេលាក្រោយថ្ងៃ១៧ មេសា ៧៥បន្តិច គឺនៅពេលដែលលោកនៅក្នុងស្រុកត្បូងឃ្មុំនៅផ្ទះរបស់លោកនៅឡើយនោះ តើលោកអាចប្រាប់បានទេថាតើមានអ្វីកើតឡើងចំពោះមន្ត្រីរដ្ឋការ លន់ នល់ និងទាហាន លន់ នល់ នៅក្នុង<ឃុំ>របស់លោកនៅនៅក្រោយថ្ងៃ១៧ មេសា ១៩៧៥នោះ?

**លោក ស សារិន៖**

**ឆ៖** ដូច -- បាទ សូមគោរពលោកប្រធាន សូមគោរពដល់អង្គសវនាការ។ ដូចខ្ញុំបានជម្រាបពីខាងដើមមកហើយ កើតមានចំពោះទាហាន លន់ នល់ កាលហ្នឹងៗ គឺក្រោយពីរំដោះ១៧ មេសាហ្នឹងមិនដឹងជាអង្គភាពខាងណាទេ គេបណ្ដើរមកហ្នឹង ប៉ុនគេថាមកយប់ទេ ខ្ញុំចាំកាលហ្នឹងមកដល់យប់ រួចគេឲ្យមកនៅលើវត្តមួង នៅក្នុងឃុំរបស់ខ្ញុំហ្នឹង។ បាទ រួចចំណាំរាល់ដងបាយគេយកទៅដាក់នៅសមរភូមិ យើងនាំគ្នាដឹកជញ្ជូនទៅសមរភូមិ ដល់លើកហ្នឹងយើងៗឈប់រើគ្នាហើយ យើងយកបាយហ្នឹងមកឧបត្ថម្ភខាងឲ្យខាងទាហាន លន់ នល់ វិញ។ បាទ សូមអស់យោបល់លោកសហព្រះរាជអាជ្ញា។

**ស៖** តើលោកបានឃើញទាហានដែលគេប្រមូលផ្ដុំនៅវត្តហ្នឹងទេ? ហើយប្រសិនបើបានឃើញ តើមានទាហានលន់ នល់ ប៉ុន្មាននាក់ដែរ ដែលគេប្រមូលផ្ដុំនៅវត្តនោះ?

[១៤:១០:១៦]

**ឆ៖** បានឃើញលោកសហព្រះរាជអាជ្ញា បានទាំងនិយាយលេងមួយគាត់ទៀត។ គេតែងតែកសាងខ្ញុំថា ពេលយកបាយទៅយើងយកឲ្យគាត់ហូប រួចតែនេះគ្មានការនិយាយឆ្លើយឆ្លងគ្នាហើយ រួចដល់អ៊ីចឹងគេថាកុំឲ្យយើងមានភាពស្និទ្ធស្នាល ព្រោះពួកហ្នឹងជាខ្មាំងអ៊ីចឹងបាទ។ ឃើញលោកៗសហព្រះរាជអាជ្ញាឃើញ។

**ស៖** បើតាមដែលលោកចាំ តើលោកឃើញទាហានលន់ នល់ ប៉ុន្មាននាក់ដែរ ដែលគេប្រមូលផ្ដុំនៅក្នុងវត្តនោះ?

**ឆ៖** ប្រហែលជាជិត ២០០នាក់ ជាង១០០នាក់អីហ្នឹង។ ខ្ញុំអត់សូវចាំដែរ ប្រហែលប៉ុណ្ណឹង។

**សៈ** តើលោកអាចប្រាប់តុលាការបានទេថា ធ្វើយ៉ាងណាបានលោកដឹងថាពួកគាត់ទាំងអស់នោះទាហានលន់ នល់?

**ធៈ** អត់មានពិបាកអីចំណាំទេលោកសហព្រះរាជអាជ្ញា ព្រោះខាងសមរភូមិគេបញ្ជូនមក ឯកសណ្ឋានគាត់ជាទាហាន អត់មានអីពិបាកចំណាំទេ។ សូមអស់យោបល់។

[១៤:១២:១១]

**សៈ** សូមអរគុណលោកដើមបណ្ដឹង។ ឥឡូវនេះ ខ្ញុំសូមអាននូវសម្រង់នៃការសម្ភាសជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីឱ្យលោកបញ្ជាក់បន្ថែមគឺ ឯកសារ E3/5783, ខ្មែរមានលេខ <0048 2778>, អង់គ្លេសមានលេខ <00739510> ហើយបារាំងមានលេខ 00746460។ នេះគឺជាកំណត់ហេតុស្ដាប់ចម្លើយ គឺជាការសម្ភាសជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំសូមដកស្រង់៖ “ខ្ញុំអាណិតអតីតទាហានលន់នល់ ដែលបន្ទាប់ពីចាញ់សង្គ្រាមទៅត្រូវបានគេយកពី<ទន្លេបិទ ពីវត្តឃ្លង ពីប៉ម ពីអីទៅហ្នឹង។> គេឱ្យខ្ញុំការពារទាហានដែលចាប់ខ្លួនប្រហែលជា២០០នាក់។ ខ្ញុំឃើញទាហាននៅទីនោះ ខ្ញុំមិនបានបណ្ដើរពួកគេទេ ហើយខ្ញុំមកដល់ទីនោះនៅពេលដែលពួកគេបញ្ជូនទៅឃុំ។” គឺថាវាត្រឹមត្រូវទេ ដែលនៅពេលនោះគេឱ្យលោកនៅការពារទាហានលន់ នល់ ហើយប្រសិនបើគេឱ្យលោកនៅការពារទាហានលន់ នល់ ហ្នឹងវិញ តើអ្នកណាបញ្ជាឱ្យលោក<ធ្វើកិច្ចការទាំងអស់ហ្នឹង>?

**ធៈ** ប៉ម ហ្នឹងទល់មុខកំពង់ចាមបាទ ជាៗរឿងត្រឹមត្រូវបាទ។ គេដាក់វេនគ្នាអាហ្នឹងយាម គេដាក់វេនគ្នាបាទ។

**សៈ** តើអ្នកណាជាអ្នកបញ្ជា ឬក៏អ្នកណាជាអ្នកចាត់តាំងឱ្យលោកនៅយាមទាហានទាំងអស់នោះ?

**ធៈ** ឈ្មោះ បងញឹម គាត់ជាប្រធានកងឈ្លបនៅក្នុងឃុំម្លូងរាវហ្នឹងបាទ។

[១៤:១៤:៥៨]

**សៈ** តើគេទុកទាហាន លន់ នល់ ទាំងអស់នេះនៅវត្តប៉ុន្មានថ្ងៃដែរ? ហើយបន្ទាប់មកទៀត តើមានអ្វីកើតឡើងចំពោះទាហានទាំងអស់នោះ?

**ធៈ** ប្រហែលជាជិតពីរខែលោកសហព្រះរាជអាជ្ញា។

**សៈ** តើនៅក្រោយពីពីរខែដែលគេទុកពួកទាហានទាំងអស់ហ្នឹងនៅវត្តហ្នឹង តើមានអ្វីកើតឡើងចំពោះទាហានទាំងអស់នោះ?

**ឆ៖** ក្រោយពេល? សូមបញ្ជាក់។ បាទដល់ក្រោយពេល រយៈពេលពីរខែហ្នឹងគេបញ្ជូនទាហានទាំងអស់នុ៎ងទៅ ហើយ បងញើម ហ្នឹងគាត់លួចខ្សឹបប្រាប់ខ្ញុំថាៗគេយកពួកហ្នឹងទៅសម្លាប់ចោលអស់ហើយ ទាហានទូទាំងប្រទេសព្រោះយើងទុកមកជិត ពីរខែហ្នឹងរង់ចាំមើលថ្នាក់លើថា យក -- ដំបូងមានគោលការណ៍ប្រុងចែកតាមសហករណ៍ រួចដល់ទៅអត់មានគោលការណ៍អីចឹង ន័យពាក្យកាលហ្នឹងគេថា "យកទៅរៀនសូត្រ"។ ដំបូងគេយកតែមេៗ ស័ក្តិ៣ ស័ក្តិ៤ អីចឹងទេ។ ខ្ញុំបានឃើញគេដឹករទេះសេះទៅ តែមិនដឹងទៅណាមកណាទេ យើងមិនហ៊ានដេញដោលទេ យើងមានឋានៈតូចតាចនោះ។ ថាយកទៅរៀនសូត្រៗហ្នឹង ដល់ក្រោយមកប្រហែលជាៗ មួយអាទិត្យក្រោយមក មួយអាទិត្យ ១០ថ្ងៃក្រោយទៀតបានៗពេលនុ៎ងកាលយាមហ្នឹង ខ្ញុំមិនមែននៅយាមរាល់ថ្ងៃ សូមបញ្ជាក់លោកសហព្រះរាជអាជ្ញា គេដាក់វេនគ្នាៗ ម្នាក់ហ្នឹងយាម១ថ្ងៃ វិលចុះវិលឡើងអីចឹងទៅ។ រួចដល់ទៅទាហានហ្នឹងគេដកចេញអស់ ខ្ញុំអត់បាននៅយាមទេ ខ្ញុំទៅនៅកន្លែងនីរសារខ្ញុំវិញហើយ ចាំរត់សំបុត្រ រត់អី ទៅតាមភូមិកន្លែងដែលមានខាងអង្គភាពខ្លះគេមកទាក់ទងពីការងារស្បៀង ខ្លះក៏នៅតែមានអីចឹង ហើយនិងរត់សំបុត្រតាមមូលដ្ឋានហ្នឹង។ សូមបញ្ជាក់លោកសហព្រះរាជអាជ្ញា អរគុណ។

[១៤:១៨:២៤]

**ស៖** លោកបានបញ្ជាក់ថា ក្នុងរយៈពេល២ខែ ដែលគេឃុំទាហានទាំងអស់នោះ គឺថាលោករង់ចាំបញ្ជាពីមជ្ឈិម។ ដូច្នេះខ្ញុំចង់ដឹងថាតើឃុំ -- តើលោកធ្វើយ៉ាងណាបានដឹងថាឃុំហ្នឹងរង់ចាំបញ្ជាពីមជ្ឈិមមក?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗឆ្លើយ លោកដើមបណ្តឹងរដ្ឋប្បវេណី អញ្ជើញលោកមេធាវី គង់ សំអុន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ ដោយសារវាជាប្រភេទសំណួរទាក់ទងទៅនឹងការប្រព្រឹត្តចំពោះទាហានលន់នល់ ដែលនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/២ របស់យើង ហើយដែលជាអង្គហេតុស្ថិតនៅក្នុងសំណុំរឿង០២/០១។ ហើយម្យ៉ាងទៀត កន្លងមកនេះខ្ញុំស្តាប់ឃើញតំណាងសហព្រះរាជអាជ្ញារងអន្តរជាតិ បានសួរសំណួរជាក់លាក់ជាច្រើនទាក់ទងទៅនឹងអង្គហេតុនៃការប្រព្រឹត្តចំពោះទាហានលន់ នល់ នេះ។ ដោយឡែក ចំពោះការជំទាស់ទី២ គឺដើមបណ្តឹងរដ្ឋប្បវេណីគាត់ឆ្លើយថា រង់ចាំបញ្ជាពីថ្នាក់លើដែលជាសម្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនមែន

រង់ចាំបញ្ជាពីមជ្ឈិមទេ។ ដូច្នេះ ខ្ញុំសូមជំទាស់លើមូលហេតុពីរនេះ។ សូមអរគុណ។

[១៤:១៩:៥៤]

**លោក ខេល លីសាក់៖**

ខ្ញុំសូមធ្វើការឆ្លើយតបសិន ព្រោះថាការប្រព្រឹត្តចំពោះទាហាន លន់ នល់ គឺថាការកំណត់គោលដៅ គឺជាផ្នែកមួយនៃសំណុំរឿង ហើយខ្ញុំគិតថាអង្គជំនុំជម្រះបានសម្រេចច្រើនដងរួចមកហើយនៅលើចំណុចនេះ ហើយខ្ញុំចំពោះ <ទាក់ទងទៅនឹងបញ្ហានៃការ>បញ្ហា<> ខ្ញុំនឹង<រៀបសំណួរ>ឡើងវិញ <ហើយនិងដកស្រង់ពីចម្លើយរបស់គាត់ ដែល>គាត់បានឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ដូច្នេះខ្ញុំសូមអនុញ្ញាតពីលោកប្រធានបន្តទៅមុខទៀត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត ហើយបដិសេធសេចក្ដីជំទាស់នេះ។ នេះគ្រាន់តែជាការបញ្ជាក់អំពីការអនុវត្តនូវគោលនយោបាយទេ។ វាក្រៅអង្គហេតុមែន ប៉ុន្តែបញ្ហាវាពាក់ព័ន្ធជាមួយនឹងការអនុវត្តគោលនយោបាយ ប៉ុន្តែមិនគប្បីសួរឲ្យស៊ីជម្រៅពេកទេ ពាក់ព័ន្ធជាមួយនឹងអតីតទាហាន លន់ លន់ នោះពីព្រោះយើងបានធ្វើសវនាការរួចហើយ។

[១៤:២១:០០]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** សូមអរគុណលោកប្រធាន។ ឥឡូវនេះ ខ្ញុំសូមអាននៅសម្រង់ខ្លីដែលដកស្រង់ចេញពីការសម្ភាសរបស់លោក គឺ E3/5783 គឺខ្មែរមានលេខ 00482778 រហូតបន្តទៅក្រោមទៀត។ អង់គ្លេសមានលេខ 00739511 ដល់12, បារាំងមានលេខ 00746461។ ហើយលោកបាននិយាយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំសូមដកស្រង់៖ "ខ្ញុំនៅចាំអ្វីដែលប្រធានខ្ញុំបាននិយាយ គាត់អប់រំខ្ញុំ ហើយនិយាយថា ទាហានទាំងអស់នោះ -- ទាហានទាំងអស់ហ្នឹង គេអត់ទាន់ឲ្យទៅណាទេ ព្រោះគេនៅរង់ចាំបញ្ជាពីមជ្ឈិមមក។ សំណួរ៖ ពួកទាហានឈ្លើយសឹកហ្នឹង? ឆ្លើយ៖ បាទ ខ្ញុំដឹងថា ទាហានឈ្លើយសឹកហ្នឹងត្រូវបានគេសម្លាប់នៅពេលក្រោយ ហើយគេនិយាយថា មជ្ឈិមបញ្ជាឲ្យ<សម្លាប់>ទាហានឈ្លើយសឹក<លន់ នល់> នៅទូទៅទាំងប្រទេស<>។ ខ្ញុំធ្លាប់ចូលប្រជុំ គឺថាពេលប្រជុំ គេថា ត្រូវតែកម្ទេចចោល<អ្នកទោសឈ្លើយសឹកទាំងអស់នោះ>"។ សូមបញ្ចប់ការដកស្រង់។

លោកបានបញ្ជាក់ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាថា គេប្រាប់លោកថា ត្រូវរង់ចាំបញ្ជាពី

ថ្នាក់ ពីមជ្ឈិម គឺថា ហើយក្រោយមកមានបញ្ជាពីមជ្ឈិមឲ្យសម្លាប់ទាហាន លន់ នល់ ទាំងអស់នៅទូទាំងប្រទេស។ ដូច្នេះ ខ្ញុំចង់ដឹងថា <តើនរណាជាអ្នកប្រាប់លោក?> តើលោកដឹងព័ត៌មានទាំងអស់នេះ<ដោយរបៀបណា>ដែរ?

**លោក ស សារិន៖**

**ឆ៖** ពីប្រធានខ្ញុំឈ្មោះ ញឹម ហ្នឹងលោកសហព្រះរាជអាជ្ញា។

[១៤:២៣:១១]

**ស៖** នៅក្នុងការសម្ភាសរបស់លោក គឺលោកបាននិយាយថា លោកបានចូលប្រជុំ ហើយនៅក្នុងការប្រជុំហ្នឹង គេនិយាយអំពីបញ្ហានេះ។ តើវាជារឿងត្រឹមត្រូវមែនទេ <បើដូច្នេះមែន តើលោកអាចប្រាប់យើងអំពីកិច្ចប្រជុំ ដែល ញឹម> និយាយអំពីរឿងហ្នឹង <បានដែរ ឬទេ>?

**ឆ៖** ជារឿងត្រឹមត្រូវបាទ។ ប្រជុំនុំងក៏និយាយ មកក្រៅហ្នឹងក៏គាត់និយាយដែរ។

**ស៖** លោកបាននិយាយថា ទាហានលន់ នល់ ត្រូវបានគេយកទៅ គឺថាជាដំបូងគេយកអ្នកដែលមានឋានៈខ្ពស់ ដូចជាឧត្តមសេនីយ៍ជាដើម។ តើលោកដឹងទេថា ទាហានលន់នល់ ដែលត្រូវបានគេសម្លាប់ហ្នឹង គឺជាទាហានដែលមានបណ្តាស័ក្តិ ឬមួយក៏ទាហានទាំងអស់ រួមទាំងកូនទាហានផងហ្នឹងត្រូវបានគេសម្លាប់ទាំងអស់គ្នា?

**ឆ៖** តាមខ្ញុំដឹង សម័យហ្នឹង គេប្រើពាក្យថា "យកទៅរៀនសូត្រ" ប៉ុន្តែដូចខ្ញុំលើកឡើងពីដំបូងហ្នឹង ថាដំបូងគេយកមេៗទៅ។ ជិះរទេះសេះទៅ ខ្ញុំឃើញ ជិះរទេះសេះទៅធម្មតាហ្នឹង គ្មានកាំភ្លើងគ្មានអីទេ ភ្លង់អី បួនប្រាំនាក់ហ្នឹងទៅ។ ដល់ក្រោយមក ចេញទៅយប់ ខ្ញុំអត់ដឹងទេ ដូចខ្ញុំបញ្ជាក់ខាងដើមអ៊ីចឹង។ ស្ងាត់ ដល់រួចទៅស្ងាត់ឈឹងទៅ មិនដឹងជាគេយកទៅទីណាអីទីណា យើងក៏គ្មានសិទ្ធិអីដេញដោលដែរ សម័យហ្នឹងនោះ សូមជម្រាបប្រសាសន៍លោកសហព្រះរាជអាជ្ញា។ ថាទៅរៀនសូត្រៗទៅ យើងដឹងពីព័ត៌មានហ្នឹង យើងក៏មិនប៉ាននិយាយដែរ តែគេនិយាយហ្នឹង គេយកទាំងយើងហ្នឹងទៅទៀត ខ្ញុំគ្រាន់តែបញ្ជាក់អ៊ីចឹង។ តែព័ត៌មានធ្លាយ ព័ត៌មានបែកការណ៍ហ្នឹង យើងក៏ទៅជាមួយទាហាននុំងដែរ។ សូមអរគុណ។

[១៤:២៥:៤៩]

**ស៖** អ្វីដែលខ្ញុំចាប់អារម្មណ៍ គឺអំពីមូលហេតុដែលលោកបានដឹង។ ខ្ញុំដឹងថាហេតុអ្វីបានជាទាហានមានបណ្តាស័ក្តិ ហេតុអ្វីបានគេយកអ្នកដែលមានទាហានមានបណ្តាស័ក្តិខ្ពស់ទៅមុនសិន លោក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដឹងទេ?

**ធ៖** ខ្ញុំជាកូនចៅគេ ខ្ញុំអត់អាចដឹងដល់ថ្នាក់នុ៎ងទេ ប៉ុនគ្រាន់ថា ដំបូងហ្នឹងខ្ញុំមើលឃើញអ៊ីចឹងថា ពេលកន្លែងគេដឹករទេះសេះគាត់ទៅហ្នឹង ឃើញទៅតែមេៗហ្នឹង។ សូមអរគុណ។

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី ថាតើស្រុកដែលលោកស្នាក់នៅ ដែលលោករស់នៅហ្នឹង នៅក្នុងតំបន់អ្វីដែរ?

**ធ៖** តំបន់២១។

**ស៖** តើអ្នកណាជាលេខា និងអនុលេខាតំបន់២១នោះ?

**ធ៖** អត់ដែលដឹងទេ សម័យនុ៎គឺលាក់ការណ៍ មិនដឹងអ្នកណាអ្នកណីធ្វើគណៈតំបន់ទេ តែគណៈស្រុកហ្នឹង ក៏យើងមិនស្គាល់ដែរ។ អត់ដឹងពីតួនាទី គេអត់មានចំហ ដូចឥឡូវផ្សាយទូរទស្សន៍ឯកឧត្តមនេះជាចៅហ្វាយខេត្ត ឯកឧត្តមនោះជាគណៈតំបន់ សម័យនុ៎ង គេលាក់ការណ៍ណាស់ អត់មានអ្នកណាដឹង អ្នកណាធ្វើអីៗទេ។ គេពាក់តែខោអាវខ្មៅបង់កក្រមា ដាក់ប៊ិកនៅហោប៉ៅហ្នឹង អត់ដឹងតែម្ដង។

[១៤:២៧:៥៣]

**ស៖** ខ្ញុំយល់អំពីចំណុចនេះលោកដើមបណ្ដឹង។ ឥឡូវនេះខ្ញុំចង់សួរលោកបន្ថែមទៀតអំពីចម្លើយដែលឆ្លើយដែលបុគ្គលម្នាក់ ដែលបញ្ជាក់ថា ជាអនុប្រធាន -- អនុលេខាតំបន់២១ គឺលោក អ៊ុក ប៊ុនឈឿន គឺកិច្ចសម្ភាសន៍ E3/387, ខ្មែរមានលេខ 00379486, អង់គ្លេសមានលេខ 00350205, បារាំងមានលេខ 00441418។ នេះគឺជាអ្វីដែលគាត់ឆ្លើយ ខ្ញុំសូមដកស្រង់៖ “នៅខែមេសា ឆ្នាំ៧៥ ប៉ុល ពត បានចេញនូវគោនយោបាយសម្ងាត់មួយទៀត គឺថាបោសសម្អាតសមាសធាតុទាំងអស់នៅក្នុងរបប លន់ នល់។ ចំពោះរដ្ឋបាលស៊ីវិល គឺនឹងមានការបោសសម្អាតពីថ្នាក់ឃុំរហូតទៅដល់ថ្នាក់លើ។ ទាក់ទងជាមួយទាហាន គឺថាបោសសម្អាតចាប់ពីអនុសេនីយ៍ត្រីរហូតទៅដល់ឧត្តមសេនីយ៍។ ថាតើវាធ្វើឱ្យលោកនឹកឃើញអំពីចំណុចនេះដែរឬទេ <នៅពេល>លោកបានឮអំពីប្រធានឈ្លបឃុំ<>និយាយអំពី<បទបញ្ជាដែលទទួលបាននោះ ថាតើមានការនិយាយអំពីភាពខុសគ្នា ដោយផ្អែកទៅលើឋានន្តរសក្តិ> ទាហានរបស់លន់ នល់ ដែរឬទេ?

[១៤:២៨:៤០]

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណី កុំអាលទាន់ឆ្លើយតប។ អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ។

01377291



**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ចំពោះការប្រើប្រាស់បែបជ្រើសរើស<ភស្តុតាង ដើម្បីឲ្យសាក្សីរូបនេះ ផ្តល់សក្ខីកម្ម>អំពីគោលនយោបាយទាក់ទងទៅនឹងទាហាន លន់ នល់ <នៅភូមិភាគបូព៌ា>។ យើងដឹងច្បាស់ទាំងអស់គ្នាហើយថាមានការសម្ភាសន៍ជាមួយ ហេង សំរិន ដែលនិយាយអំពីការប្រជុំខែឧសភា ឆ្នាំ៧៥ ហើយគាត់បានប្រើប្រាស់ពាក្យថាយកទាហាន និងមន្ត្រីរដ្ឋការលន់នល់ ចេញពីក្របខ័ណ្ឌ ហើយខ្ញុំគិតថា យើងបានពិភាក្សាពីចំណុចនេះច្រើនដងណាស់មកហើយ។ ប៉ុន្តែឥឡូវនេះ បែរជាគាត់ជ្រើសរើសដោយកាត់យកសក្ខីកម្មមួយចំណុចតូចរបស់កម្មាភិបាលខាងបូព៌ា <ហើយមិនបានលើកឡើងកិច្ចសម្ភាសន៍របស់ ហេង សំរិន>។ ដូច្នេះខ្ញុំគិតថា ព្រះរាជអាជ្ញាកំពុងតែធ្វើឲ្យដើមបណ្ដឹងរដ្ឋប្បវេណីគាត់យល់ច្រឡំហើយ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំបានអានន្ទូវសក្ខីកម្មរបស់អនុលេខាតំបន់ <ដែលសាក្សីធ្លាប់នៅ។> ហើយមេធាវីការពារក្តីគាត់អាចប្រើប្រាស់ភស្តុតាង ឬក៏អ្វីដែលគាត់ចង់ធ្វើ ព្រោះថា ប៉ែន យៀវនិន បានសម្ភាសមនុស្សប្រាំមួយនាក់ ហើយគេបានប្រើប្រាស់ពាក្យកម្ទេចដែលមានន័យថាសម្លាប់ ហើយ ហេង សំរិន និយាយថាកម្ចាត់ ដែលយើងដឹងថាវាមានបញ្ហានៅលើអត្ថន័យរបស់ពាក្យនេះ។ ដូច្នេះ ប្រសិនបើមេធាវីការពារក្តី គាត់ចង់សួរសំណួរ ឬក៏ចង់ចោទទៅលើបញ្ហាហ្នឹង គឺជាសិទ្ធិរបស់គាត់។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់របស់មេធាវីការពារក្តី បាទ ហើយបើមានបញ្ហាអីគឺលោកអាចដល់វេនលោកៗក៏នឹងធ្វើទៅ ហើយបច្ចេកទេស វិធីសាស្ត្រ ឬក៏យុត្តិសាស្ត្រក្នុងការពារក្តីមិនខុសគ្នាទេ ភាគីទាំងសងខាងសុទ្ធតែដកស្រង់នូវអ្វីដែលវា ដែលជាប្រយោជន៍ក្នុងការបំពេញមុខងាររៀងៗខ្លួន។

សាក្សីឆ្លើយតបនឹងសំណួរប្រសិនបើលោកសាក្សីចាំ! ហើយបើមិនចាំទេ លោកអាចសុំឲ្យតំណាងសហព្រះរាជអាជ្ញាអន្តរជាតិសួរលោកម្តង សាជាថ្មីម្តងទៀត។ ឥឡូវដើមៗបណ្តឹងរដ្ឋប្បវេណីសូមឲ្យលោករៀបចំសំណួរនោះសាជាថ្មីម្តងទៀត ភ្លេចហើយណ៎ា។

[១៤:៣២:២៧]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមអរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំអានសម្រង់ពីកិច្ចសម្ភាសន៍មួយជាមួយអតីតអនុប្រធានតំបន់២១ សំណួរខ្ញុំសួរថាតើវាជួយរំឭកដល់ការចងចាំដែរឬ របស់លោកឬក៏អត់? នៅពេលដែលលោកឮបញ្ហាតាមរយៈ <ញើម> គឺជាប្រធានឈ្លបឃុំហ្នឹង គឺថាលោកឮសួរថាគឺគេឲ្យមានការ<បែងចែកខុសគ្នាចំពោះការប្រព្រឹត្ត ដោយផ្អែកទៅលើឋានន្តរសក្ដិ>ទាហានរបប លន់ នល់ <ឬក៏អ្នករដ្ឋការលន់ នល់ ដែរ ឬទេ>?

**លោក ស សារិន៖**

**ឆ៖** ជារឿងត្រឹមត្រូវ។

**ស៖** តើលោកនៅចាំទេ ថាទាហានដែលគេឃុំខ្លួននៅក្នុងវត្តនោះ តើលោកមាននៅចាំ ឬអាចប៉ាន់ប្រមាណបានទេ ក្នុងចំណោមទាហានដែលគេឃុំនៅវត្តហ្នឹងមានទាហានប្រហែលជាប៉ុន្មាននាក់ដែរដែលមានបណ្ដាស័ក្ដិខ្ពស់ៗ?

**ឆ៖** ប្រហែលជាបួន ទៅប្រាំនាក់ប៉ុណ្ណឹង។

**ស៖** មុននេះ លោកបានបញ្ជាក់ថាលោកប្រើពាក្យថា "ខ្សឹប" គឺថាលោកថាមេឈ្លបឃុំហ្នឹងខ្សឹបទៅ -- ខ្សឹបប្រាប់លោកថាទាហានទាំងអស់ហ្នឹងត្រូវបានគេសម្លាប់ចោលអស់ហើយ តើខ្ញុំ -- បើខ្ញុំយល់មិនច្រឡំទេ គឺមេឈ្លបហ្នឹង គឺបានព័ត៌មានៗដែលបានថាទាហានទាំងអស់ត្រូវគេយកសម្លាប់អីចឹងគឺមកពីមេឈ្លបឃុំឈ្មោះ <ញើម> ហ្នឹង ឬក៏យ៉ាងណា? <តាមដែលលោកចាំ តើលោកអាចជម្រាបជូនតុលាការបានទេថា នេះគឺជាអ្វីដែល ញើម បានប្រាប់លោកនោះ?>

**ឆ៖** នេះគាត់ៗបានព័ត៌មានផ្ទៃក្នុងគាត់ខាងលើមកទេ ហើយគាត់ស្និទ្ធស្នាលជាមួយខ្ញុំគាត់ចេះតែនិយាយអីចឹងទៅ និយាយពាក្យហ្នឹងពេលប្រជុំនោះក៏និយាយ ដូចខ្ញុំលើកឡើងខាងដើមហើយ ពីរដងហើយពាក្យហ្នឹង។ ថាពេលប្រជុំក៏គាត់បាននិយាយ ពេលខ្សឹបគ្នាហ្នឹងពេលដើរធ្វើការពីរនាក់គាត់ហ្នឹងក៏គាត់និយាយដំណាលពីរឿងហ្នឹងដែរ។ រួចរឹងការសម្លាប់ហ្នឹងក៏មិនមែននៅហ្នឹងដែរ គេបញ្ជូនឡើងទៅលើទៀតក៏មិនដឹងទៅណាទេ។ មានមជ្ឈដ្ឋានខ្លះគេថាយកទៅកន្លែងឲ្យទៅកាប់ព្រៃនៅស្អីណាស្វាយយក្សស្វាយអីណានោះ អាហ្នឹងជាព័ត៌មានក្រៅទេណា។ រួចខ្លះគេថា អូ៎! ទៅសន្តិសុខទៅបារាយផ្កាដូងឯណានោះ ដែលក្នុងឯកសារយើងថានៅក្នុងមន្ទីរ១០០ លោកសហព្រះរាជអាជ្ញា បាទខ្ញុំមិនដែលស្គាល់ទេ។ ប្រហែលឮចាស់ៗគាត់ថាពួកហ្នឹងគេយកទៅណាសន្តិសុខបារាយផ្កាដូងឯណានោះ ហើយខ្លះទៅថា អូ៎! យកទៅខាងស្វាយយក្សស្វាយអីកាប់ព្រៃអីចឹង បើខ្ញុំក៏មិនដេញដោលដែរអាការងារហ្នឹង បើដឹងថាគេ

យកទៅរៀនសូត្រសម័យហ្នឹងវាកម្រណាស់អារឿងរស់។ បាទ សូមបញ្ចាក់លោកសហព្រះរាជអាជ្ញា។

[១៤:៣៦:២៥]

**ស៖** ឥឡូវខ្ញុំសួរសំណួរពាក់ព័ន្ធទៅនឹងអំឡុងពេលដែលលោកនៅស្រុកកំណើតរបស់លោក មុនពេលលោកមកភ្នំពេញ។ តើលោកអាចជម្រាបជូនតុលាការបានទេថាមានអ្វីកើតឡើងទៅដល់វត្ត ហើយនិងលោកសង្ឃនៅក្នុងឃុំរបស់លោក ក្រោយថ្ងៃ១៧ មេសា ១៩៧៥ មក?

**ឆ៖** ក្រោយថ្ងៃ១៧ មេសា ១៩៧៥ហ្នឹង ព្រះសង្ឃទាំងអស់នៅក្នុងវត្តនៅក្នុងឃុំខ្ញុំហ្នឹង គឺត្រូវបានផ្សឹកទាំងអស់ ថាព្រះសង្ឃចាស់ មិនថាព្រះសង្ឃក្មេងទេ។ គេផ្សឹកហ្នឹងរួចគេបញ្ជូនមកខាងលើហ្នឹង ខាងលើហ្នឹងមានន័យមកមជ្ឈិមហ្នឹង ខ្លះក្រោយមកទេ ដែលខ្ញុំបានបើកឡានហ្នឹង ខ្ញុំទៅជួប ខ្លះនៅកំពង់សោម ធ្វើកម្មករលីសែង ខ្លះនៅរោងចក្រប្រេងកាតកំពង់សោមហ្នឹង ព្រះសង្ឃនៅហ្នឹងដែលនៅស្រុកខ្ញុំហ្នឹង ក្រោយមកខ្ញុំជួបបាទ។ បើមុន៧៥ហ្នឹងសឹកដោយស្ម័គ្រចិត្ត ដល់ក្រោយហ្នឹងផ្សឹកអត់មានរកតែលោកមួយអង្គធ្វើបុណ្យក៏គ្មានដែរ។ សូមអស់យោបល់។

**ស៖** នៅកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបានបញ្ជាក់ថាវត្តពីរនៅស្រុកកំណើតរបស់លោក ខ្ញុំសង្ឃឹមថានឹងអានឈ្មោះវត្តនេះត្រូវ គឺសំរោង<បូរី> ហើយនិងម្លូង។ តើលោកអាចជម្រាបជូនតុលាការបានទេថា មានអ្វីកើតឡើងចំពោះវត្តទាំងពីរនេះក្រោយថ្ងៃរំដោះ ១៧ មេសា ៧៥មក? <តើគេប្រើប្រាស់វត្តហ្នឹងធ្វើអ្វីដែរ នៅក្នុងរបបខ្មែរក្រហម?>

**ឆ៖** វត្តនៅក្នុងឃុំខ្ញុំហ្នឹង គឺវត្តមួយដែលដាក់ទាហានហ្នឹងនៅជ្រុងនិរតីផ្សារស្លួងហ្នឹង វិហារខ្ពស់ធំហ្នឹង គេហៅថាវត្តម្លូង រួចវត្តសំរោងហ្នឹង សំរោងបូរី ខាងត្បូងស្លួងហ្នឹងឡើងទៅផ្លូវរកាខ្ទួចមកចូលអូររាំងឪ។ ពី១ទីក្រុងស្លួងប្រហែលជា៥គីឡូ អាហ្នឹងជួបប្រទះ ដូចខ្ញុំបានលើកឡើងអ៊ីចឹងគេផ្សឹកពីរវត្តហ្នឹង ថាខ្ញុំដឹងរឿងពីរវត្តហ្នឹង ខ្ញុំនិយាយពីរវត្តហ្នឹង។ ក៏ប៉ុន្តែកាលហ្នឹងគឺផ្សឹកទាំងអស់ហ្មង តាមវត្តនៅជិតនៅឆ្ងាយក៏ដោយក៏អត់មានដែរ ប៉ុនគ្រាន់តែលោកទៅមក១ដែលខ្ញុំធ្លាប់ចេញចូល១សម័យហ្នឹងគេអត់ឱ្យយើងដើរសេរីទេ ពីភូមិមួយទៅភូមិមួយសេរីបានខ្ញុំទេ ច្រើនធ្វើនីរសារអ៊ីចឹង ធាក់កង់អីទៅចែកសំបុត្រចែកអី ក៏សុំសំបុត្រប៉ុនបានដែហ្នឹង សម័យហ្នឹងនោះ តឹងតែងណាស់។ រួចពីឃុំមួយ ទៅឃុំមួយហ្នឹងក៏មានសំបុត្រឆ្លងឃុំដែរ។ អ៊ីចឹង គ្រាន់តែដឹងឃុំក្បែរ១ហ្នឹង ដូចឃុំជប់ ឃុំអី ឃុំស្លួងអីហ្នឹង អស់ដូចខ្ញុំលើកឡើងអ៊ីចឹង ថារកតែលោកមួយអង្គធ្វើបុណ្យគ្មានផង។ ខ្មោចងាប់អីហ្នឹង គេលែងសូត្រធម៌ហើយអង្កាល់នោះ គេយកទៅកប់១តែម្តងហ្នឹង។ បើអ្នកមានមុខមានមាត់ គេគោរពវិញ្ញាណក្ខន្ធទៅ

ហើយបើថាអ្នកប្រជាជនសាមញ្ញហ្នឹងយកទៅកប់ដូច ខ្មោចឆ្កែ ខ្មោចឆ្មាទៅ។ សូមអស់យោបល់។

[១៤:៤១:១០]

**ស៖** សូមអរគុណ។ ឥឡូវខ្ញុំសួរសំណួរពាក់ព័ន្ធទៅនឹងអំឡុងពេលដែលលោកទើបតែបានមកទីក្រុងភ្នំពេញ។ លោកបានឆ្លើយរួចមកហើយនៅក្នុងកិច្ចសម្ភាសន៍របស់លោក លោកថាលោកបានមកដល់ភ្នំពេញនៅម្តុំខែកញ្ញា ឬក៏ខែតុលា ឆ្នាំ១៩៧៥ ហើយព្រឹកមិញនេះ ក៏លោកលើកឡើងម្តងដែរ ពីពេលមកដល់ភ្នំពេញ។ តើគេមានចាត់តាំងឲ្យលោកទៅរៀន ចូលរៀនសូត្រវគ្គអប់រំនយោបាយណាមួយដែរឬទេ ក្រោយពេលមកដល់ទីក្រុងភ្នំពេញ គឺក្រោយពេលមកដល់ទីក្រុងភ្នំពេញនៅឆ្នាំ ចុងឆ្នាំ១៩៧៥ និងដើមឆ្នាំ១៩៧៦?

**ឆ៖** សូមគោរពលោកប្រធាន។ មាន សូមបញ្ជាក់លោកសហព្រះរាជអាជ្ញា មានឲ្យទៅរៀននៅគេហៅ ក-១៥ ហ្នឹងសាលាបច្ចេកទេសសូវៀតរាល់ថ្ងៃហ្នឹង។ វិទ្យាស្ថានបច្ចេកទេសសូវៀតរាល់ថ្ងៃហ្នឹង។

**ស៖** តើ<នរណាជាអ្នកបង្រៀន>វគ្គរៀនសូត្រនយោបាយ<ដែលលោកចូលរួមរៀន>នៅក-១៥<សាលាបច្ចេកទេសសូវៀត ហ្នឹង?>

**ឆ៖** ឈ្មោះ តាភុំ ជំនាន់នុ៎ង គេសហៅសមមិត្តភុំ។ គាត់មាឧល្អិត កម្ពស់គាត់ប្រហែលមួយម៉ែត្រហាជាង ហុកអីហ្នឹង ប៉ុណ្ណឹង។ មុខញញឹមជាប់។ សម្តីស្រទន់ ពីរោះ។ អរគុណ។ គាត់ឈ្មោះ ភុំ។

**ស៖** តើតាភុំ នុ៎ងមានតួនាទីអ្វីដែរ បើលោកដឹងសូមជួយប្រាប់ផង?

**ឆ៖** ខ្ញុំអត់ដឹងពីតួនាទីគាត់ទេ សម័យនុ៎ង គេលាក់ការណ៍ណាស់តួនាទី ចៀសវាងតែប្រធានយើង ក៏ប៉ុន្តែខ្ញុំដឹងថា គាត់ជាគ្រូៗបង្រៀននៅសាលា ក-១៥ហ្នឹង – ដឹងថាគាត់ជាគ្រូបង្រៀននៅសាលា ក-១៥ហ្នឹង តែមិនដឹងគាត់មានឋានៈតួនាទីក្នុងជួរបក្សនុ៎ង ខ្ញុំមិនអាចដឹងទេ ថាគាត់ហ្នឹងឋានៈជាអ្វីនោះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកសហព្រះរាជអាជ្ញារង។

ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ដើម

បណ្តឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និង ឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៤ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៥៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិដើម្បីបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអភ័យទោសដោយសារមានបញ្ហាបច្ចេកទេសបន្តិចបន្តួចលោកប្រធាន។ គឺថាចម្លើយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលព្រះរាជអាជ្ញាបានលើកឡើងគឺហាក់ដូចជាមានលេខ <E3> ចំនួនពីរ គឺE3/4596មួយ ហើយនិងលេខមួយទៀតដែលព្រះរាជអាជ្ញាបានបង្ហាញគឺ E3/5783។ ប្រសិនបើដូច្នេះមែនថាតើយើងគួរប្រើឯកសារE មួយណាសម្រាប់ចម្លើយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានេះ។

**លោក ឌេល លីសាក់៖**

ខ្ញុំអត់បានដឹងអំពីបញ្ហានេះទេ។ ខ្ញុំអត់បានដឹងថាតើមានឯកសារមួយទៀតដែលមានលេខ E3/4596នោះទេ គឺយើងបានដាក់នៅលើអ៊ីនធឺហ្វេស តែលេខឯកសារដែលខ្ញុំបង្ហាញ គឺ E3/5783 ប៉ុណ្ណោះ។ ខ្ញុំជឿជាក់ថាឯកសារE3/5783 គឺជាអ្វីដែលយើងបានដាក់នៅក្នុងសំណុំរឿង ហើយគាត់បានដាក់ភ្ជាប់ជាមួយនឹងបណ្តឹងរបស់គាត់ ហើយវាជាការសម្ភាសជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាដែលជាឯកសារភស្តុតាង ហើយខ្ញុំគិតថាឯកសារហ្នឹង គឺឯកសារE3/5783។

[១៥:០៤:០៨]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<មន្ត្រីកំពុង>តែពិនិត្យ។ <>ដូច្នេះសូមលោកបន្តទៅមុខទៀតចុះ <ជាមួយលេខឯកសារនេះរហូតដល់ពេលមានការបញ្ជាក់ជូននាពេលខាងមុខ>។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** យើងបាននិយាយអំពី តាភុំ គឺជាអ្នកបង្រៀនវគ្គនយោបាយនៅ ក-១៥។ តើលោក១នៅបាន<ឃើញ> តាភុំ ក្រោយវគ្គនយោបាយនោះដែរឬទេ គឺនៅ<ដើម>ឆ្នាំ៧៦ដែរទេ? តើនៅក្នុងឆ្នាំ៧៧ ៧៨វិញ តើមានអីកើតឡើងដែរចំពោះ តាភុំ នោះ?

**លោក ស សារិន៖**

**ឆ៖** តាភុ -- មិនមែន តាភឹម ទេ មានតែ តាភួម លោកសហមេ -- ព្រះរាជអាជ្ញា មិនមែន តាភឹម តាភួម។ ក្រោយមកទៀតបាត់គាត់អត់ឃើញទៅរៀនទេ ហើយក៏មិនដឹងគាត់ទៅណាមកណាដែរ។ យើងក៏មិនហ៊ានសួរនាំ ឃើញគាត់បង្រៀនតែមួយសាហ្នឹង។ ហើយក្រោយមកខ្ញុំបានជូនភ្ញៀវថ្នាក់កម្មាភិបាលមកពីតាមគ្រប់ភូមិភាគហ្នឹង ដើរទស្សនកិច្ចជុំវិញស្រុកខ្មែរហ្នឹងក្រោយពីរៀនសូត្រ រៀនសូត្រហ្នឹងនៅបុរីកីឡា ប៉ុនចប់វគ្គរៀនសូត្រហ្នឹងទៅគេមានឲ្យដើរសិក្សារៀនសូត្រពីគ្នាទៅវិញទៅមក ពីការរីកចម្រើនពីភូមិភាគមួយទៅភូមិភាគមួយហ្នឹងជួបគាត់ គាត់អ្នក១ជូនដំណើរ។ គណៈប្រតិភូថ្នាក់ដឹកនាំជុំវិញមជ្ឈិមហ្នឹងដើរហ្នឹង គឺគាត់អ្នកដើរតែក្រោយមកហ្នឹងមិនដឹងគាត់បាត់ខ្លួនទៅណា ប្រហែលជាបក្សកុម្មុយនីស្តកម្ពុជាត្រូវបោសសម្អាតដែរ មិនដឹងអីមិនដឹងបាត់រហូត។ អរគុណ។

**ស៖** ហេតុផលដែលខ្ញុំសួរលោកនេះ គឺថានៅក្នុងបញ្ជីស-២១ ដែលរៀបចំឡើងដោយខាង<ការិយាល័យសហចៅក្រមស៊ើបអង្កេត> គឺលេខ 4723 គឺនៅត្រង់បញ្ជីនោះគឺមានឈ្មោះ ម៉ៅ ខែម នឿន ហៅ ភុំ ដែលគេកំណត់ថាជាអនុលេខាស-៧១ ដែលចូលស-២១ នៅថ្ងៃ០៥ មេសា ១៩៧៧។ ហើយខ្ញុំក៏សូមកត់សម្គាល់ផងដែរថាចម្លើយសារភាពស-២១ របស់គាត់គឺមាននៅក្នុងឯកសារភស្តុតាង E3/1859 នៅទំព័រខាងលើគឺគេបញ្ជាក់ថា គាត់ជាអនុលេខារបស់សាលានយោបាយ។ លោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំចង់ដឹងថាតើលោកស្គាល់ឈ្មោះពេញរបស់ តាភុំ ទេ? ហើយតើអាចទេថានៅក្នុងអំឡុងខែមេសា ៧៧ គឺតាភុំ បានបាត់ខ្លួន?

[១៥:០៨:២២]

**ឆ៖** សូមគោរពលោកប្រធាន សូមគោរពលោកសហព្រះរាជអាជ្ញា ខ្ញុំអត់ស្គាល់ឈ្មោះគាត់ពេញទេ សម័យហ្នឹងយើងអត់មានដឹង ដេញដោលថា បងឯងឈ្មោះដើមឈ្មោះអី ឈ្មោះបដិវត្តន៍ឈ្មោះអី អត់មានសិទ្ធិដេញដោលអីចឹងទេ ឮប៉ុនណាយើងចាំទុកតែប៉ុណ្ណឹងឯង។ សូមអរគុណ។

**ស៖** ហើយខ្ញុំចង់សួរសំណួរទី២ ចំពោះលោកគឺថា តាមបញ្ជីស-២១ គាត់ចូលនៅខែមេសា ឆ្នាំ

១៩៧៧ តើ -- ក្នុងអំឡុងពេលហ្នឹងឬដែលគាត់បាត់ខ្លួននោះ?

**ឆៈ** ខែមេសា ៧៧ ប្រហែលហើយ។ ព្រោះខ្ញុំរៀនវគ្គដំបូងនៅចុង៧៥ បាទចុង៧៥ ខ្ញុំទៅរៀន គាត់បង្រៀនៗខ្ញុំនៅសាលាបច្ចេកទេសសូវៀតហ្នឹង ប៉ុនបង្រៀនអត់ដូចអ៊ំជនជាប់ចោទទាំងពីរហ្នឹងទេ។ ឯកសារខ្លឹមសារគាត់បង្រៀនកាលហ្នឹង ខ្ញុំនៅចាំបង្រៀនអំពីច្បាប់សម្ភារនិយមបដិច្ចសមុប្បាទ អ្វីៗតែងតែទាក់ទងនឹងគ្នា អ្វីៗដូចថាការប្រើប្រាស់រមែងតែងតែរេចរឹលអ៊ីចឹង ក្នុងន័យច្បាប់សម្ភារៈបដិច្ចសមុ-ប្បាទហ្នឹង ហើយសំដៅធ្ងន់បំផុតសម័យនោះ គឺកម្ចាត់កម្មសិទ្ធឯកជន ដើម្បីបន្តធ្វើបដិវត្តន៍សង្គមនិយមហ្នឹង គាត់ថាត្រូវកម្ចាត់កម្មសិទ្ធិឯកជន កម្មសិទ្ធិយើងម្នាក់ៗ។ ខ្ញុំចាំបានន័យគាត់ថា កម្មសិទ្ធិរបស់សមមិត្តម្នាក់ៗ គឺមានតែស្បោងមួយតូច គឺខោអាវពីរកំប្លេហ្នឹងឯង អត់មានឲ្យមានអីច្រើនទេ។ រួចព្រោះអ៊ីចេះ បានគាត់លើកឡើងអ៊ីចឹង ធម្មតាយើងនៅជនបទមិនដែលឃើញសម្ភារៈអីច្រើន ពាសពេញសម្បូរបែប សម្បូរហូរហៀរ យើងនិយាយថាអ៊ីចឹងចុះ។ រួចម្នាក់ៗ និយាយពីសង្វាត សឹងថាដាក់ ច្រើនណាស់ ប្រមូល អាខ្លះ អាប្រជាជនភ្នំពេញរត់ចេញអស់ទៅ ខ្លះខោអាវ ខ្លះរបស់របរ ប្រើប្រាស់ទៅប្រមូលម្នាក់ៗឲ្យតែបានអង្គការឲ្យទៅលេងស្រុក យកទៅផ្ញើបងប្អូន។ តាំងពីវិទ្យុ តាំងពីម៉ាញេ តាំងពីចានឆ្នាំង របស់ប្រើខោអាវអីហ្នឹង រួចដល់ទៅប្រជុំគាត់ថា យើងត្រូវកម្ចាត់អាហ្នឹងអត់ឲ្យមានទេ។ ដល់មកបង្រៀនវិញ នាំគ្នាយកដាក់ឃ្លាំងខ្ទេចអត់មានសល់ទេ។ អាហ្នឹងខ្ញុំចាំន័យគាត់បង្រៀនហ្នឹងជាងគេ។ រួចដល់ទៅ ប្រហែលជាខែ១១ ប្រហែលខែ១០ ខែ១១ ខែស្រូវចេញ យើងច្រូតហើយណា ១១ហ្នឹង មករៀនកម្មាភិបាលថ្នាក់តូចត្រឹមមេឃុំ គេហៅគណៈសង្កាត់ ជំនាន់នោះគេអត់ហៅមេឃុំទេ គេថាពាក្យសក្តិភូមិ។ គណៈសង្កាត់ហ្នឹងគេឡើងមករៀននៅមជ្ឈិមហ្នឹង និងសហករណ៍គំរូជាច្រើននៅទូទាំងប្រទេសហ្នឹង។ ដល់រៀនចប់ទៅ ខាងខ្ញុំ ក-១២ ដឹកដើរទស្សនកិច្ចៗ គ្រប់ភូមិភាគ ប្រមាណប្រហែលកន្លះខែ ប្រហែលកន្លះខែ ប្រាំមួយ ប្រាំពីរដណ្ដប់ថ្ងៃ ប៉ុណ្ណឹង។ រួចគាត់ហ្នឹង អ្នកដឹកនាំជូនគណៈប្រតិភូទាំងអស់ហ្នឹងដើរ ខ្ញុំបានដឹកគាត់បានមួយថ្ងៃដែរជាមួយបងវុយ។ គាត់អង្គុយក្រោយ បងវុយ កាន់តែអ្វូ។ ខ្ញុំបើកអាលីប អាជី កាលហ្នឹង។ រួចទៅដល់ភូមិភាគឧត្តរទៅ បងហួន នោះគាត់ឈឺ បងវុយ ឲ្យខ្ញុំមកបើកឡានហ្សេ.អឹម.សេ វិញទៅ។ បែកពីគាត់មិនសូវឮពាក្យពេចន៍សម្ដី គាត់ប៉ុននិយាយណាស់អ៊ំហ្នឹង។ គិតទៅ ត្រឹមខែ មើលយើងដើម ថាដើមឆ្នាំ៧៧ចុះ ដែលខ្ញុំបានជួបគាត់ហ្នឹង រួចដល់ទៅខែមេសា ហ្នឹងវាបួនខែក្រោយមកទៀត។ លោកសហព្រះរាជអាជ្ញាថា គេចាប់ដាក់ស-២១ ហ្នឹងប្រហែលជាត្រូវហើយ ព្រោះខ្ញុំបាត់គាត់តាំងពីហ្នឹងមក ក៏ខ្ញុំមិនដែលជួបគាត់ដែរ។ មករៀនវគ្គៗក្រោយទៀត ក៏អត់ៗដែលជួប

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

គាត់ដែរ គាត់ប៉ិននិយាយៗដូច អ៊ំនួន អ៊ីចឹង បើនិយាយពីទ្រឹស្តីគាត់សម័យនោះ។ សូមអស់យោបល់។

[១៥:១៤:២០]

**ស៖** សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ លោកបាននិយាយអំពីអ្វីដែលខ្ញុំប្រុងនឹងសួរលោកបន្ទាប់នេះដែរ គឺថា និយាយអំពីការនាំមនុស្សដើរមើលនៅកន្លែងនេះ កន្លែងនោះ នៅក្នុងប្រទេស ហើយលោកបាននិយាយអំពីរយៈពេលនៅក្នុងខែវិច្ឆិកា ៧៦ ដែលនៅពេលនោះ លោកនៅក្នុងក្រុមអ្នកបើកបរដឹកកម្មាភិបាលនៅទូទាំងប្រទេស។ តើលោកអាចប្រាប់តុលាការបានទេ តើលោកចាំថា លោកធ្វើដំណើរទៅតំបន់ណាខ្លះ? ថាតើលោកដឹកកម្មាភិបាលភូមិភាគទៅផ្នែកណាខ្លះក្នុងប្រទេស នៅក្នុង<ខែវិច្ឆិកា> ឆ្នាំ៧៦ នោះ?

**ឆ៖** អរគុណ។ ដំបូងចេញសាលាហ្នឹងទៅ ភ្ញៀវច្រើនដែរ ឡានក-១២ ដឹកអត់អស់ទៀត។ ទៅស្នើខាងគេហៅអង្គភាពដឹកជញ្ជូនជើងគោក ប្រហែលជា១០គ្រឿងមកទៀត។ រួចយើងដើរទស្សនកិច្ចកាលនុ៎ង អាឡានក្រុងនុ៎ងក៏ជិះមិនគ្រប់គ្នាដែរ អាក្របាមៗហ្នឹងមានតែប្រហែលប្រាំពីរប្រាំបីប៉ុណ្ណឹងទេ។ រួចដល់តែទីជនបទ ចុះអត់រួច។ អ៊ីចឹងនៅលើហ្នឹង បងវុយហ្នឹង គាត់ឲ្យដើរតាមតាមផ្ទះ រកពួកយើង អាពួកយើងហ្នឹង យកទៅរៀបពេញខាងក្រោយហ្នឹងទៅ។ ហើយយើងរកកន្ទេលក្រាលទៅឲ្យគាត់អង្គុយតាមក្រុម តាមកងគាត់ទៅ។ ចេញដំបូងទៅភូមិភាគបូព៌ា។ ចេញទៅខាងស្វាយរៀង ឡើងពីអ្នកលឿងទៅស្វាយរៀង។ រួចដល់ស្វាយរៀងហ្នឹង ធ្វើស្រូវ ធ្វើស្រែកើតណាស់ យើងជំនាន់នុ៎ង ស្រូវផ្លែឡើង អើខែនុ៎ង ខែផ្លែ ខែច្រូតស្រូវផងនោះ ស្រូវល្អណាស់។ រួចទៅដល់ស្រុកមួយ កាលហ្នឹងបក្សយើងគាត់លើកឡើងថាបក្សយើងឲ្យទង់កិត្តិយសដល់ស្រុក មើលស្រុកប្រសូត្រយ៉ាងអាហ្នឹង ស្រុកប្រសូត្រអ៊ីចឹងហើយតំបន់២៣ ស្រុកប្រសូត្រ ខេត្តស្វាយរៀងហ្នឹង។ ឲ្យទង់កិត្តិយសដល់ខេត្តហ្នឹងដែលជា -- ដល់ស្រុកហ្នឹងដែលជាស្រុកទន់ខ្សោយពីមុនមក គាត់ហៅសិក្ខាកាមទាំងអស់ហ្នឹងថា យើងគួររៀនសូត្រពីគំរូស្រុកប្រសូត្រហ្នឹង ព្រោះស្រុកហ្នឹងជាស្រុកទន់ខ្សោយ ធ្វើស្រែពីដើមមកគ្មានបានផលអីទេ ឥឡូវខាងស្រុកនុ៎ងគេធ្វើកើត។ យើងយកតម្រាប់ស្រុកហ្នឹង។ ឯស្រុកយើងសម្បូរដីជាតិត្រូវប្រឹងឲ្យធ្វើលើសស្រុកហ្នឹង ភូមិភាគបូព៌ាហ្នឹង បានទង់កិត្តិយសពីបក្សកុម្មុយនីស្តកម្ពុជាហ្នឹងមួយ ភូមិភាគបូព៌ា។ គេឲ្យស្រុកហ្នឹងជាគំរូ។

[១៥:១៨:១០]

ចេញពីនុ៎ងមក ផ្លាយតាមប្រឡាយព្រែកជីកមួយពីស្រុករមាសហែកចេញមកខាងកំចាយមា

ចេញមក បើមកផុតប្រឡាយហ្នឹងមើលឃើញព្រៃកៅស៊ូ ខាងស្រុកខ្ញុំត្បូងឃ្មុំហ្នឹង។ រួចបានបកពីហ្នឹងទៅៗ ព្រៃវែង ល្ងមទៅដល់ព្រៃវែងហ្នឹង មើលប្រឡាយព្រែកជីកហ្នឹង ទម្រាំដល់ព្រៃវែងហ្នឹងយប់ បានទៅដេកក្រុងព្រៃវែងហ្នឹងមួយយប់។ រហូតព្រលឹមឡើង ទៅទស្សនកិច្ចវាលស្រែនៅខាងកើតក្រុងព្រៃវែងហ្នឹង និងទំនប់ប្រឡាយ ប្រព័ន្ធភ្លឺស្រែជំនាន់ហ្នឹង ស្រូវល្អណាស់។ ចេញពីហ្នឹងទៅ បានឡើងទៅអូររាំងឪ ទៅទស្សនកិច្ចនៅខាងស្រុកកំណើតខ្ញុំហ្នឹង ខាងស្រុកត្បូងឃ្មុំហ្នឹង ទៅទស្សនកិច្ចនៅសហ-ករណ៍ឃុំសន្ទប់ ស្រុកត្បូងឃ្មុំ តំបន់២១ហ្នឹង មើលការរីកចម្រើនហ្នឹង បានយប់ឡើង ដេកនៅហ្នឹង ហេ! មើល៍ចេញពីនុំងមក មកទស្សនកិច្ចចម្ការកៅស៊ូ ចម្ការកៅស៊ូយើងជប់ហ្នឹង។ បាន--

**ស៖** សូមទោស ខ្ញុំសូមកាត់លោកបន្តិច លោកដើមបណ្ដឹង។ ឥឡូវនេះ ខ្ញុំគិតថា ជាងការដែលលោករៀបរាប់គ្រប់កន្លែងទាំងអស់។ ខ្ញុំចង់ឱ្យលោករៀបរាប់វិញ ថាតើលោកបានទៅតំបន់ ឬក៏ទៅខេត្តណាខ្លះ ហើយបន្ទាប់មកទៀត ខ្ញុំនឹងសួរលោកលម្អិតទៅលើចំណុចមួយៗ ប្រសិនបើមានភាពពាក់ព័ន្ធនោះ។ ដូច្នេះ ខ្ញុំចង់ឱ្យលោកប្រាប់ថា តើលោកបានទៅខេត្តណាខ្លះ ឬក៏ទៅភូមិភាគណាខ្លះវិញ?

**ឆ៖** អរគុណ។ ទៅហ្នឹង គឺទៅបើសង្ខេបអ៊ីចឹង គឺមានភូមិភាគបូព៌ា ភូមិភាគកណ្ដាល ចេញពីភូមិភាគកណ្ដាលទៅ ទៅតំបន់សៀមរាប ឧត្តរមានជ័យ។ ចេញពីសៀមរាប ឧត្តរមានជ័យទៅ ទៅមើលអង្គរវត្ត ទៅមើលអង្គរវត្តដែរ។ គ្រាន់តែដើរមើលអង្គរវត្តនុំងមួយថ្ងៃដែរ។ ចេញពីហ្នឹងទៅ ទៅអាងទឹកត្រពាំងថ្ម ភូមិភាគពាយ័ព្យ អាងទឹកកំពីងពួយ -- ហេ! មើល៍ត្រង់នឹងកំពីងពួយអត់ទាន់បានទៅមើលទេ គេទើបនឹងធ្វើទេ មិនទាន់ទេ ក្រោយមកទៀតទេ។ រួចមកភូមិភាគបស្ចិមៗរួច មកនិរតី។ ភូមិភាគនិរតី ចេញពីតាកែវចូលកំពត ចេញទៅកំពង់សោមនោះ បាននាំគ្នាជិះកប៉ាល់សមុទ្រ ទៅដើរមើលឆ្នេរសមុទ្រនុំង រួចទៅបកមកវិញ មកភូមិភាគបស្ចិមខាងកំពង់ស្ពឺនោះ ទៅមើលទំនប់នៅជិតភ្នំឱរ៉ាល់នោះ។ ទំនប់អីទេ ខាងគណៈតំបន់៣២ហ្នឹង គេនាំទៅ។ រួចពីហ្នឹងទៅ បកមកច្បារមនវិញ ចូលក្រុងភ្នំពេញចប់ទស្សនកិច្ច។ សូមអរគុណ។

[១៥:២២:៣២]

**ស៖** សូមអរគុណចំពោះការរៀបរាប់របស់លោក។ ឥឡូវនេះ ខ្ញុំសួរលោកអំពីការធ្វើដំណើរវិញ តើលោកបានជួបជាមួយនឹងលេខាពាយ័ព្យឈ្មោះ រស់ ញឹម ដែរឬទេ នៅពេលដែលលោកធ្វើដំណើរទៅទីនោះ? ហើយប្រសិនបើលោកបានជួបគាត់ តើលោកចាំអីខ្លះអំពី រស់ ញឹម ដែលជាលេខាភូមិភាគពាយ័ព្យនោះ?

**ឆ៖** ខ្ញុំបើនៅដឹក តាភុំ បានឮគាត់និយាយហើយ ក្បួនឡានវាវែងពេក ដល់ទៅរាប់រយគ្រឿងណោះ ហើយគាត់ទទួល គាត់មកទទួលនែ៎នៅជិតក្រឡាញ់នេះ ចេញពីតំបន់សៀមរាប ឧត្តរមានជ័យហ្នឹងទៅ មានព្រំប្រទល់ភូមិភាគពាយ័ព្យ និងតំបន់សៀមរាប ឧត្តរមានជ័យ។ គាត់ជិះឡាន គាត់អាហ្ស៊ីបមួយដែរ មកចាំទទួលនៅហ្នឹង ហើយកងការពារគាត់ម្នាក់ពីរ អ្នកបើកឡានហ្នឹង។ ទទួលក្បួនឡានគណៈប្រតិភូនុំងមកដល់ គាត់ក៏ជួបសំណេះសំណាល ខ្ញុំក៏នៅឆ្ងាយដែរ ចង់ប្រហែលជា៥០០ម៉ែត្រ ១គីឡូនោះ ប៉ុន្តែដឹងថា គាត់មកទទួលៗចេញពីត្រង់ហ្នឹងទៅ ទៅស៊ីសុផុន១ ដេកនឹងស្វាយស៊ីសុផុនហ្នឹង គេហៅស្វាយស៊ីសុផុនត្រង់ហ្នឹង កន្លែងបន្ទាយមានជ័យរាល់ថ្ងៃហ្នឹង គេអត់ហៅបន្ទាយមានជ័យទេ គេហៅ ស្វាយស៊ីសុផុន។ នៅដេកនឹងហ្នឹងមួយយប់ បានព្រលឹមឡើងចេញដំណើរទៅទៀត។ អត់បានឮអីទេ គ្រាន់តែឃើញរូបរាងគាត់។ បាទ ដល់ក្រោយមកទៀតទេ ដំណើរក្រោយៗមកទៀតទេ ខ្ញុំធ្លាប់ជួបគាត់នោះ។ ខ្ញុំជូនភ្ញៀវ ទៅដឹកសម្ភារៈអីៗផ្សេងៗអីចឹង ទៅជួបគាត់នោះ។ សូមអរគុណ។

[១៥:២៤:៣៨]

**ស៖** លោកបានបញ្ជាក់ថា នៅពេលដែលលោកធ្វើដំណើរហ្នឹង គឺនៅចុងឆ្នាំ៧៦ ហើយលោកនាំក្រុមកម្មាភិបាលជាច្រើននាក់ទៅទូទាំងប្រទេស ហើយលោកបាននិយាយអំពីការដឹកនាំភ្ញៀវបរទេសទៅតាមខេត្តផងដែរ។ នៅពេលដែលលោកធ្វើដំណើរទៅខេត្ត តើលោកមានសង្កេតឃើញមានប្រជាជនថា តើពួកគាត់មានសុខភាពល្អ ឬក៏មានអាហារហូបចុកគ្រប់គ្រាន់អីដែរឬទេ?

**ឆ៖** ពេលទៅទទួលភ្ញៀវអីចឹងឃើញតែមកគគ្រឹកគគ្រេង សប្បាយដូចធ្វើបុណ្យអីចឹង ព្រោះយើងគណៈប្រតិភូទៅនោះ អីចឹងគេអត់មានឲ្យទៅមើលរឿងកន្លែងអាក្រក់ទេ រួចអារឿងអត់បាយអត់អីហ្នឹងអត់ដឹងទេ ព្រោះយើងគេអត់ឲ្យទៅមើលអាកន្លែងសហករណ៍ហ្នឹងផង គេឲ្យតែទៅមើលការបោកបែន ការច្រូតកាត់ ការអភិវឌ្ឍ មានម៉ាស៊ីនបោកស្រូវអីចឹង ឲ្យរៀនសូត្រធ្វើម៉ាស៊ីនហ្នឹងតាមគ្នា ជំនាន់ហ្នឹង ឃើញអភិវឌ្ឍខាងកសិកម្មហ្នឹង ខាងម៉ាស៊ីនបោកស្រូវហ្នឹង ចេញដំបូង។ មានអាស្រ័យប្រវត្តិ មានអាពាក់កណ្តាលស្វ័យប្រវត្តិ គេឲ្យសិក្សាពីគ្នាទៅវិញទៅមកអីចឹង ហើយមានអាម៉ាស៊ីនរោយ អីចឹងទៅមានកង្ហារបក់ទៅ ពីរបីសណ្ឋាន។ គេឲ្យរៀនសូត្រពីគ្នាទៅវិញទៅមកដើម្បីយកគំរូធ្វើតាមគ្នាឲ្យមានភាពជឿនលឿន កុំឲ្យពិបាកដើរបញ្ឆោន់នឹងក្របី បោកនឹងដៃអីចឹង ខ្ញុំចាំ។ បាទ អរគុណ។

[១៥:២៦:៤៩]

**ស៖** ឥឡូវនេះខ្ញុំសួរអំពីចម្លើយរបស់ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាវិញម្តង គឺ E3/5378,

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01377301





ខ្មែរមានលេខ <00482800>, <អង់គ្លេស 00739532,> បារាំង <00746479> ដូចលោកបានប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា៖ “ខ្ញុំមិនដឹងថាមាន<ការខ្វះខាតអាហារ> ដោយសារតែនៅពេលដែលអង្គការសម្រេចឱ្យខ្ញុំទៅម្នាក់ឯងតាមឡាន ខ្ញុំឈប់នៅតាមផ្លូវ ហើយភាគច្រើនពួកគេមកសុំអាហារពីខ្ញុំ”។ តើលោកអាចប្រាប់បានទេថាតើលោកជួបហេតុការណ៍ហ្នឹងនៅកន្លែងណា គឺនៅពេលដែលប្រជាជនមកឃាត់ឡានលោក ហើយសុំម្ហូបអាហារពីលោកនោះ?

**ឆ៖** កាលហ្នឹង ខ្ញុំទៅនៅកំពង់ចាមហើយ រួចដល់ រួចទៅខ្ញុំមកពីកំពង់ចាមវិញហ្នឹង ឈប់ហូបបាយនឹងថ្នល់កែងហ្នឹង ប្រជាជនគាត់ឃើញ អាហ្នឹងគាត់សុំបាយខ្ញុំហូប ខ្ញុំឱ្យគាត់ហូបទាំងអស់ទៅ។ ហើយនិងទៅតាមជំនាន់ដឹកភ្ញៀវ ក៏ត្រង់ហ្នឹងម្តងដែរ ត្រង់ហ្នឹងមានដើមឈើ ម្លប់ឈើមួយ ខ្ញុំតែងតែឈប់នៅត្រង់ហ្នឹងឱ្យតែមកឈប់ហូបបាយហ្នឹងហើយ ហើយឃើញគាត់ខ្វះខាត ភាគច្រើននៅតាមផ្លូវហ្នឹង ស្គមៗ រួចគេធ្វើថ្នល់អីហ្នឹង សុទ្ធតែកុមារយកទៅធ្វើថ្នល់ជាតិជំនាន់ហ្នឹង ប្រហែលអាយុ ៨-១០ឆ្នាំហ្នឹង មានក្រុមកុមារគេធ្វើផ្លូវជាតិ មានមេគេហ្នឹងធំៗឱ្យគ្នាគាស់កាយតាមផ្លូវហ្នឹងពីថ្នល់កែង មកព្រែកក្តាមហ្នឹង បាទ។

**ស៖** សូមអរគុណ លោកដើមបណ្តឹងរដ្ឋប្បវេណី។ លោកនៅព្រឹកមិញនេះ លោកបាននិយាយអំពី គឺថា អំពីការដឹកជញ្ជូនភ្ញៀវបរទេសទៅកាន់កន្លែងជាច្រើន។ មុនពេលដែលលោកទទួលការងារដំបូងរបស់លោក <ខ្ញុំគិតថា គឺទទួលគណៈប្រតិភូភូមា> តើលោកធ្លាប់ទទួលការបណ្តុះបណ្តាលពី អៀង សារី ដែរឬទេ ថាតើៗគាត់មានបណ្តុះបណ្តាល ឬក៏ណែនាំលោកអំពីថាតើត្រូវធ្វើយ៉ាងម៉េចជាមួយភ្ញៀវបរទេសហ្នឹងដែរទេ? គឺថាខ្ញុំចង់សួរថាលោកធ្លាប់រៀនសូត្រជាមួយ អៀង សារី ដែរឬទេ?

[១៥:៣០:០២]

**ឆ៖** ដំបូងឡើយការដឹកភ្ញៀវបរទេសហ្នឹង អត់ទាន់បានរៀនសូត្រអីទេ។ ដល់ក្រោយមកមានទទួលថ្នាក់ប្រធានាធិបតី បីប្រទេសផ្សេងៗគ្នាហ្នឹង អ៊ំ អៀង សារី ហ្នឹងគាត់មានគោលនយោបាយថ្មី ហៅទៅរៀននៅមន្ទីរប-១ មន្ទីរប-១ ហ្នឹងមានបរិវេណកន្លែងគណៈរដ្ឋមន្ត្រីរាល់ថ្ងៃហ្នឹង មកលិចដល់ប្រើសពីរ សត្វប្រើសមួយគូតាមផ្លូវជាតិហ្នឹង ហើយនិងផ្លូវកម្ពុជាក្រោមហ្នឹង សុទ្ធតែគេហៅបរិវេណប-១ ហើយហ្នឹង។ មានកន្លែងផ-១ បន្តិចទេត្រង់ហ្នឹង កន្លែងផលិតថ្នាំខាង អ៊ំអៀង ធីរិទ្ធ ខាងប្រពន្ធគាត់ហ្នឹង អាហ្នឹងរបស់ខាងសង្គមកិច្ច។

គាត់ឱ្យទៅរៀនកាលហ្នឹងគាត់ក្នុងន័យគាត់ គាត់និយាយថា បក្សយើងទទួលភ្ញៀវបរទេសថ្នាក់

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ប្រធានាធិបតីមកទស្សនកិច្ចជាផ្លូវរដ្ឋ។ អ៊ីចឹងយើងទាំងអស់គ្នាឈប់ស្លៀកពាក់ខ្មៅ និងពាក់អាវស៊ីម្ពី។ កាលហ្នឹងមានស៊ីម្ពីមកពីចិននោះ ឯកសណ្ឋានទាហានហ្នឹង ហើយនិងខោអាវត្រួយចេក ពណ៌ត្រួយចេក ដូចប៉ូលិសទៀតទៅ យើងទៅផ្សារអូរឫស្សីទៅឲ្យ ទៅអូរឫស្សីគ្រាន់ថាផ្សារអូរឫស្សី គ្រាន់ថាទៅអូរឫស្សីហ្នឹងដែលជាកន្លែងកាត់ដេររដ្ឋហ្នឹង នាំគ្នាកាត់ម្នាក់ពីរកំប្លេទៅ រួចស្បែកជើងគាត់ឈប់ឲ្យពាក់ស្បែកជើងកង់ឡានដែរឲ្យពាក់ ហើយមានឯកសណ្ឋានហ្នឹងដូចៗគ្នា ទាំងអ្នកបម្រើ ទាំងតែកុងឡាន មានខោហ្នឹងពណ៌ខៀវ អាវហ្នឹងពណ៌ប្រហែលដូចព្រុំហ្នឹងរាងពងមាន់ចាស់ ឯកសណ្ឋានអ៊ីចឹង ដៃវែងមួយ ដៃខ្លីមួយ ខោហ្នឹងមួយ ស្បែកជើងហ្នឹងមួយ។ ខ្ញុំកាលហ្នឹងអរណាស់ មិនដែលបានខោអាវពាក់ផង។

[១៥:៣២:៤១]

បាទ ហើយគាត់ហៅប្រជុំហ្នឹងមានបីស្ថាប័ន។ ស្ថាប័នខាងខ្ញុំបើកបរហ្នឹងមានប្រធានខ្ញុំឈ្មោះ មៀល ហ្នឹងហើយផ្នែកខាងការពារភ្ញៀវនិងការពារអ៊ំៗហ្នឹងមានប្រធានគាត់ហ្នឹងឈ្មោះ ខាំ មី។ ហើយខាងបម្រើភ្ញៀវខាងបាយទឹកហ្នឹង ខាងផ្សារខាងអីហ្នឹង គឺមានឈ្មោះ យាយស៊ីន ខាងបម្រើភ្ញៀវខាងទទួលម្ហូបហ្នឹង ហើយគាត់ណែនាំ យើងធ្វើម៉េចខាងផ្សារខាងអីដាក់ទំនិញហ្នឹងឲ្យច្រើន។ សណ្ឋាគារដែលលក់ឲ្យផ្សារបរទេស កន្លែងផ្សារបរទេស គេហៅផ្សារបរទេសជំនាន់ហ្នឹង សណ្ឋាគារសមុនហ្នឹងប៉ុនឥឡូវមិនដឹងគេដាក់ឈ្មោះអីទេ ខ្ញុំភ្លេចហើយនៅខាងកែងផ្សារថ្មីនេះ សម្រាប់ៗបរទេសទិញ និងសម្រាប់អង្គទូត។ ហើយនិងគាត់ណែនាំច្រើនដែរ អ៊ំអៀង សារី កាលហ្នឹងនិយាយពីព្រឹត្តិការណ៍ជាតិយើងពីការខ្វះខាតរបស់ប្រជាជនយើង គាត់លើកឡើងថាប្រទេសយើងទើបចប់ពីសង្គ្រាម មិនមែនសម្បូរហូរហៀរ សម្បូរស៊ីសម្បូរចុក ខ្វះសព្វខ្វះគ្រប់ ខ្វះស្បៀងខ្វះថ្នាំដង្កូវ មិនមែនសម្បូរដូចវ៉ាដ្យូផ្សាយអ៊ីចឹងទេ។ អ៊ីចឹងសមមិត្តត្រូវរួមចំណែកដើម្បីធ្វើការងារហ្នឹងឲ្យបានជោគជ័យ គាត់លើកពីព្រឹត្តិការណ៍ហ្នឹងបន្តិចដែរ ខ្ញុំនៅចាំ ត្រង់ថាមិនសូវសម្បូរហូរហៀរហ្នឹង។ បាទ រួចជំនាន់ហ្នឹងនៅមន្ទីរខ្ញុំហ្នឹងក៏ខ្វះខាតដែរ រួចជីវិតយើងបើធំរឿងឃ្លានបាយហ្នឹងហើយ តែគាត់និយាយពីរឿងៗស៊ីហ្នឹងឃ្លានហ្មង។

[១៥:៣៥:០៦]

ដូចអ៊ំៗ ខៀវ សំផន គាត់បង្រៀនអ៊ីចឹង គាត់ថា -- ខ្ញុំភ្លេចនិយាយព័ត៌មានហ្នឹង ខ្ញុំបង្ហើយបន្តិចពីរឿងថាហូបចុកជារឿងធ្វើម្ហូបមួយថ្ងៃបីមុខអីៗហ្នឹង។ ហើយការហូបចុកហ្នឹង គាត់ឲ្យហូបជាលក្ខណៈសមូហភាព ជាក្រុម ជាកង សហករណ៍តូច ជាសហករណ៍ធំ។ ហើយសហករណ៍នីមួយៗត្រូវឯករាជ្យម្ចាស់ការចេះដាំបន្លែអីហ្នឹង អត់ត្រូវដើរសុំគេទេ ពីសហករណ៍គេយកមកឧបត្ថម្ភសហករណ៍ខ្លួនទេ។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

01377303



**សៈ** បាទ ខ្ញុំសូមបញ្ចប់ការឆ្លើយរបស់លោកបញ្ហានេះត្រឹមនេះសិន ពាក់ព័ន្ធទៅនឹងការចូល <រួមប្រជុំ ឬ>រៀនសូត្រជាមួយនឹង ខៀវ សំផន។ ខ្ញុំផ្តោត<ដំបូង> ជាមួយនឹង អៀង សារី។ បើខ្ញុំយល់មិនច្រឡំទេ សក្ខីកម្មរបស់លោកហ្នឹងគឺថា អៀង សារី បាន<ដឹង និង>ប្រាប់មកលោកថា ប្រជាជននៅតាមបណ្តាខេត្តហ្នឹងគឺថា ខ្វះខាត ចំណីអាហារ និងថ្នាំសង្កូវ។ តើគាត់មានប្រាប់លោកថា ឲ្យនិយាយថា ដូចម្តេចទេ បើសិនណាជាភ្ញៀវបរទេសសួរលោកពាក់ព័ន្ធទៅនឹងការខ្វះខាតចំណីអាហារ ឬខ្វះខាតថ្នាំសង្កូវនេះ? អ៊ីចឹង តើអៀង សារី មានប្រាប់លោកថា ឲ្យលោកហ្នឹងរៀបចំពាក្យពេចន៍និយាយម៉េចទេ បើភ្ញៀវបរទេសសួរមកលោកពីរឿងនេះ?

[១៥:៣៦:៥២]

**ឆៈ** ហ្នឹង ខ្ញុំដូចអត់សូវចាំ ដូចជាភ្លេចហើយ លោកសហព្រះរាជអាជ្ញា បើរឿងថា អត់សំបូរស៊ីសម្បូរចាយ ដូចរ៉ាដូផ្សាយ អាហ្នឹងគាត់និយាយ។ បាទ រួចនិយាយទៅកាន់ភ្ញៀវអីៗហ្នឹង ដូចជាពាក្យថាគេសួររកប្រជាជនទៅណាមកណាអស់អ៊ីចឹង "ថាស្ម័គ្រចិត្តទៅបង្កបង្កើនផលអស់ហើយ"។ អាហ្នឹងមិនមែនគេ ដូចមិនមែនពាក្យអ៊ំរ៉ាន់ និយាយទេត្រង់ហ្នឹង ដូចជាប្រធានខ្ញុំទេកាលហ្នឹង។ បើភ្ញៀវឲ្យតែឡើងឡាន សួរតែម្តង។ រួចតែសួរពេក ខ្ញុំច្រើននិយាយថាអ៊ីចេះ ថាខ្ញុំជាប់បើកឡាន។ ភ្ញៀវភាគច្រើនមកចេះខ្មែរ ឡើងដូចខ្មែរមែនទែន។ ខ្ញុំ សួរពីរឿងប្រជាជន។ រួចប្រធានខ្ញុំគាត់ថា ឥឡូវបើគេសួររឿងប្រជាជនអ៊ីចឹង -- អើថាទៅប្រជុំការងារ យើងលើកឡើងប្រាប់ ភ្ញៀវសួរថាម៉េច អីថាម៉េច អ៊ីចឹងសួររឿងប្រជាជន ទៅណាអស់ហើយអ៊ីចឹង។ ទៅផ្សារ ជូនគាត់ទៅផ្សារ។ រួចទៅផ្សារ ផ្ទះជុំវិញផ្សារថ្មីស្ងាត់ជ្រងំ មានអី មានតែគេលក់អីវ៉ាន់នៅផ្សារហ្នឹង។ គាត់សួរថា ប្រជាជនទៅណាអស់បានអត់មានប្រជាជនមានតែផ្ទះទទេៗអ៊ីចឹង? ហើយកាលហ្នឹង ប្រធានខ្ញុំគាត់ឲ្យថា "គាត់ស្ម័គ្រចិត្តទៅបង្កបង្កើនផលនៅទីជនជនបទអស់ហើយ" បើគាត់សួររឿងប្រជាជននោះ។ បើសួរពេលបើកឡាន យើងថាយើងជាប់បើកឡានហ្នឹង មិនបាច់និយាយច្រើនទេ។ អាហ្នឹងខ្ញុំចាំពាក្យត្រង់ហ្នឹងដែរ។ ភ្ញៀវឆ្ងល់ដែរហ្នឹងណាមកឃើញស្ងាត់ គាត់សួររកមនុស្សទៅណាអស់ ដូចភ្ញៀវឡាវអីៗ ចេះខ្មែរឡើងច្បាស់ៗ។ សូមអរគុណ។

[១៥:៣៩:១១]

**សៈ** ខ្ញុំសូមសួរលោកចំពោះចម្លើយដែលលោកឆ្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាគឺ ឯក-សារ E3/5784, 00428812 , អង់គ្លេស 00739544, បារាំង 00746487 លោកបានឆ្លើយ សូមដកស្រង់៖ "នៅក្នុងអង្គប្រជុំ គេប្រាប់ខ្ញុំឲ្យឆ្លើយថា ប្រជាជនហ្នឹងគឺស្ម័គ្រចិត្តទៅធ្វើកសិកម្មនៅតាមជនបទ

01377304



ហ្នឹង បើមានគេសួរខ្ញុំពីសំណួរនេះ។ សួរ៖ អ្នកណាប្រាប់ឲ្យលោកត្រៀមឆ្លើយបែបនេះ? ឆ្លើយ៖ គឺប្រធានមន្ទីរ ប្រាប់យើងឲ្យឆ្លើយបែបនេះ បើសិនណាជាភ្ញៀវសួរយើង។ យើងត្រូវនិយាយប្រាប់គេអំពីរឿងល្អៗ ទោះបីជាការពិតវាមានរឿងមិនល្អក៏ដោយ"។ បញ្ចប់ការដកស្រង់។ តើអ្នកណាជាប្រធានមន្ទីរនោះ ដែលប្រាប់មកលោកឲ្យត្រៀមឆ្លើយរបបនេះ?

**ឆ៖** សូមអរគុណ។ គឺ បងមៀល ប្រធានមន្ទីរខ្ញុំហ្នឹង។ អាហ្នឹងគាត់មិនដឹងជាបានពាក្យពេចន៍ពីខាងលើមក ហើយក៏គាត់ប្រឌិតខ្លួនគាត់អីមិនដឹងទេ ខ្ញុំក៏មិនដេញដោលដែរ។ ពេលប្រជុំនុ៎ង ខ្ញុំលើកឡើងពីរឿងថា គេសួរពីរឿងភ្ញៀវមក ហើយមានប្រតិកម្ម មានការងារអីជាគុណសម្បត្តិ ជាគុណវិបត្តិក្រែងលោយើងម្នាក់ៗបានធ្វើខុសឆ្គងទៅលើភ្ញៀវអី យើងដើម្បីកែប្រែរកការរីកចម្រើនម្តងៗហ្នឹង ព្រោះប្រជុំក្រោយពេលនេះហ្នឹង ប្រជុំរាល់ថ្ងៃណោះ ប៉ុនប្រធានបទហ្នឹងដល់និយាយទៅ ថាឆ្លងទៅខាង អ៊ំខៀវ សំផន បង្រៀនទៀតហើយ។ គាត់ -- ឥឡូវខ្ញុំសូមឆ្លងការងារហ្នឹងបន្តិចចុះ។ គាត់រឿងនេះហ្នឹងព្រោះការនិយាយ វាច្រើនតែភ្លេច។ ខ្ញុំអត់សួរ វាច្រើនធ្វើទុក្ខឈាមផងនោះ។ ប៉ុនដល់លោកសួរហ្នឹងមកបាននឹកឃើញរឿងអ៊ីចឹង។ ដល់នឹកឃើញ និយាយឲ្យហើយចុះ សុំទោស។ គាត់លើកឡើងអំពីថា ដើម្បីរកខ្មាំងស៊ីរូងផ្ទៃក្នុងអីៗហ្នឹង គឺយើងត្រូវឈរលើគោលជំហរទិតៀន ស្វ័យទិតៀន ដើម្បី ចំណងជើងគាត់ហ្នឹងថាម៉េចទេនេះ! ថាកុំឲ្យ "កុំឲ្យឲ្យមានខ្មាំងស៊ីរូងផ្ទៃក្នុង ដើម្បីបោសសម្អាតខ្មាំងស៊ីរូងផ្ទៃក្នុងត្រូវឈរលើគោលជំហរទិតៀន ស្វ័យទិតៀន និងតស៊ូវណ្ណៈឲ្យបានជាលជ្រោបំផុត"។ បាទ ប្រជុំពួកហ្នឹងមួយថ្ងៃ។ រួចពីការងារហ្នឹងប្រជុំដប់ម្ភៃនាទីទៅ។ រួចប្រជុំក្រុមនោះបីថ្ងៃម្តង។ ប្រជុំកងតូចនុ៎ង កន្លះខែម្តង។ ប្រជុំកងធំហ្នឹង ១៥ទៅមួយខែម្តង បើមានការចាំបាច់ យើងមួយខែអ៊ីចឹងទៅ។ អាហ្នឹងចំពោះការប្រជុំ ដើម្បីឲ្យកុំ យើងទប់ស្កាត់កុំឲ្យខ្មាំងស៊ីរូងផ្ទៃក្នុងនៅក្នុងជួរបក្ស ជួរកម្មាភិបាល កម្មករ កសិករបាន គឺត្រូវឈរលើគោលជំហរហ្នឹង។ កាលហ្នឹងគាត់បង្រៀនអ៊ីចឹង។ ខ្ញុំចាំអ៊ីចឹង។ ប៉ុនមុនហ្នឹង ខ្ញុំភ្លេច។

[១៥:៤៣:០៤]

ខ្ញុំសុំទោសលោកសហព្រះរាជអាជ្ញាផងថា ការនិយាយហ្នឹងវាឆ្លងទៅខាង អ៊ំអៀង សារីបង្រៀនមក ខាង ខៀវ សំផន បង្រៀនអ៊ីចឹង។ ប៉ុនអាហ្នឹងខ្ញុំលើកមុន ខ្ញុំអត់បានបញ្ជាក់។ រួចដូចអាកន្លែង បានដល់ អ៊ំខៀវ សំផន ហ្នឹងនិយាយពីរឿងការឧបត្ថម្ភសហករណ៍វិញហ្នឹង គាត់ថា រាល់ថ្ងៃទី១០ ថ្ងៃ២០ ថ្ងៃទី៣០ ត្រូវដែលជាថ្ងៃសម្រាកពីការងារស្នូល កាលហ្នឹងយើងអត់មានសៅរ៍ អាទិត្យទេ។ មួយខែយើងសម្រាកតែបីថ្ងៃទេ ប៉ុនសម្រាកពីការងារស្នូលមែន ប៉ុនឲ្យយើងទៅដាំបន្លែ បាទ។ ដាំបន្លែ

ដើម្បីឧបត្ថម្ភសហករណ៍ ឬសហជីពខ្លួននីមួយៗ។ ត្រូវចេះចិញ្ចឹមជ្រូក មាន់ ទា គោ ក្របី ត្រីសាច់ អត់មានទៅដើរសុំពីគេមកស៊ីទេ ត្រូវឯក -- ត្រូវម្ចាស់ការលើស្បៀង។ ហ្នឹង មុនហ្នឹងខ្ញុំភ្លេច បន្ថែមត្រង់ហ្នឹងបន្តិចចុះ។ បាទ សូមលោកសហព្រះរាជអាជ្ញា មេត្តាអធ្យាស្រ័យ បាទ សុំអស់សំណួរ។

**ស៖** ខ្ញុំនឹងមកសួរលោកពីចំណុចនេះនៅព្រឹកថ្ងៃព្រហស្បតិ៍នៅពេលចាប់ផ្តើមដំណើរការសវនាការឡើងវិញ។ ប៉ុន្តែឥឡូវនេះខ្ញុំសុំផ្តោតតែការធ្វើដំណើររបស់លោកទៅកាន់បណ្តាខេត្តនានា។ លោកបាននិយាយថា លោកធ្វើជាអ្នកបើកបរ គឺបើកបរជូននៅពេលដែលប្រតិភូចិន ដឹកនាំដោយ ឆឹង យ៉ីង គួយ ហ្នឹងមកប្រទេសកម្ពុជា។ តើលោកបានបើកបរជូនប្រតិភូចិននៅពេញផ្ទៃប្រទេសតែម្តងឬ? ហើយបើសិនណាជាបើកបរជូនពេញផ្ទៃប្រទេសអ៊ីចឹងមានបានជូនទៅទំនប់ ១មករា នៅស្ទឹងជីនិត និង នៅទំនប់ត្រពាំងថ្ម នៅភូមិភាគពាយ័ព្យនោះដែរឬទេ នៅក្នុងពេលលោកធ្វើដំណើរជូនប្រតិភូចិននោះ?

[១៥:៤៥:៤៦]

**ឆ៖** បានទៅៗ និយាយទៅដំណើរទស្សនកិច្ចរបស់សមមិត្ត ឆឹង យ៉ីង គួយ ជាមួយសមមិត្តលេខា ប៉ុល ពត ហ្នឹង ដើរដូចៗ ជូនកម្មាភិបាលតាមភូមិភាគតាមស្រុកមករៀន អ៊ីចឹង។ គ្រាន់តែអត់ទៅស្វាយរៀងទេ កាត់តាមនេះ ទៅជប់តែម្តង។ វគ្គមុនទៅដល់ស្វាយរៀង វគ្គហ្នឹងចូលពីទន្លេបិទ ឡើងទៅស្ទួង មកពីស្ទួង គ្រាន់តែលុបតែត្រង់ហ្នឹងមួយចេញទេ ក្រៅពីនុ៎ង ដើរទស្សនកិច្ចហ្នឹងដូចកម្មាភិបាលនៅក្នុងស្រុកអ៊ីចឹង។ ទំនប់១មករា ស្ទឹងជីនិតហ្នឹងក៏ទៅ ត្រពាំងថ្មនុ៎ងក៏ទៅ ទៅដូចគ្នា ប៉ុន្តែគ្រាន់ បាទ ទៅត្រពាំងថ្ម ដូចគ្នា។ ខ្ញុំនៅចាំ ហូបបាយក្រោមដើមត្នោតកាលហ្នឹង។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេ ថាលោកចាំអ្វីខ្លះអំពីការដ្ឋានទំនប់ ១មករា និង អាងទំនប់ត្រពាំងថ្ម ជាពិសេស ថាតើលោកមានបានធ្វើការកត់សម្គាល់អំពីស្ថានភាពរស់នៅ និង ស្ថានភាពការងារ<របស់កម្មករ>នៅការដ្ឋានទាំងពីរនោះដែរឬទេ? <តើលោកអាចជម្រាបជូនតុលាការអំពីអ្វីដែលលោកនៅចាំអំពីដំណើរទស្សនកិច្ចទៅការដ្ឋានទំនប់ទាំងពីរនោះបានដែរឬទេ?>

[១៥:៤៧:៣៤]

**ឆ៖** ទំនប់១មករា ហ្នឹងអង្កាល់នុ៎ង ចាប់ផ្តើមធ្វើអត់ទាន់រួចល្អទេ គ្រាន់តែទៅមើលរាងខាងៗទេ អត់ទាន់រួច ១០០ភាគរយទេ។ ប៉ុន្តែបើមុនៗនុ៎ង ខ្ញុំធ្លាប់ទៅ ឃើញមនុស្សកុះករ កកកុញ ដូចស្រមោចជញ្ជូនដី មនុស្សនោះ ប្រមូលមួយភូមិភាគហើយ កងចល័តដូចស្រមោចអ៊ីចឹង។ រួចបើទៅទំនប់ត្រពាំងថ្មវិញ អត់មានឃើញមនុស្សច្រើនទេ ព្រោះអង្កាល់ហ្នឹង គេស្ទួងរួចហើយ គ្រាន់តែថា ទៅមើលភាពរីក

ចម្រើន វាលស្រែ វាលស្រូវ ដ៏ខៀវខ្ចី កំពុងតែចេញខ្លះ កំពុងតែស្ទួងខ្លះ ទុំខ្លះ ខ្លះខិន។ និងទៅមើលរោងសិប្បកម្មមួយនៅក្បែរនុ៎ង កន្លែងចិញ្ចឹមនាងធ្វើសូត្រអីហ្នឹង នៅស្រុកភ្នំស្រុក នៅភូមិភាគពាយ័ព្យហ្នឹង ពេលហ្នឹង តាញ៉ឹម មកជូនរហូតជាមួយគណៈប្រតិភូហ្នឹង ព្រោះ ប៉ុល ពត គាត់ទៅដែរ។ អត់ទៅតែអ៊ំនួន ទេ កាលហ្នឹង ហើយនិងអ៊ំខៀវ សំផន នុំងអត់ជូនទៅទេ គាត់នៅចាំផ្ទះ តាមខ្ញុំចាំ។ ក្រៅពីនុំងទៅទាំងអស់។ ឡានច្រើនណាស់ ជាប់ប្រហែលជា៥០, ៦០, ៧០គ្រឿង។

**ស៖** បាទខ្ញុំបញ្ជាក់ឲ្យបានច្បាស់ដើម្បីប្រតិចារឹក។ នៅពេលលោកទៅកាន់ការដ្ឋានទំនប់១មករា នៅស្ទឹងជីនិត តើ ប៉ុល ពត មានបានធ្វើដំណើរទៅជាមួយនឹងប្រតិភូចិនដែរទេ នៅពេលដែលប្រតិភូចិនហ្នឹងធ្វើដំណើរទៅកាន់ទំនប់ ១មករា នោះ?

[១៥:៤៩:៥៥]

**ឆ៖** ប៉ុល ពត គាត់ទៅជាមួយរហូត។ គាត់ដើរទៅជាមួយរហូត ព្រោះគាត់ជាម្ចាស់ផ្ទះហើយ គាត់ប្រតិភូចិន ឆឹង យឹង គួយ ហ្នឹង គាត់ជាភ្ញៀវ អ៊ីចឹងម្ចាស់ផ្ទះអត់អាចដើរចោលគាត់ទេ ទៅទីណាក៏គាត់ទៅតាមដែរ។

**ស៖** ខ្ញុំចង់ស្វែងយល់អំពីពេលវេលាឲ្យបានច្បាស់ ហើយនិងអានឲ្យលោកស្ដាប់នូវការផ្សព្វផ្សាយតាមវិទ្យុកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី០៧ ធ្នូ ៧៧។ <លោកប្រធាន> នេះគឺឯកសារ E3/1339 – E3/1339, ERN អង់គ្លេស 00168335 ដល់36, ខ្មែរ <01169188> ដល់ 89 <អត់ទាន់មានការបកប្រែជាភាសាបារាំងទេ។> វិទ្យុកម្ពុជាប្រជាធិបតេយ្យនេះនិយាយអំពីប្រតិភូចិនដឹកនាំដោយ ឆឹង យឹងគួយ នេះគឺថាទៅទស្សនកិច្ចនៅភូមិភាគកណ្ដាល។ "នៅព្រឹកថ្ងៃទី០៦ <ធ្នូ ឆ្នាំ១៩៧៧> សមមិត្ត យឹងគួយ សមាជិកការិយាល័យនយោបាយមជ្ឈិមបក្សនៃគណមជ្ឈិមបក្សកុម្មុយនីស្តចិន និងប្រតិភូចិនដទៃទៀតបានទៅទស្សនកិច្ចនៅ<ចម្ការកប្បាស និងវាលស្រែ នៅ>វាលស្បូវដោយមានការអមដំណើរដោយសមមិត្ត ប៉ុល ពត, វន វ៉េត, ជួន ជឿន រដ្ឋមន្ត្រីក្រសួងសុខភាពសាធារណៈ, ពក លេខាគណៈកម្មាធិការបក្សកុម្មុយនីស្តកម្ពុជាភូមិភាគកណ្ដាល <និង អាន ជាអនុលេខា>។ នៅពេលរសៀលប្រតិភូភាតរភាពចិននេះបានទៅទស្សនកិច្ច<វាលស្រែ> នៅបារាយ និងនៅទំនប់១មករា។ កម្មាភិបាល និងប្រជាជនរាប់ពាន់នាក់ <ក្នុងទឹកចិត្តបដិវត្តន៍ដ៏ជ្រាលជ្រៅជាបងប្អូន ក៏មានវត្តមានដើម្បី>ស្វាគមន៍ចំពោះដំណើរទស្សនកិច្ច<របស់ភ្ញៀវកិត្តិយស>។" តើលោកនៅចាំទេ ថាតើ ប៉ុល ពត និងថ្នាក់ដឹកនាំបក្សដទៃទៀតធ្វើដំណើរទៅជាមួយនឹងប្រតិភូចិនទេ រួមទាំង វន វ៉េត ក៏ដូចជាលេខាភូមិភាគកណ្ដាល គឺ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

កែ ពក គឺលោកបាន -- តើលោកបានឃើញអ្នកទាំងនោះទេ?

[១៥:៥២:៥៦]

**ឆ៖** បាទ បានឃើញដូចអ៊ីចឹងមែន ព្រោះកាលណាទៅដល់ភូមិភាគមួយៗ គឺគណៈភូមិភាគមកទទួលហើយ ព្រោះដូចថាមេទៅពីភ្នំពេញហើយ មិនមកទទួលម៉េច ហើយសុទ្ធតែថ្នាក់ដឹកនាំបក្ស។ ត្រឹមត្រូវ សង្ខេបឲ្យខ្លីថាត្រឹមត្រូវ។ រួចមនុស្សកកកុញច្រើនមែន ច្រើនណាស់ មីដេរដាស ដូចខ្ញុំនិយាយពាក្យសាមញ្ញថា ដូចស្រមោចអ៊ីចឹង វាច្រើនពេក។

**ស៖** ក្នុងដំណើរទស្សនកិច្ចជាមួយប្រតិភូចិន តើអ្នកណាជាអ្នកចាត់តាំងលោកឲ្យបើកបរជូនភ្ញៀវនោះ?

**ឆ៖** សមមិត្ត មៀល។ កាលហ្នឹង សមមិត្ត មៀល គាត់ឲ្យខ្ញុំបើក ដំបូងខ្ញុំបើកជូនតា ជួន ជឿន ក្រោយមកដល់ទៅដល់ស្នួង ខាងអ្នកបើកឡានកុនហ្នឹងយឺតពេក គាត់ថាឡានកុន គេត្រូវជ្រេរចុះឡើងពេលគណៈប្រតិភូចង់ឲ្យទៅមុខ រួចអាឡានបើកយឺតអត់ថតទាន់ទេ អ៊ីចឹងសមមិត្ត មៀល ហ្នឹងឲ្យខ្ញុំមកបើកឡានកុនវិញ ដើម្បីស្រួលចល័តក្នុងគណៈប្រតិភូ។ នៅពេលហ្នឹង ខ្ញុំទៅឃើញថ្នាក់ដឹកនាំជិតៗ ព្រោះកាលណាយើងទៅថតៗយករូបភាពក្បែរៗហ្នឹង ក្បែរគណៈប្រតិភូហ្នឹង ធ្លាប់ឃើញគាត់តាំងពីបូព៌ាហ្នឹងរហូតទៅ ដូចខ្ញុំលើកឡើងទៅខាងភ្នំស្រុកហ្នឹង មួយជុំប្រទេសហ្នឹងទៅដល់កំពង់សោមជិះនាវាប្រដេញអាធំៗទៀតណោះ អត់មានជិះអាតូចៗទេ ជិះសុទ្ធតែអាពួកគេហៅនាវាពិឃាដ គណៈប្រតិភូហ្នឹងជិះសុទ្ធតែអាហ្នឹងទៀតទៅមើលឆ្នេរសមុទ្រ អត់មានជិះអាធំៗទៅទេ អានាវាហ្នឹងតូចៗទេ ប៉ុនគ្រាប់វាប៉ុនៗគល់ត្នោត។

[១៥:៥៥:៣៦]

**ស៖** សំណួរចុងក្រោយពាក់ព័ន្ធទៅនឹងការចាត់តាំងឲ្យបើកបរជូនភ្ញៀវ តើ<អ្នកដែលនៅ>មន្ទីររបស់លោកគឺក-១២នេះ ជាអ្នកបើកបរជូនប្រតិភូចិន ឆឹង យឹងគួយ នេះ ឬហើយបើអ៊ីចឹងមែន តើនៅ<នរណាដែលមកពី>មន្ទីររបស់លោកហ្នឹង <ត្រូវបានគេ>ចាត់តាំង<>ឲ្យបើកបរជូនប្រតិភូចិនហ្នឹង?

**លោក វ៉ិចទ័រ កូប៉េ៖**

ជាការកត់សម្គាល់ខ្លីមួយទេ នេះគឺ<សាក្សីដំបូង នៅក្នុង>វគ្គចុងក្រោយពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ។ សហព្រះរាជអាជ្ញាអាចសួរសំណួរបានមួយសេរីតាមគាត់ចង់សួរ ក៏ប៉ុន្តែ<ខ្ញុំមិនបានឮសំណួរណាមួយ>ពាក់ព័ន្ធទៅនឹងតួនាទី<ទី២>របស់ជនជាប់ចោទ<នោះទេ។ ដើម្បីជាព័ត៌មាន

ដល់គ្រប់គ្នា គឺថា>យើងខ្ញុំមិនជំទាស់ទេ ជាពិសេសពាក់ព័ន្ធនឹងដំណើរទស្សនកិច្ចរបស់ប្រតិភូចិននេះ គឺទៅមើលការដ្ឋានទាំងនោះគឺមិន យើងខ្ញុំមិនជំទាស់ទេ។ <យើងបានពិភាក្សារឿងនេះច្រើនមកហើយ នៅពេលដែលយើងសួរដេញដោលអំពីការដ្ឋានទាំងនោះ>។ ហើយគ្រាន់ថាជម្រាបតាមត្រង់ទៅគឺថា ការដែលសួរច្រើនរបៀបនេះគឺវានាំឲ្យខាតពេលវេលា ហើយថាតើមានកំណត់អ្វីច្បាស់លាស់ដែរ ចំពោះសវនាការវគ្គនេះលោកសហព្រះរាជអាជ្ញារង?

**លោក ឌេល លីសាក់៖**

ខ្ញុំមិនសប្បាយចិត្តទេចំពោះការបន្ទច់បង្អាក់ការ -- បាទការមកនិយាយប្រមាថរបៀបនេះ ពីភាគីមួយផ្សេងទៀតនោះ។ <ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ> គាត់បានប្រាប់ហើយ គាត់បានចូលរួមរៀនសូត្រវគ្គនយោបាយជាមួយនឹង នួន ជា និង ខៀវ សំផន គាត់បានរៀបរាប់វែងឆ្ងាយណាស់ ហើយខ្ញុំនឹងសួរអំពីតួនាទីនេះ ហើយគាត់មានការដឹងច្រើនមែនទែនពីប្រភពផ្សេងៗ។ អ៊ីចឹងហើយបានខ្ញុំព្យាយាមសាកសួរដើម្បីស្វែងរកឲ្យឃើញ ឈានទៅដល់ចំណុចដែលត្រូវចង់សួរនោះតែម្ដង។

[១៥:៥៧:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ បន្តការតាំងសំណួរតទៅទៀត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** បាទលោកប្រធាន។ អ្វីដែលខ្ញុំចាប់អារម្មណ៍លោកគឺ ថាមន្ទីររបស់លោកហ្នឹងគឺត្រូវបានគេចាត់តាំង<>ឲ្យទៅបើកបរជូន<ប្រធានគណៈប្រតិភូភូមា និងគណៈប្រតិភូមិជាន់ខ្ពស់>ចិន។ <តើអ្នកដែលមកពី>មន្ទីររបស់លោកនេះ <គឺត្រូវបានគេ>ចាត់តាំងឲ្យបើកបរ<ជូន>ប្រតិភូភូមា ប្រតិភូឡាវ ដូចប្រតិភូចិន អីង យីងគួយ <មែនទេ? តើមន្ទីររបស់លោកហ្នឹងជឿទុកចិត្តបុគ្គលហ្នឹងដែរទេ>?

**លោក ស សារិន៖**

**ឆ៖** ដូចគ្នា ព្រោះមានតែមួយទេ សូមជម្រាបប្រសាសន៍លោកសហព្រះរាជអាជ្ញា អង្គភាពឡានដែលទំនើបៗគឺនៅមន្ទីរក-១២ ទាំងអស់ទាំងឡានអ៊ំៗហ្នឹងក៏នៅហ្នឹងទាំងអស់ ឡានទទួលភ្ញៀវក៏នៅហ្នឹងទាំងអស់ គាត់អត់មានយកទៅដាក់ផ្ទះគាត់ជាកម្មសិទ្ធទេ គាត់មហាសន្សំសំចៃហើយ ជិះតែឡាំប្រ៊ីតាទេ ដាក់ដំបូលក្រណាត់ កម្រពីណាដាក់ស្គាល់អត្តសញ្ញាណគាត់ណាស់ ទាល់នៅដូចពួកខ្ញុំបានស្គាល់។ លើកលែងតែទៅទទួលភ្ញៀវទៅបានគាត់ជិះឡានល្អទៅ គាត់ដើរធ្វើការជិះឡានឡាំប្រ៊ីតាយើង

ដូចផ្សារអូរឫស្សី ខ្ញុំហៅថាអ៊ីចឹងចុះ អាម៉ាកហុងដាម៉ាកស៊ុយសុគីហ្នឹង ដាក់ដំបូលក្រណាត់គាត់អង្គុយនៅហ្នឹង ទាំងអ៊ំនួន, ទាំងអ៊ំ ខៀវ សំផន, អ៊ំវន វ៉េត, អ៊ំប្រាង អីហ្នឹងដូចគ្នាអ៊ីចឹង។ គាត់រៀបៗបើថាឲ្យរៀបក៏នៅកន្លែងខ្ញុំហ្នឹងដែរ ព្រោះកន្លែងហ្នឹងជាកន្លែងទទួលរថយន្តភ្ញៀវក្នុងនិងក្រៅស្រុកតែម្តង។ តែប្រពន្ធកូនគាត់ក៏មិនដែលជិះឡានម៉ាកសីដេសទៅមើលសិល្បៈដែរ ជំនាន់ហ្នឹងនោះគាត់ចាំណាស់។ សម័យហ្នឹងអត់ហៅថាចាំទេ គេហៅថាសន្សំសំចៃ ព្រោះគាត់ថា១៥ឆ្នាំទៀត បានបក្សយើងនាំរបស់ហ្នឹងចូល។ អ៊ីចឹងយើងប្រើប្រាស់ ហើយគាត់សង្កត់ធ្ងន់ណាស់ ក្រុមឡានហ្នឹង ពិបាកជាងគេបង្អស់ ខ្លាចរឿងគ្រោះថ្នាក់ តែបុកហើយ បាត់ខ្លួនហើយ ព្រោះភាគច្រើន ខ្ញុំសម្គាល់អ៊ីចឹង។ ឃើញអ្នកបើកបុក បើកទូក បើកក្រឡាប់ មិនដែលឃើញៗនៅទៀតទេ ឃើញតែបាត់ទៅ ទៅផ្លាស់ប្តូរភារកិច្ចទៅ ដូចមិត្តវ៉េត, មិត្តរី, តាឈយ, តាភួងអី ហើយខ្ញុំធ្លាប់ឃើញមានបញ្ហាៗកន្លងមកហ្នឹង ប៉ុន្តខ្ញុំមិនដែលហ៊ានដេញដោល។ អាហ្នឹងខ្ញុំគ្រាន់តែបញ្ជាក់លោកសហព្រះរាជអាជ្ញាអំពីទុក្ខព្រួយ ទុក្ខលំបាកខ្ញុំកាលនុ៎ង។

[១៦:០០:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សវនាសការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃព្រហស្បតិ៍ទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃទី១០ វិច្ឆិកា អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ស សារិន និងមានសក្សីបម្រុង 2-TCW-913 នឹងអាចមានដើមបណ្តឹងរដ្ឋប្បវេណីបម្រុង 2-TCPP-235 ពាក់ព័ន្ធនឹងអង្គហេតុតួនាទីរបស់ជនជាប់ចោទ សូមភាគីជ្រាប និងអញ្ជើញចូលរួមបានតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក ស សារិន សវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនៅមិនទាន់ចប់នៅឡើយទេ ហើយអង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃព្រហស្បតិ៍ ទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦។

ហើយឲ្យមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ទៅកាន់ទីកន្លែងគាត់ស្នាក់នៅ ហើយនិងឲ្យអញ្ជើញគាត់មកចូលរួមសវនាការនៅថ្ងៃព្រហស្បតិ៍ ទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ ទៀត។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបលោក នួន ជា និងលោក

ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការនៅថ្ងៃថ្ងៃព្រហស្បតិ៍ ទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*